# Language: ខ្មែរ (Khmer)

## Book: Matthew

## Matthew

### ជំពូក 1

1 នេះជាសៀវភៅរាយនាមអំពីព្រះយេស៊ូគ្រិស្ដ ជាព្រះរាជវង្សរបស់ព្រះបាទដាវីឌ ដែលត្រូវជាពូជពង្សរបស់លោកអប្រាហាំ។ 2 លោកអប្រាហាំបង្កើតលោក
អ៊ីសាក លោកអ៊ីសាកបង្កើតលោកយ៉ាកុប លោកយ៉ាកុបបង្កើតលោកយូដា និងបងប្អូនរបស់គាត់។ 3 លោកយូដា និងនាងតាម៉ារបង្កើតលោកពេរេស និងលោក
សេរ៉ាស លោកពេរេសបង្កើតលោកហេស្រុន លោកហេស្រុនបង្កើតលោកអើរ៉ាម 4 លោកអើរ៉ាមបង្កើតលោកអមីណាដាប់ លោកអមីណាដាប់បង្កើតលោក
ណាសូន លោកណាសូនបង្កើតលោកសាលម៉ូន។ 5 លោកសាលម៉ូន និងនាងរ៉ាហាបបង្កើតលោកបូអូស លោកបូអូស និងនាងរស់បង្កើតលោកអូបេដ
ហើយលោកអូបេដបង្កើតលោកអ៊ីសាយ។ 6 លោកអ៊ីសាយបង្កើតស្តេចដាវីឌ ហើយស្ដេចដាវីឌ និងភរិយារបស់អ៊ូរី បង្កើតស្តេចសាឡូម៉ូន។ 7 សាឡូម៉ូនបង្កើត
រេហូបោម រេហូបោមបង្កើតអប៊ីយ៉ា អប៊ីយ៉ាបង្កើតអេសា។ 8 អេសាបង្កើតយ៉ូសាផាត យ៉ូសាផាតបង្កើតយ៉ូរ៉ាម យ៉ូរ៉ាមបង្កើតអូសៀស។ 9 អូសៀសបង្កើតយ៉ូថាម
យ៉ូថាមបង្កើតអេហាស អេហាសបង្កើតអេសេគាស។ 10 អេសេគាសបង្កើតម៉ាណាសេ ម៉ាណាសេបង្កើតអាំម៉ូន អាំម៉ូនបង្កើតយ៉ូសៀស។ 11 យ៉ូសៀសបង្កើត
យេកូនាស និងប្អូនប្រុសរបស់គាត់ ក្នុងគ្រាដែលគេនិរទេស ទៅស្រុកបាប៊ីឡូន។ 12 ក្រោយពីនិរទេសទៅស្រុកបាប៊ីឡូន លោកយេកូនាសបង្កើតលោក
សាលធាល លោកសាលធាលបង្កើតលោកសូរ៉ូបាបិល។ 13 លោកសូរ៉ូបាបិលបង្កើតលោកអប៊ីយូដ លោកអប៊ីយូដបង្កើតលោកអេលាគីម លោកអេលាគីម
បង្កើតលោកអេសូរ។ 14 លោកអេសូរបង្កើតលោកសាដុក លោកសាដុកបង្កើតលោកអេគីម លោកអេគីមបង្កើតលោកអេលីយូដ។ 15 លោកអេលីយូដបង្កើត
លោកអេឡាសារ លោកអេឡាសារបង្កើតលោកម៉ាថាន លោកម៉ាថាន បង្កើតលោកយ៉ាកុប។ 16 លោកយ៉ាកុបបង្កើតលោកយ៉ូសែប ជាស្វាមីរបស់នាងម៉ារី
ដែលបង្កើតព្រះយេស៊ូ ដែលហៅថាព្រះគ្រិស្ដ។ 17 ពីជំនាន់លោកអប្រាហាំមកដល់ស្តេចដាវីឌ មានដប់បួនតំណ ពីស្តេចដាវីឌមកដល់នឹងគ្រា ដែល
គេនិរទេសទៅស្រុកបាប៊ីឡូន មានដប់បួនតំណ ហើយចាប់ពីគ្រាដែលគេនិរទេសទៅស្រុកបាប៊ីឡូនមកទល់ព្រះគ្រិស្ដ ក៏មានដប់បួនតំណដែរ។ 18 នេះជា
ដំណើររឿងស្ដីអំពីកំណើតរបស់ព្រះយេស៊ូគ្រិស្ដ។ នាងម៉ារីជាមាតារបស់ព្រះអង្គ ត្រូវជាគូដណ្តឹងរបស់លោកយ៉ូសែប។ មុនពេលពួកគេរួមរស់ជាមួយគ្នា នាងម៉ារី
មានផ្ទៃពោះ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធរួចទៅហើយ។ 19 លោកយ៉ូសែបដែលជាស្វាមីរបស់នាង ជាមនុស្សសុចរិត ហើយលោកមិនចង់បំបាក់មុខនាង
ជាសាធារណៈឡើយ។ ដូច្នេះ លោកបានសម្រេចចិត្តផ្តាច់ពាក្យជាមួយនាងដោយស្ងាត់ៗវិញ។ 20 ពេលដែលគាត់កំពុងគិតដូច្នេះ ស្រាប់តែមានទេវតារបស់
ព្រះអម្ចាស់ លេចមកប្រាប់គាត់ក្នុងសុបិនថា៖ «យ៉ូសែប! ជាព្រះរាជវង្សរបស់ព្រះបាទដាវីឌអើយ! សូមកុំខ្លាចនឹងទទួលយកនាងម៉ារីមកធ្វើជាភរិយាឡើយ
ពីព្រោះបុត្រដែលនៅក្នុងផ្ទៃនាង កើតមកពីព្រះវិញ្ញាណដ៏វិសុទ្ធទេ។ 21 នាងនឹងសម្រាលបានបុត្រមួយ ហើយត្រូវថ្វាយព្រះនាមថា យេស៊ូ ដ្បិតបុត្រនោះនឹង
សង្គ្រោះប្រជារាស្ត្រព្រះអង្គ ឲ្យរួចពីបាបរបស់គេ»។ 22 ហេតុការណ៍នេះកើតឡើង ស្របតាមសេចក្ដីដែលព្រះអម្ចាស់មានព្រះបន្ទូល តាមរយៈព្យាការីថា៖ 23
«មើល! ស្ត្រីព្រហ្មចារីនឹងមានផ្ទៃពោះ ហើយនាងនឹងសម្រាលបានបុត្រមួយ គេនឹងថ្វាយព្រះនាមថា «អេម៉ាញូអែល» មានន័យថា «ព្រះជាម្ចាស់គង់ជាមួយ
យើង»។ 24 លុះលោកយ៉ូសែបភ្ញាក់ពីដំណេក លោកក៏ធ្វើតាមបង្គាប់ទេវតា គឺលោកទទួលនាងម៉ារីមកធ្វើជាភរិយា។ 25 ប៉ុន្តែ លោកពុំបានរួមបវេណីជាមួយ
នាង រហូតដល់នាងសម្រាលបានបុត្រ។ រួចលោកថ្វាយព្រះនាមថា «យេស៊ូ»។

---


generated on Thu Feb 8 15:37:30 2024

## ជំពូក 2

1 បន្ទាប់ពីព្រះយេស៊ូប្រសូតនៅក្នុងភូមិបេថ្លេហិម ស្រុកយូដា ក្នុងរជ្ជកាលព្រះបាទហេរ៉ូដ មានពួកហោរាចារ្យធ្វើដំណើរពីទិសខាងកើតមកដល់
យេរូសាឡឹមដោយសួរថា៖ 2 «តើព្រះអង្គដែលប្រសូតមកជាមហាក្សត្ររបស់ជនជាតិយូដាគង់នៅឯណា? យើងបានឃើញផ្កាយរបស់ព្រះអង្គពីទិសខាងកើត
ហើយយើងមកថ្វាយបង្គំព្រះអង្គ»។ 3 កាលព្រះបាទហេរ៉ូដឮដំណឹងនេះ ព្រះអង្គមានព្រះហឫទ័យរន្ធត់យ៉ាងខ្លាំង ហើយអ្នករស់នៅយេរូសាឡឹមទាំងអស់ ក៏
រន្ធត់ចិត្តជាមួយព្រះអង្គដែរ។ 4 ព្រះបាទហេរ៉ូដកោះហៅពួកនាយកបូជាចារ្យ និងពួកអាចារ្យទាំងប៉ុន្មានរបស់ប្រជាជនមក ហើយសួរគេពីទីកន្លែងដែលព្រះគ្រិស្ត
បានប្រសូត។ 5 ពួកគេទូលប្រាប់ស្ដេចថា ព្រះគ្រិស្តប្រសូតនៅភូមិបេថ្លេហិម ក្នុងស្រុកយូដា ព្រោះមានសេចក្ដីចែងទុកមកតាមរយៈព្យាការីថា៖ 6 «បេថ្លេហិមជា
ដែនដីយូដាអើយ! អ្នកមិនមែនតូចជាងគេទេ ក្នុងក្រុងសំខាន់ៗនៃស្រុកយូដា ដ្បិតនឹងមានមេដឹកនាំមួយរូបកើតចេញពីអ្នក លោកនឹងមើលថែជនជាតិ
អ៊ីស្រាអែលរបស់យើង»។ 7 ក្រោយមក ព្រះបាទហេរ៉ូដហៅពួកហោរាចារ្យមកជាសម្ងាត់ សួរបញ្ជាក់យ៉ាងហ្មត់ចត់ពីពេលដែលផ្កាយរះឡើង។ 8 ព្រះអង្គចាត់
ពួកគេទាំងនោះឲ្យទៅបេថ្លេហិម ដោយបង្គាប់ថា៖ «នាំគ្នាទៅចុះ! ហើយស៊ើបសួរដំណឹងអំពីព្រះបុត្រនោះអោយបានច្បាស់លាស់។ កាលបើបានឃើញ
បុត្រនោះហើយ សូមមកប្រាប់យើងវិញផង ដើម្បីឲ្យយើងទៅថ្វាយបង្គំព្រះអង្គដែរ»។ 9 បន្ទាប់ពីបានឮបញ្ជារបស់ស្ដេចហើយ ពួកគេក៏នាំគ្នាចេញទៅ
ហើយផ្កាយដែលគេបានឃើញនៅទិសខាងកើត ក៏នាំមុខគេជានិច្ចរហូតដល់កន្លែងដែលព្រះបុត្រគង់នៅទើបឈប់។ 10 កាលហោរាចារ្យទាំងនោះឃើញ
ផ្កាយហើយ គេសប្បាយចិត្តយ៉ាងខ្លាំង។ 11 ពួកគេចូលទៅក្នុងផ្ទះ ហើយឃើញព្រះបុត្រនៅជាមួយនាងម៉ារី ជាមាតារបស់ព្រះអង្គ។ ពួកគេក៏នាំគ្នាថ្វាយបង្គំ
ព្រះអង្គ រួចក៏បើកហិបយកទ្រព្យរបស់ខ្លួនមក គឺមាន មាស គ្រឿងក្រអូប និងជ័រល្វីងទេសថ្វាយដល់ព្រះអង្គ។ 12 ព្រះជាម្ចាស់មានព្រះបន្ទូលព្រមានគេ ក្នុង
សុបិនមិនឲ្យវិលទៅជួបព្រះបាទហេរ៉ូដវិញឡើយ បន្ទាប់មក ពួកគេវិលត្រឡប់ទៅស្រុករបស់ខ្លួនវិញ តាមផ្លូវមួយផ្សេងទៀត។ 13 បន្ទាប់ពីពួកហោរាចារ្យចាក
ចេញទៅ ទេវតារបស់ព្រះអម្ចាស់លេចមកប្រាប់លោកយ៉ូសែបក្នុងសុបិនថា៖ «ក្រោកឡើង! នាំព្រះបុត្រ និងមាតារបស់ព្រះអង្គ ភៀសខ្លួនទៅអេស៊ីបទៅ។ ត្រូវ
ស្នាក់នៅកន្លែងនោះ រហូតដល់យើងប្រាប់ឲ្យវិលត្រឡប់មកវិញសឹមមក ពីព្រោះព្រះបាទហេរ៉ូដរកសម្លាប់ព្រះបុត្រ»។ 14 យប់នោះលោកយ៉ូសែបក្រោកឡើង
ហើយនាំព្រះបុត្រ និងមាតារបស់ព្រះអង្គ រត់ភៀសខ្លួនទៅអេស៊ីបទាំងយប់។ 15 គាត់នៅទីនោះរហូតដល់ព្រះបាទហេរ៉ូដសោយទិវង្គត ការនេះកើតឡើងស្រប
នឹងសេចក្ដី ដែលព្រះអម្ចាស់មានព្រះបន្ទូលតាមរយៈព្យាការីថា៖ «យើងហៅបុត្រយើងចេញពីអេស៊ីបមក»។ 16 បន្ទាប់ពីព្រះបាទហេរ៉ូដយល់ថា ពួកហោរាចារ្យ
បានបំបាក់មុខព្រះអង្គ ព្រះអង្គព្រះពិរោធយ៉ាងខ្លាំង ហើយក៏ចេញបញ្ជាឲ្យគេសម្លាប់ក្មេងប្រុសៗទាំងអស់ក្នុងភូមិបេថ្លេហិម និងភូមិជិតខាង ចាប់ពីអាយុយពីរ
ឆ្នាំចុះក្រោម គឺតាមកំណត់ថ្ងៃដែលទ្រង់បានសួរបញ្ជាក់ពួកហោរាចារ្យ។ 17 ហេតុការណ៍នេះកើតឡើង ស្របតាមសេចក្ដីដែលបានចែងទុកតាមរយៈព្យាការី
យេរេមាថា៖ 18 «មានឮសំឡេងពីរ៉ាម៉ាមកជាទំនួញយំសោក និងកាន់ទុក្ខ គឺនាងរ៉ាជែលយំសោកអាណិតកូននាង ហើយនាងមិនព្រមអោយនរណាសម្រាល
ទុក្ខនាងឡើយ ព្រោះកូននាងបាត់បង់ជីវិតអស់ទៅហើយ»។ 19 ក្រោយពីព្រះបាទហេរ៉ូដសោយទិវង្គត ទេវតារបស់ព្រះអម្ចាស់បានលេចមកប្រាប់លោកយ៉ូសែប
នៅអេស៊ីបក្នុងសុបិនថា៖ 20 «ក្រោកឡើង! នាំព្រះបុត្រ និងមាតារបស់ព្រះអង្គត្រឡប់ទៅអ៊ីស្រាអែលវិញទៅ ដ្បិតពួកអ្នកដែលប៉ុនប៉ងមកលើព្រះកុមារបាន
ស្លាប់បាត់អស់ទៅហើយ»។ 21 យ៉ូសែបក្រោកឡើង នាំព្រះបុត្រ និងមាតារបស់ព្រះអង្គត្រឡប់ទៅអ៊ីស្រាអែលវិញ។ 22 ប៉ុន្តែ កាលលោកឮថា ព្រះបាទ
អើខេឡោសឡើងគ្រងរាជ្យនៅស្រុកយូដា ស្នងស្ដេចហេរ៉ូដជាព្រះបិតា លោកភ័យខ្លាចមិនហ៊ានទៅស្រុកនោះទេ លោកភៀសខ្លួនទៅកាលីឡេ
ដោយព្រោះព្រះជាម្ចាស់ប្រាប់លោកឲ្យដឹងក្នុងសុបិន។ 23 លោកទៅរស់នៅ ក្នុងភូមិមួយឈ្មោះណាសារ៉ែត ការនេះកើតឡើងស្របតាមសេចក្ដីដែលពួកព្យាការី
បានថ្លែងទុកថា៖ គេនឹងហៅព្រះអង្គថា ជាអ្នកភូមិណាសារ៉ែត។

## ជំពូក 3

1 នៅគ្រានោះ លោកយ៉ូហានបាទីស្ដប្រកាសនៅវាលរហោស្ថាន ស្រុកយូដាថា៖ 2 «ចូរប្រែចិត្តឡើង! ដ្បិតព្រះរាជ្យនៃស្ថានបរមសុខ ជិតមកដល់ហើយ!»។ 3
លោកនេះហើយដែលព្យាការីអេសាយបានថ្លែងទុកអំពីលោកថា៖ «មានសំឡេងមួយស្រែកឡើងនៅវាលរហោស្ថានថា៖ ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់ ចូរតម្រង់
ផ្លូវថ្វាយព្រះអង្គ!»។ 4 លោកយ៉ូហានស្លៀកសម្លៀកបំពាក់ធ្វើអំពីរោមអូដ្ឋ ហើយខ្សែក្រវាត់គាត់ធ្វើអំពីស្បែក។ លោកបរិភោគកណ្ដូប និងទឹកឃ្មុំធ្វើជាអាហារ។
5 អ្នករស់នៅយេរូសាឡឹម ស្រុកយូដា និងអ្នកស្រុកនៅតំបន់ ទន្លេយ័រដាន់ទាំងមូលនាំគ្នាមករកលោក។ 6 ពួកគេសារភាពអំពើបាបរបស់ខ្លួន ហើយលោកក៏ធ្វើ
ពិធីជ្រមុជទឹកឲ្យគេក្នុងទន្លេយ័រដាន់។ 7 ប៉ុន្តែកាលលោកឃើញពួកផារីស៊ី និងពួកសាឌូស៊ី មកទទួលពិធីជ្រមុជទឹកពីលោក លោកនិយាយទៅគេថា៖ «ឲ្យពូជ
ពស់វែកអើយ! តើនរណាប្រាប់អ្នករាល់គ្នាឲ្យរត់គេចពីព្រះពិរោធ ដែលនឹងមកដល់ដូច្នេះ?។ 8 ចូរបង្កើតផលផ្លែល្អ ដើម្បីបញ្ជាក់ពីការដែលអ្នករាល់គ្នាបានកែប្រែ
ចិត្តគំនិតមែន។ 9 កុំគិតថាថាខ្លួនមានលោកអប្រាហាំជាបុព្វបុរសនោះឡើយ ខ្ញុំសូមប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់អាចបង្កើតកូនចៅលោក
អប្រាហាំចេញពីថ្មទាំងនេះក៏បានដែរ។ 10 ពូថៅដាក់នៅជិតគល់ឈើស្រេចហើយ ដើមឈើណាមិនផ្ដល់ផ្លែល្អទេ នឹងត្រូវកាប់ ហើយបោះចោលទៅក្នុងភ្លើង។
11 ខ្ញុំធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាដោយទឹក ដើម្បីអ្នករាល់គ្នាកែប្រែចិត្តគំនិត ប៉ុន្តែលោកដែលមកក្រោយខ្ញុំ មានអំណាចលើសខ្ញុំទៅទៀត។ ខ្ញុំមិនសក្តិសមសូម្បី
តែដោះស្បែកជើងជូនលោក។ លោកនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នា ដោយព្រះវិញ្ញាណដ៏វិសុទ្ធនិងដោយភ្លើងវិញ។ 12 លោកកាន់ចង្អេរ សម្អាតលានបោកស្រូវ
អុំស្រូវប្រមូលយកគ្រាប់ដាក់ក្នុងជង្រុក រីឯសំដី លោកនឹងដុតក្នុងភ្លើង ដែលឆេះរហូត»។ 13 ពេលនោះ ព្រះយេស៊ូយាងពីកាលីឡេទៅទន្លេយ័រដាន់ដើម្បីឲ្យ
លោកយ៉ូហានធ្វើពិធីជ្រមុជទឹកឲ្យ។ 14 ប៉ុន្តែ លោកយ៉ូហានព្យាយាមប្រកែកថា៖ «ខ្ញុំទេតើដែលត្រូវទទួលពិធីជ្រមុជទឹកពីលោក ម្ដេចក៏លោកមករកខ្ញុំវិញ?»។
15 ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយតបទៅគាត់ថា៖ «ចូរធ្វើម្ដងនេះសិនចុះ ដើម្បីឲ្យសម្រេចស្របតាមគ្រប់ទាំងសេចក្ដីសុចរិតដែលព្រះជាម្ចាស់បានបង្គាប់»។
លោកយ៉ូហានក៏យល់ព្រម។ 16 ក្រោយពេលទទួលពិធីជ្រមុជទឹករួចហើយ ព្រះយេស៊ូយាងឡើងពីទឹកភ្លាម ស្រាប់តែផ្ទៃមេឃបើកចំហ ទ្រង់ឃើញព្រះវិញ្ញាណ
របស់ព្រះជាម្ចាស់ចុះមកដូចសត្វព្រាប និងសណ្ឋិតលើព្រះអង្គ។ 17 មើល មានសំឡេងពីលើមេឃមកថា៖ «នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់
ព្រះទ័យនឹងព្រះអង្គខ្លាំងណាស់!»។

---

## ជំពូក 4

1 បន្ទាប់មក ព្រះវិញ្ញាណបាននាំព្រះយេស៊ូទៅវាលរហោស្ថានដើម្បីឲ្យមារសាតាំងល្បួង។ 2 ពេលទ្រង់បានតមអាហារអស់ពេលសែសិបយប់ សែសិបថ្ងៃមក
ព្រះអង្គក៏ចាប់ផ្ដើមឃ្លាន។ 3 មេល្បួងបានចូលមករកព្រះអង្គ ទាំងនិយាយថា៖ «ប្រសិនបើលោកពិតជាបុត្រារបស់ព្រះជាម្ចាស់មែន សូមបញ្ជាឲ្យដុំថ្មទាំងនេះ
ទៅជានំប៉័ងមើល៍!»។ 4 ប៉ុន្ដែ ព្រះយេស៊ូឆ្លើយតបទៅមេល្បួងវិញថា៖ «ក្នុងគម្ពីរបានចែងថា មនុស្សមិនមែនរស់ដោយសារតែនំប៉័ង ប៉ុណ្ណោះទេ គឺរស់ដោយសារ
គ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ»។ 5 បន្ទាប់មក មារបាននាំព្រះអង្គទៅក្រុងដ៏វិសុទ្ធ ដាក់ព្រះអង្គលើកំពូលព្រះវិហារ 6 ហើយ
និយាយថា៖ «ប្រសិនបើលោកពិតជាបុត្រារបស់ព្រះជាម្ចាស់មែន ចូរលោតទម្លាក់ខ្លួនចុះទៅក្រោមមើល៍ ដ្បិតក្នុងគម្ពីរបានចែងថា ព្រះជាម្ចាស់នឹងបញ្ជាឲ្យ
ទេវតាថែរក្សាលោក ចាំទ្រលើកលោកឡើង មិនឲ្យជើងលោកប៉ះទង្គិចនឹងថ្មឡើយ»។ 7 ព្រះយេស៊ូឆ្លើយតបទៅមារវិញថា៖ «ក្នុងគម្ពីរបានចែងទៀតថា
អ្នកមិនត្រូវល្បងលព្រះជាម្ចាស់ជាព្រះរបស់អ្នកឡើយ»។ 8 លើកនេះមារក៏នាំព្រះអង្គទៅកន្លែងយ៉ាងខ្ពស់មួយ ហើយបង្ហាញនគរទាំងប៉ុន្មានក្នុងពិភពលោក
ព្រមទាំងបង្ហាញឲ្យឃើញភាពរុងរឿងរបស់នគរទាំងនោះផង។ 9 មារនិយាយទៅកាន់ព្រះអង្គថា៖ «ខ្ញុំនឹងប្រគល់សម្បត្តិទាំងនេះឲ្យទៅលោកប្រសិនបើលោក
ក្រាបថ្វាយបង្គំខ្ញុំ!»។ 10 ក្រោយមកព្រះយេស៊ូនិយាយទៅកាន់មារថា៖ «ថយចេញពីទីនេះទៅសាតាំងអើយ! ដ្បិតក្នុងគម្ពីរបានចែងថា អ្នកត្រូវថ្វាយបង្គំ
ព្រះអម្ចាស់ជាព្រះរបស់អ្នក និងបំរើតែព្រះអង្គមួយប៉ុណ្ណោះ»។ 11 ក្រោយមក មារក៏ចាកចេញពីព្រះអង្គទៅ រួចមានពួកទេវតានាំគ្នាចូលមក និងបម្រើព្រះអង្គ។
12 កាលព្រះយេស៊ូឮដំណឹងថា គេបានចាប់លោកយ៉ូហានដាក់ឃុំឃាំងហើយ ព្រះអង្គក៏ភៀសចេញទៅស្រុកកាលីឡេ។ 13 ព្រះអង្គចាកចេញពីភូមិ
ណាសារ៉ែត ទៅរស់នៅក្រុងកាពើណិមជិតមាត់សមុទ្រ ក្នុងតំបន់សាប់យូឡូន និងណែបថាលី។ 14 ការនេះកើតឡើងដើម្បីឲ្យបានស្របនឹងសេចក្ដីដែល
បានចែងទុកតាមរយៈព្យាការីអេសាយថា៖ 15 «ដែនដីសាប់យូឡូន និងណែបថាលី ដែលជាផ្លូវឆ្ពោះទៅកាន់សមុទ្រអើយ! ខាងនាយទន្លេយ័រដាន់ ស្រុក
កាលីឡេដែលជាកន្លែងសាសន៍ដទៃរស់នៅអើយ! 16 ប្រជាជនដែលអង្គុយនៅក្នុងទីងងឹត បានឃើញពន្លឺមួយដ៏អស្ចារ្យ ហើយពួកអ្នករស់ក្នុងស្រុកដែលស្ថិត
នៅក្រោមអំណាចនៃសេចក្ដីស្លាប់ នឹងមានពន្លឺមួយលេចឡើងបំភ្លឺពួកគេ»។ 17 ចាប់តាំងពីគ្រានោះមក ព្រះយេស៊ូចាប់ផ្ដើមប្រកាសនិងនិយាយថា៖ «ចូរកែប្រែ
ចិត្តឡើង! ដ្បិតព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ»។ 18 កាលព្រះអង្គយាងតាមឆ្នេរសមុទ្រកាលីឡេ ទ្រង់បានឃើញបងប្អូនពីរនាក់គឺស៊ីម៉ូន ហៅ
ពេត្រុស និងអនទ្រេ ជាប្អូនរបស់គាត់ ដែលកំពុងតែបង់សំណាញ់ ពួកគេជាអ្នកនេសាទ។ 19 ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកគេថា៖ «សូមអញ្ជើញមកតាម
ខ្ញុំចុះ ខ្ញុំនឹងតាំងអ្នកឲ្យនេសាទមនុស្សវិញ»។ 20 ភ្លាមនោះអ្នកទាំងពីរក៏ទុកសំណាញ់ចោល រួចដើរតាមព្រះអង្គទៅ។ 21 កាលព្រះយេស៊ូយាងទៅមុខបន្តិច
ព្រះអង្គឃើញបងប្អូនពីរនាក់ទៀត គឺយ៉ាកុប និងយ៉ូហានប្អូនរបស់គាត់ ពួកគេនៅក្នុងទូកជាមួយឪពុករបស់ពួកគេគឺលោកសេបេដេជា ដែលកំពុងតែរៀបចំ
អួន។ ព្រះអង្គក៏ហៅអ្នកទាំងពីរ។ 22 ហើយអ្នកទាំងពីរក៏ចាកចោលទូក និងឪពុកភ្លាម រួចដើរតាមព្រះអង្គទៅ។ 23 ព្រះយេស៊ូយាងកាត់ពេញស្រុកកាលីឡេ
ទាំងមូល ទ្រង់បង្រៀនក្នុងគ្រប់សាលាប្រជុំ ប្រកាសដំណឹងល្អអំពីព្រះរាជ្យនៃព្រះជាម្ចាស់ ហើយប្រោសជំងឺគ្រប់យ៉ាង និងអ្នកជំងឺគ្រប់ប្រភេទ ក្នុងចំណោម
ប្រជាជនឲ្យបានជាសះស្បើយ។ 24 ដំណឹងនេះក៏ល្បីឮពាសពេញស្រុកស៊ីរីទាំងមូល ហើយគេបាននាំអស់អ្នកជំងឺគ្រប់ប្រភេទដែលមានជំងឺផ្សេងគ្នាៗ អ្នក
អារក្សចូល មនុស្សឆ្កួតជ្រូក និងមនុស្សស្លាប់ដៃស្លាប់ជើង មករកព្រះអង្គ។ ព្រះអង្គក៏ប្រោសបានពួកគេឲ្យបានជាសះស្បើយទាំងអស់។ 25 មានមហាជនជា
ច្រើននាំគ្នាដើរតាមព្រះអង្គ ចាប់ពីស្រុកកាលីឡេ ស្រុកដេកាប៉ូល ក្រុងយេរូសាឡឹម ស្រុកយូដា និងពីតំបន់ខាងនាយទន្លេយ័រដាន់។


generated on Thu Feb 8 15:37:30 2024

## ជំពូក 5

1 ពេលព្រះយេស៊ូឃើញមហាជនទាំងនេះ ព្រះអង្គយាងឡើងទៅលើភ្នំ ហើយគង់នៅទីនោះ ពួកសិស្សនាំគ្នាចូលមកគាល់ព្រះអង្គ 2 ទ្រង់បង្រៀនពួកគេ
ដោយមានព្រះបន្ទូលថា៖ 3 «មានពរហើយអ្នកណាក្រខ្សត់ខាងវិញ្ញាញ ដ្បិតអ្នកនោះនឹងបានទទួលព្រះរាជ្យនៃស្ថានបរមសុខ។ 4 មានពរហើយអ្នកណាដែល
សោកសៅ ដ្បិតព្រះជាម្ចាស់នឹងសម្រាលទុក្ខពួកគេ។ 5 មានពរហើយអ្នកណាមានចិត្តស្លូតបូត ដ្បិតពួកគេនឹងទទួលផែនដីទុកជាមត៌ក។ 6 មានពរហើយអ្នក
ណាស្រេកឃ្លានសេចក្ដីសុចរិត ដ្បិតព្រះជាម្ចាស់នឹងប្រទានឲ្យពួកគេបានឆ្អែត។ 7 មានពរហើយអ្នកណាមានចិត្តមេត្តាករុណា
ដ្បិតគេនឹងទទួលបានក្ដីមេត្តាករុណាត្រឡប់មកវិញ។ 8 មានពរហើយអ្នកណាមានចិត្តបរិសុទ្ធ ដ្បិតគេនឹងឃើញព្រះជាម្ចាស់។ 9 មានពរហើយអ្នកណាកសាង
សន្តិភាព ដ្បិតពួកគេ នឹងមានឈ្មោះជាបុត្ររបស់ព្រះជាម្ចាស់។ 10 មានពរហើយអ្នកណាត្រូវគេបៀតបៀន ព្រោះបានធ្វើតាមសេចក្ដីសុចរិត ដ្បិតពួកគេនឹង
ទទួលបានព្រះរាជ្យនៃស្ថានបរមសុខ។ 11 មានពរហើយអ្នកដែលត្រូវគេត្មះតិះដៀល បៀតបៀន និងមានគេនិយាយអាក្រក់គ្រប់យ៉ាង បង្ខូចឈ្មោះ ព្រោះតែខ្ញុំ។
12 ចូរមានអំណរ និងចិត្តរីករាយឡើង ព្រោះអ្នករាល់គ្នានឹងទទួលរង្វាន់យ៉ាងធំនៅស្ថានបរមសុខ សូម្បីតែពួកព្យាការីដែលរស់នៅមុនអ្នករាល់គ្នា ក៏ត្រូវគេ
បៀតបៀនដែរ។ 13 អ្នកជាអំបិលនៃផែនដី ប៉ុន្តែ បើអំបិលបាត់ជាតិប្រៃហើយ តើគេនឹងយកអ្វីមកធ្វើឲ្យវាប្រៃឡើងវិញបាន? អំបិលនោះគ្មានប្រយោជន៍អ្វីទៀត
ឡើយ មានតែបោះចោលឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ។ 14 អ្នកជាពន្លឺ សម្រាប់បំភ្លឺពិភពលោក។ ទោះក្រុងនៅលើភ្នំក៏មិនអាចលាក់បំបាំងបានឡើយ។ 15
គ្មានអ្នកណាអុជចង្កៀងហើយ យកទៅដាក់ក្រោមល្អីលើនោះទេ គឺគេយកចង្កៀងនោះទៅដាក់លើជើងចង្កៀងវិញ ហើយចង្កៀងនោះនឹងបំភ្លឺមនុស្សនៅក្នុងផ្ទះ។
16 ចូរឲ្យពន្លឺរបស់អ្នក បំភ្លឺដល់មនុស្សដូច្នោះដែរ គេនឹងឃើញអំពើល្អ ដែលអ្នកប្រព្រឹត្ត ហើយសរសើរតម្កើងដល់ព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថាន
បរមសុខ។ 17 កុំគិតថាខ្ញុំមកដើម្បីលុបបំបាត់គម្ពីរវិន័យ ឬគម្ពីរព្យាការីចោលឡើយ។ ខ្ញុំមិនមែនមកលុបបំបាត់ទេ ប៉ុន្តែខ្ញុំមកដើម្បីធ្វើឲ្យគម្ពីរនោះបានសម្រេច
ពេញលក្ខណៈទៅវិញទេ។ 18 ខ្ញុំប្រាប់អ្នករាល់គ្នាឲ្យបានដឹងច្បាស់ថា បើផ្ទៃមេឃ និងផែនដីនៅតែស្ថិតស្ថេរជាដរាប នោះគ្មានក្បៀស ឬបន្តក់ណាមួយក្នុងគម្ពីរ
វិន័យត្រូវរលុបចោលឡើយ គឺរហូតដល់ការទាំងនេះបានសម្រេចសព្វគ្រប់។ 19 អ្នកណាល្មើសបទបញ្ជាតូចបំផុតណាមួយ ហើយបង្រៀនអ្នកផ្សេងទៀតឲ្យធ្វើ
តាម អ្នកនោះនឹងមានឋានៈតូចបំផុតជាងគេ ក្នុងព្រះរាជ្យនៃស្ថានបរមសុខ។ ប៉ុន្តែ អ្នកណាប្រព្រឹត្តតាមបទបញ្ជាទាំងនេះ ហើយបង្រៀនអ្នកផ្សេង
ទៀតឲ្យធ្វើតាម អ្នកនោះនឹងមានឋានៈធំក្នុងព្រះរាជ្យនៃស្ថានបរមសុខ។ 20 ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា បើសេចក្ដីសុចរិតរបស់អ្នករាល់គ្នាមិនលើសសេចក្ដីសុចរិត
របស់ពួកអាចារ្យ និងពួកខាងគណៈផារីស៊ីទេនោះ អ្នករាល់គ្នាគ្មានផ្លូវអាចចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខបានឡើយ។ 21 អ្នកធ្លាប់ឮសេចក្ដីដែល
បាននិយាយពីជំនាន់ដើមថា៖ «កុំសម្លាប់មនុស្ស» ហើយ «អ្នកណាសម្លាប់មនុស្ស អ្នកនោះនឹងត្រូវគេផ្ដន្ទាទោសវិញ»។ 22 ប៉ុន្តែ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្នក
ណាខឹងបងប្អូនខ្លួន អ្នកនោះនឹងត្រូវគេផ្ដន្ទាទោសដែរ។ ហើយអ្នកណាជេរបងប្អូនថាជាមនុស្សឥតប្រយោជន៍ អ្នកនោះនឹងត្រូវក្រុមប្រឹក្សាជាន់ខ្ពស់កាត់ទោស
ហើយអ្នកណាជេរគេថាមនុស្សឆ្កួត អ្នកនោះនឹងត្រូវផ្ដន្ទាទោសធ្លាក់ក្នុងភ្លើងនរកអវិចី។ 23 ដូច្នេះ ប្រសិនបើអ្នកយកតង្វាយមកថ្វាយលើអាសនា ហើយ
ស្រាប់តែនឹកឃើញថាអ្នកមានទំនាស់ជាមួយបងប្អូនណាមួយ 24 អ្នកត្រូវទុកតង្វាយរបស់អ្នក នៅលើអាសនាសិន ហើយទៅស្រុះស្រួលនឹងបងប្អូនរបស់អ្នកជា
មុន រួចសូមវិលមកថ្វាយតង្វាយរបស់អ្នកវិញ។ 25 ត្រូវស្រុះស្រួលជាមួយគូវិវាទរបស់អ្នកសិន ពេលអ្នកធ្វើដំណើរទៅតុលាការជាមួយគ្នា ក្រែងលោគេបញ្ជូន
អ្នកទៅចៅក្រម ហើយចៅក្រមបញ្ជូនអ្នកទៅនគរបាល ហើយអ្នកត្រូវជាប់គុក។ 26 ខ្ញុំសុំប្រាប់ឲ្យអ្នកដឹងថា បើអ្នកមិនបង់ប្រាក់ពិន័យគ្រប់ចំនួនឥតខ្វះមួយ
កាក់នោះទេ អ្នកនឹងមិនអាចរួចខ្លួនបានឡើយ»។ 27 អ្នកធ្លាប់ឮសេចក្ដីថ្លែងទុកមកថា «កុំប្រព្រឹត្តអំពើផិតក្បត់»។ 28 ប៉ុន្តែខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្នក
ណាមើលស្ត្រីម្នាក់ ហើយមានចិត្តស្រើបស្រាលជាមួយនាង អ្នកនោះដូចជាបានប្រព្រឹត្តអំពើផិតក្បត់នៅក្នុងចិត្ត រួចស្រេចទៅហើយ។ 29 ប្រសិនបើភ្នែកស្ដាំអ្នក
នាំអ្នកឲ្យជំពប់ដួល ចូរខ្វេះវាចេញ ហើយបោះចោលឲ្យឆ្ងាយពីអ្នកទៅ ដ្បិតបើបាត់ភ្នែកម្ខាងនោះនឹងប្រសើរជាងឲ្យរូបកាយទាំងមូលធ្លាក់ទៅក្នុងនរក។ 30
ប្រសិនបើដៃស្ដាំអ្នក នាំអ្នកឲ្យជំពប់ដួល ចូរកាត់វា ហើយបោះចោលឲ្យឆ្ងាយពីអ្នកទៅ ដ្បិតបើបាត់អវយវៈមួយនេះ ប្រសើរជាងបណ្ដោយឲ្យរូបកាយទាំងមូល
ធ្លាក់ទៅក្នុងនរក»។ 31 មានសេចក្ដីចែងទុកមកថា «អ្នកណាលែងភរិយាខ្លួន ត្រូវធ្វើលិខិតលែងលះឲ្យនាង»។ 32 រីឯខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្នកណា
លែងភរិយារបស់ខ្លួន (លើកលែងតែអ្នកទាំងពីររស់នៅជាមួយគ្នា ដោយឥតបានរៀបការ) អ្នកនោះធ្វើឲ្យនាងទៅជាស្ត្រីផិតក្បត់ ប្រសិនបើនាងរៀបការម្ដង
ទៀត។ រីឯបុរសណាមករៀបការជាមួយនឹងស្ត្រីដែលប្ដីលែងនោះ អ្នកនោះក៏ប្រព្រឹត្តអំពើផិតក្បត់ដែរ»។ 33 អ្នករាល់គ្នាធ្លាប់ឮសេចក្ដីដែលមានចែងទុកមកថា
«កុំក្បត់ពាក្យសម្បថឡើយ ត្រូវធ្វើតាមគ្រប់ពាក្យដែលអ្នកបានស្បថនឹងព្រះអម្ចាស់»។ 34 រីឯខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា កុំស្បថឲ្យសោះ កុំយកមេឃមក
ស្បថឡើយ ព្រោះមេឃជាបល្ល័ង្ករបស់ព្រះជាម្ចាស់ 35 ក៏កុំយកផែនដីមកស្បថដែរ ព្រោះផែនដីជាកំណល់កល់ព្រះបាទារបស់ព្រះអង្គ។ កុំយក
ក្រុងយេរូសាឡឹមមកស្បថឡើយ ព្រោះយេរូសាឡឹមជាក្រុងរបស់ព្រះមហាក្សត្រដ៏ឧត្ដុង្គឧត្ដម។ 36 ក៏កុំស្បថដោយយកក្បាលអ្នកមកដាក់ឡើយ ព្រោះអ្នកពុំ
អាចធ្វើឲ្យសក់ទៅជាស ឬខ្មៅបានឡើយ។ 37 ប៉ុន្តែត្រូវនិយាយឲ្យប្រាកដ បើ «មែន» ត្រូវនិយាយថា «មែន» បើ «ទេ» ត្រូវនិយាយថា «ទេ»។ រីឯពាក្យពន្លើស
សុទ្ធតែមកពីមារទាំងអស់»។ 38 អ្នកធ្លាប់បានឮសេចក្ដីចែងទុកមកថា «ភ្នែកទល់និងភ្នែក ធ្មេញទល់នឹងធ្មេញ»។ 39 រីឯខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា កុំតប
តនឹងមនុស្សអាក្រក់សោះឡើយ បើគេទះកំផ្លៀងស្ដាំរបស់អ្នក ត្រូវបែរឲ្យគេទះម្ខាងទៀតទៅ។ 40 បើមានគេប្ដឹងចង់យកអាវក្នុងអ្នក ចូរឲ្យគេយកអាវធំថែម
ទៀតទៅ។ 41 បើមានគេបង្ខំអ្នកឲ្យធ្វើដំណើរមួយគីឡូដី ចូរដើរពីរគីឡូដីជាមួយគេចុះ។ 42 អ្វីដែលគេសុំពីអ្នក ចូរឲ្យគេទៅ ហើយកុំគេចមុខចេញពីអ្នក
ដែលចង់សុំខ្ចីពីអ្នកដែរឡើយ។ 43 អ្នករាល់គ្នាធ្លាប់បានឮសេចក្ដីចែងទុកមកថា «ត្រូវស្រឡាញ់បងប្អូន តែត្រូវស្អប់ខ្មាំងសត្រូវរបស់អ្នក»។ 44 រីឯខ្ញុំវិញ ខ្ញុំសុំ
ប្រាប់អ្នករាល់គ្នាថា ត្រូវស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក ព្រមទាំងអធិស្ឋានឲ្យអ្នកដែលបៀតបៀនដល់អ្នករាល់គ្នាផង។ 45 ដូច្នោះ ទើបអ្នកសមជាបុត្ររបស់
ព្រះបិតា ដែលគង់នៅស្ថានបរមសុខ ដ្បិតព្រះអង្គឲ្យព្រះអាទិត្យរបស់ព្រះអង្គរះបំភ្លឺ ទាំងមនុស្សអាក្រក់ ទាំងមនុស្សល្អ ហើយទ្រង់ឲ្យទឹកភ្លៀងធ្លាក់មកលើទាំង
មនុស្សសុចរិត ទាំងមនុស្សទុច្ចរិតផងដែរ។ 46 ដ្បិត បើអ្នករាល់គ្នាស្រឡាញ់តែអស់អ្នកណាដែលស្រឡាញ់ដល់អ្នក តើអ្នកនឹងទទួលបានរង្វាន់អ្វី? តើអ្នកទារ
ពន្ធពួកគេមិនបានប្រព្រឹត្តដូច្នេះទេឬអី? 47 បើអ្នករាល់គ្នារាប់អានតែបងប្អូនខ្លួន តើមានអ្វីល្អជាងគេ? តើសាសន៍ដទៃមិនប្រព្រឹត្តដូច្នោះដែរឬ?។ 48 ដូច្នេះសុំឲ្យ
អ្នករាល់គ្នាបានគ្រប់លក្ខណ៍ ដូចព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខ ដែលព្រះអង្គគ្រប់លក្ខណ៍យ៉ាងនោះដែរ»។


generated on Thu Feb 8 15:37:30 2024

## ជំពូក 6

1 ចូរប្រុងប្រយ័ត្ន កុំធ្វើទាននៅមុខមនុស្សម្នា ដើម្បីឲ្យតែមនុស្សឃើញនោះឡើយ។ ការធ្វើបែបនេះអ្នករាល់គ្នានឹងមិនបានរង្វាន់ពីព្រះបិតា ដែលគង់នៅស្ថាន
បរមសុខនោះទេ។ 2 ដូច្នេះពេលណាអ្នកឲ្យទានដល់គេ កុំស្រែកប្រកាសឲ្យគេដឹង ដូចជាពួកមានពុតដែលតែងតែធ្វើនៅសាលាប្រជុំ ឬនៅតាមដងផ្លូវ ដើម្បី
ឲ្យមនុស្សលោកកោតសរសើរនោះឡើយ។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យដឹងប្រាកដថា អ្នកទាំងនោះបានទទួលរង្វាន់របស់គេហើយ។ 3 ប៉ុន្តែ កាលណាដៃស្តាំអ្នកធ្វើ
ទាន នោះកុំឲ្យដៃឆ្វេងដឹងថាដៃស្តាំធ្វើទាននោះឡើយ 4 ដើម្បីឲ្យទានរបស់អ្នកនៅទីស្ងាត់កំបាំង នោះព្រះបិតារបស់អ្នក ដែលទតឃើញពីទីស្ងាត់កំបាំង ទ្រង់នឹង
ប្រទានរង្វាន់មកអ្នករាល់គ្នាជាមិនខាន។ 5 ពេលណាអ្នករាល់គ្នាអធិស្ឋាន កុំធ្វើដូចមនុស្សមានពុត ដែលចូលចិត្តឈរអធិស្ឋាន ក្នុងសាលាប្រជុំ និងនៅត្រង់
ថ្នល់កែង ដើម្បីឲ្យមនុស្សឃើញនោះឡើយ។ ខ្ញុំសុំប្រាប់ឲ្យដឹងប្រាកដថាពួកអ្នកទាំងនោះបាន ទទួលរង្វាន់របស់គេហើយ។ 6 ប៉ុន្តែកាលណាអ្នករាល់គ្នាអធិស្ឋាន
ត្រូវចូលទៅក្នុងបន្ទប់ បិទទ្វារឲ្យជិត ហើយអធិស្ឋានទៅកាន់ព្រះបិតារបស់អ្នកដែលគង់នៅក្នុងទីស្ងាត់កំបាំង។ ព្រះបិតាដែលទតឃើញពីទីស្ងាត់កំបាំងមក
ព្រះអង្គនឹងប្រទានរង្វាន់មកអ្នករាល់គ្នាជាពុំខាន។ 7 ពេលអ្នកអធិស្ឋាន កុំពោលពាក្យច្រំដែលៗ ដូចសាសន៍ដទៃនោះឡើយ។ ព្រោះគេនឹកស្មានថា បើពោល
ពាក្យយ៉ាងច្រើនដូច្នេះ ព្រះជាម្ចាស់នឹងសណ្តាប់ពាក្យអធិស្ឋានរបស់គេ។ 8 ដូច្នេះ កុំធ្វើដូចពួកគេឡើយ ដ្បិតព្រះបិតារបស់អ្នករាល់គ្នាព្រះអង្គជ្រាបពីអ្វីៗ ដែល
អ្នករាល់គ្នាត្រូវការ មុនអ្នករាល់គ្នាទូលសូមព្រះអង្គទៅទៀត។ 9 ដូច្នេះត្រូវអធិស្ថានបែបដូច្នេះ ឱព្រះបិតានៃយើងខ្ញុំដែលគង់នៅស្ថានបរមសុខអើយ!
សូមឲ្យមនុស្សលោកស្គាល់ព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គ។ 10 សូមឲ្យព្រះរាជ្យរបស់ព្រះអង្គបានមកដល់ សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ បានសម្រេចនៅលើ
ផែនដីដូចជានៅស្ថានបរមសុខដែរ។ 11 សូមប្រទានអាហារដល់យើងខ្ញុំនៅថ្ងៃនេះ។ 12 សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំបានអត់ទោសឲ្យគេដែរ។ 13
សូមកុំឲ្យយើងខ្ញុំចាញ់ការល្បួងឡើយ តែសូមរំដោះយើងខ្ញុំឲ្យរួចពីមារកំណាចវិញ។ 14 បើអ្នកអត់ទោសឲ្យគេ ព្រះបិតារបស់អ្នកដែលគង់នៅស្ថានបរមសុខ ក៏
អត់ទោសឲ្យអ្នកដែរ។ 15 ប៉ុន្តែ បើអ្នកមិនអត់ទោសឲ្យគេទេនោះ ព្រះបិតារបស់អ្នកក៏មិនអត់ទោសឲ្យអ្នកដែរ»។ 16 ជាងនេះទៅទៀត ពេលណាអ្នកតមអាហារ
កុំធ្វើមុខក្រៀមដូចអ្នកមានពុតនោះឡើយ។ ពីព្រោះពួកគេបង្ហាញទឹកមុខដើម្បីឲ្យអ្នកដទៃឃើញថា គេតមអាហារ។ ខ្ញុំសុំប្រាប់ឲ្យអ្នកដឹងប្រាកដថា អ្នកទាំងនោះ
បានទទួលរង្វាន់របស់គេហើយ។ 17 ប៉ុន្តែរីឯអ្នករាល់គ្នាវិញ ពេលណាអ្នកតមអាហារ ត្រូវលាបប្រេងនៅលើក្បាល ហើយលុបមុខផង 18 ធ្វើដូចនេះកុំឲ្យគេ
ឃើញថាអ្នកតមអាហារឡើយ គឺឲ្យតែព្រះបិតារបស់អ្នក ដែលគង់ក្នុងទីស្ងាត់ឃើញប៉ុណ្ណោះ ហើយព្រះបិតារបស់អ្នកដែលទតឃើញនៅក្នុងទីស្ងាត់ នឹងប្រទាន
រង្វាន់ឲ្យអ្នកជាមិនខាន។ 19 កុំសន្សំទ្រព្យទុកសម្រាប់ខ្លួន នៅផែនដីដែលជាកន្លែងមានកណ្ដៀរ និងច្រេះស៊ី និងជាកន្លែង ដែលចោរអាចទម្លាយជញ្ជាំងចូលមក
លួចប្លន់នោះឡើយ។ 20 ផ្ទុយទៅវិញ ត្រូវប្រមូលទ្រព្យទុកនៅស្ថានបរមសុខវិញ ជាកន្លែងគ្មានកណ្ដៀរ និងច្រេះស៊ី និងជាកន្លែងគ្មានចោរចូលមកលួចប្លន់
ឡើយ 21 បើទ្រព្យរបស់អ្នកនៅទីណា ចិត្តរបស់អ្នកក៏នៅទីនោះដែរ។ 22 ភ្នែកជាចង្កៀងនៃរូបកាយ ដូច្នេះបើភ្នែករបស់អ្នកនៅភ្លឺល្អ រូបកាយអ្នកទាំងមូលក៏ភ្លឺល្អ
ដែរ 23 ប៉ុន្តែ បើភ្នែករបស់អ្នកងងឹត នោះរូបកាយអ្នកទាំងមូលក៏ងងឹតដែរ។ បើពន្លឺនៅក្នុងអ្នកត្រឡប់ទៅជាងងឹតទៅហើយ តើសេចក្ដីងងឹតនោះ នឹងទៅជា
សូន្យសុង ដល់កំរិតណាទៅ! 24 គ្មានអ្នកណាអាចបម្រើម្ចាស់ពីរបាននោះទេ ព្រោះអ្នកនោះនឹងស្អប់មួយ ស្រឡាញ់មួយ ស្មោះត្រង់នឹងម្នាក់ ហើយមើលងាយ
ម្នាក់ទៀត អ្នករាល់គ្នាក៏មិនអាចបម្រើព្រះជាម្ចាស់ផង ហើយនិងបម្រើទ្រព្យសម្បត្តិផងបាននោះឡើយ។ 25 ដូច្នេះ បានជាខ្ញុំប្រាប់អ្នករាល់គ្នាថា កុំខ្វល់ខ្វាយ
នឹងជីវិត ថាត្រូវបរិភោគអាហារអ្វី ឬសម្លៀកបំពាក់សម្រាប់បិទបាំងរូបកាយឡើយ។ តើជីវិតមិនមានតម្លៃលើសម្ហូបអាហារ ហើយរូបកាយក៏មានតម្លៃលើស
សម្លៀកបំពាក់ដែរឬអី? 26 ចូរមើលបក្សាបក្សីនៅលើមេឃ។ វាមិនសាបព្រោះ មិនច្រូតកាត់ និងមិនប្រមូលផលដាក់ជង្រុកឡើយ ប៉ុន្តែ ព្រះបិតារបស់អ្នកដែល
គង់នៅស្ថានបរមសុខ ទ្រង់ចិញ្ចឹមវា។ តើអ្នករាល់គ្នា មិនមានតម្លៃលើសបក្សាបក្សីទាំងនោះទេឬអី?។ 27 ក្នុងចំណោមអ្នករាល់គ្នា ទោះបីខំប្រឹងខ្វល់ខ្វាយ
តើអាចបង្កើនអាយុរបស់ខ្លួនអោយវែងបានដែរទេ? 28 ហេតុអ្វីបានជាអ្នកខ្វល់ខ្វាយអំពីសម្លៀកបំពាក់ដូច្នេះ? ចូរមើលទៅផ្កានៅតាមទីវាល វាដុះឡើងយ៉ាង
ណា។ វាមិនបានធ្វើការនឿយហត់ ឬត្បាញរវៃឡើយ។ 29 ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា សូម្បីតែសាឡូម៉ូនមានគ្រប់ទាំងសិរីរុងរឿងព្រះអង្គ ក៏មិនល្អស្មើនឹងផ្កាមួយ
ទងនេះផង។ 30 ប្រសិនបើព្រះជាម្ចាស់ផ្តល់សម្រស់ឲ្យស្មៅនៅតាមទីវាល រស់នៅថ្ងៃនេះហើយថ្ងៃស្អែកត្រូវគេដុតចោលយ៉ាងហ្នឹងទៅហើយ តើព្រះអង្គ
នឹងផ្គត់ផ្គង់ឲ្យអ្នករាល់គ្នាលើសពីនេះ យ៉ាងណាទៅទៀត?។ 31 ដូច្នេះ ចូរកុំខ្វល់ខ្វាយដោយពោលពាក្យថា យើងនឹងបានអ្វីបរិភោគ និងមានអ្វីស្លៀក
ពាក់ឡើយ? 32 ដ្បិត មានតែសាសន៍ដទៃទេ ដែលខំស្វះស្វែងរករបស់ទាំងនោះ។ ចំណែកឯព្រះបិតារបស់អ្នកដែលគង់នៅស្ថានបរមសុខ ព្រះអង្គជ្រាបនូវអ្វីៗ
ដែលអ្នកត្រូវការហើយ។ 33 ប៉ុន្តែត្រូវស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និងសេចក្តីសុចរិតរបស់ព្រះអង្គជាមុនសិន ទើបព្រះអង្គប្រទានរបស់ទាំងនោះឲ្យអ្នក
រាល់គ្នាថែមទៀតផង។ 34 ចូរកុំខ្វល់ខ្វាយអំពីថ្ងៃស្អែកឡើយ ចាំស្អែកសឹមគិតពីរឿងថ្ងៃស្អែកទៅ! ការលំបាកនៅថ្ងៃណា គឺល្មមគ្រប់គ្រាន់នៅថ្ងៃនោះហើយ។

 generated on Thu Feb 8 15:37:30 2024

## ជំពូក 7

1 មិនត្រូវថ្កោលទោសគេឡើយ ដើម្បីកុំឲ្យគេថ្កោលទោសអ្នករាល់គ្នាវិញដែរ។ 2 ដ្បិត បើអ្នករាល់គ្នាថ្កោលទោសគេយ៉ាងណា នោះគេក៏នឹងថ្កោលទោសអ្នក
រាល់គ្នាយ៉ាងនោះដែរ។ ហើយគេនឹងវាល់ឲ្យអ្នករាល់គ្នា តាមរង្វាល់ដែលអ្នករាល់គ្នាវាល់ឲ្យអ្នកដទៃដែរ។ 3 ហេតុអ្វីបានជាអ្នកមើលឃើញកំទេចធូលីនៅក្នុងភ្នែក
បងប្អូនរបស់អ្នក ប៉ុន្តែមិនមើលធ្នឹមដែលនៅក្នុងភ្នែករបស់អ្នកដូច្នេះ? 4 ម្ដេចក៏អ្នកនិយាយទៅកាន់បងប្អូនអ្នកថា
ឲ្យខ្ញុំយកកំទេចធូលីនៅក្នុងភ្នែករបស់ឯងចេញទៅ តែក្នុងភ្នែកខ្លួនឯងនៅមានធ្នឹមដូច្នេះ? 5 មនុស្សមានពុតអើយ! ត្រូវយកធ្នឹមចេញពីភ្នែកខ្លួនជាមុនសិន ទើប
អ្នកមើលឃើញច្បាស់ ដើម្បីនឹងផ្ដិតយកកំទេចធូលីចេញពីភ្នែករបស់បងប្អូនរបស់អ្នកបាន។ 6 កុំយករបស់ដែលវិសុទ្ធ ទៅឲ្យសត្វឆ្កែឡើយ ហើយក៏កុំបោះត្បូង
គុជររបស់អ្នកនៅមុខសត្វជ្រូកដែរ ក្រែងលោវាជាន់ឈ្លី ហើយបែរមកហែកខាំអ្នករាល់គ្នាជាដុំៗវិញ។ 7 ចូរសុំ នោះអ្នកនឹងបានទទួល ចូរស្វែងរក នោះអ្នកនឹង
បានឃើញ ចូរគោះ នោះទ្វារនឹងបើកឲ្យអ្នកជាពុំខាន។ 8 ព្រោះអ្នកណាសុំ អ្នកនោះនឹងបានទទួល អ្នកណាស្វែងរក អ្នកនោះនឹងបានឃើញ ហើយអ្នកណាគោះ
ទ្វារនឹងបើកឲ្យអ្នកនោះ។ 9 ក្នុងចំណោមអ្នករាល់គ្នា ប្រសិនកូនសុំនំប៉័ងតើអ្នកនឹងដុំថ្មទៅវាឬអី? 10 ហើយប្រសិនបើកូនសុំត្រី តើអ្នកនឹងឲ្យពស់អសិរពិស
ទៅវាឬអី? 11 បើអ្នករាល់គ្នាដែលជាមនុស្សអាក្រក់ ក៏ចេះឲ្យរបស់ល្អទៅកូនដូច្នេះ ចុះចំណង់បើព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខ តើព្រះអង្គ
នឹងឲ្យរបស់ល្អៗដល់អស់អ្នកដែលទូលសូមពីព្រះអង្គ យ៉ាងណាទៅទៀត? 12 ដូច្នេះ បើអ្នកចង់ឲ្យគេប្រព្រឹត្តចំពោះខ្លួនបែបណា អ្នកត្រូវប្រព្រឹត្តចំពោះគេបែប
នោះដែរ ដ្បិតនេះជាក្រឹត្យវិន័យ និងគម្ពីរព្យាការីមានចែងទុកមកស្រាប់។ 13 ចូរនាំគ្នាចូលតាមទ្វារចង្អៀតចុះ ដ្បិតទ្វារធំទូលាយនាំទៅរកសេចក្តីវិនាសអន្តរាយ
ហើយមានមនុស្សច្រើនណាស់ចូលតាមទ្វារនោះ។ 14 រីឯទ្វារចង្អៀត និងផ្លូវពិបាកវិញនាំទៅរកជីវិត មានមនុស្សតិចណាស់រកផ្លូវនោះឃើញ។ 15 ចូរប្រយ័ត្ន
នឹងពួកព្យាការីក្លែងក្លាយ គេមករកអ្នករាល់គ្នា ដោយពាក់ស្បែកចៀម តែចិត្តរបស់គេវិញសាហាវដូចឆ្កែចចកអ៊ីចឹង។ 16 អ្នករាល់គ្នានឹងស្គាល់គេ តាម
ផលផ្លែដែលគេបានធ្វើ។ តើដែលមានមនុស្សណាបេះផ្លែទំពាំងបាយជូរ ពីគុម្ពបន្លា ឬផ្លែឧទុម្ពរ ពីដើមដំបងយក្សឬទេ? 17 ដូច្នេះ ដើមឈើល្អតែងតែផ្ដល់ផ្លែល្អ
រីឯដើមឈើអាក្រក់ តែងតែផ្ដល់ផ្លែអាក្រក់ដែរ។ 18 ដើមឈើល្អមិនអាចផ្ដល់ផ្លែអាក្រក់នោះទេ រីឯដើមឈើអាក្រក់វិញក៏មិនអាចផ្ដល់ផ្លែល្អបានដែរ។ 19 ដើម
ឈើណាមិនផ្ដល់ផ្លែល្អ នឹងត្រូវកាប់ចោល ហើយយកទៅដុតក្នុងភ្លើង។ 20 ដូច្នេះ អ្នករាល់គ្នានឹងស្គាល់អ្នកទាំងនោះបានដោយសារអំពើដែលគេប្រព្រឹត្តដែរ។
21 មិនមែនអ្នកដែលគ្រាន់តែហៅខ្ញុំថា «ព្រះអម្ចាស់! ព្រះអម្ចាស់!» នឹងអាចចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខបាននោះឡើយ ប៉ុន្តែមានតែអ្នកដែលធ្វើតាម
ព្រះហឫទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់នៅស្ថានបរមសុខប៉ុណ្ណោះទើបអាចចូលបាន។ 22 មានមនុស្សជាច្រើននឹងពោលមកខ្ញុំនៅថ្ងៃនោះថា «ព្រះអម្ចាស់
ព្រះអម្ចាស់អើយ! តើយើងខ្ញុំមិនធ្លាប់បានថ្លែងទំនាយ ដេញអារក្ស ហើយនិងធ្វើការអស្ចារ្យជាច្រើនក្នុងនាមព្រះអង្គដែរទេឬអី?”។ 23 នៅពេលនោះ ខ្ញុំនឹង
ប្រកាសប្រាប់គេថា យើងមិនដែលស្គាល់អ្នករាល់គ្នាទេ ចូរថយចេញឲ្យឆ្ងាយពីយើងទៅ «ពួកអ្នកប្រព្រឹត្តអំពើទុច្ចរិតអើយ!» ។ 24 ដូច្នេះអ្នកណាដែលឮពាក្យខ្ញុំ
ហើយប្រព្រឹត្តតាម អ្នកនោះប្រៀបបានទៅនឹងមនុស្សឈ្លាសវៃ ដែលបានសង់ផ្ទះរបស់ខ្លួននៅលើថ្មដា។ 25 ទោះបីមានភ្លៀងធ្លាក់ចុះមក ហើយមានទឹកជន់
មានខ្យល់បក់ប៉ះផ្ទះនោះខ្លាំងយ៉ាងណាក៏ដោយ ក៏ផ្ទះនោះមិនរលំដែរ ព្រោះវាបានចាក់គ្រឹះនៅលើថ្មដា។ 26 អស់អ្នកណាដែលឮពាក្យខ្ញុំហើយ តែមិនប្រព្រឹត្ត
តាម អ្នកនោះប្រៀបបានទៅនឹងមនុស្សល្ងង់ ដែលបានសង់ផ្ទះរបស់ខ្លួននៅលើដីខ្សាច់។ 27 ពេលមានភ្លៀងធ្លាក់ចុះមក ហើយមានទឹកជន់ មានខ្យល់បក់ប៉ះផ្ទះ
នោះ ផ្ទះនោះរលំបាក់បែកខ្ទេចអស់គ្មានសល់ទេ។ 28 កាលព្រះយេស៊ូមានព្រះបន្ទូលពីសេចក្តីទាំងនេះ ចប់សព្វគ្រប់ហើយ មហាជនមានការងឿងឆ្ងល់យ៉ាង
ខ្លាំងអំពីសេចក្តីដែលព្រះអង្គបង្រៀន។ 29 ពីព្រោះព្រះអង្គបង្រៀនដល់ពួកគេប្រកបដោយអំណាច ខុសប្លែកពីពួកអាចារ្យដែលបានបង្រៀន។


generated on Thu Feb 8 15:37:30 2024

## ជំពូក 8

1 កាលព្រះយេស៊ូយាងចុះពីលើភ្នំមក មានមហាជនជាច្រើននាំគ្នាដើរតាមព្រះអង្គ។ 2 ពេលនោះ មានមនុស្សឃ្លង់ម្នាក់ចូលមកក្រាបថ្វាយបង្គំព្រះអង្គដោយ
ទូលថា៖ «ព្រះអម្ចាស់អើយ! ប្រសិនបើព្រះអង្គសព្វព្រះហឫទ័យ សូមប្រោសទូលបង្គំឲ្យជាស្អាតផង។ 3 ព្រះយេស៊ូលូកព្រះហស្តទៅពាល់គាត់ ហើយមាន
ព្រះបន្ទូលថា៖ «យើងសព្វព្រះហឫទ័យ ចូរឲ្យបានជាស្អាតចុះ។ ភ្លាមនោះ គាត់ក៏បានជាស្អាតពីរោគឃ្លង់។ 4 ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «កុំនិយាយ
ប្រាប់ឲ្យនរណាដឹងពីការនេះឡើយ តែត្រូវទៅបង្ហាញខ្លួនដល់ពួកបូជាចារ្យ ហើយថ្វាយតង្វាយដូចដែលលោកម៉ូសេបានបង្គាប់ចុះ ដើម្បីជាសក្ខីភាពបញ្ជាក់ថា
អ្នកពិតជាបានជាប្រាកដមែន។ 5 កាល ព្រះយេស៊ូបានយាងចូលក្រុងកាពើណិម នោះមានមេទ័ពម្នាក់ ចូលមកគាល់ព្រះអង្គទាំងទូលអង្វរថា៖ 6 «ព្រះអម្ចាស់
អើយ! អ្នកបម្រើរបស់ទូលបង្គំដេកស្ដូកស្ដឹងនៅឯផ្ទះ ទាំងមានការឈឺចាប់យ៉ាងខ្លាំង។ 7 ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំនឹងទៅប្រោសគាត់ឲ្យបាន
ជា»។ 8 មេទ័ពនោះទូលព្រះអង្គថា៖ «ព្រះអម្ចាស់ហើយ ទូលបង្គំ មិនសក្ដិសម ឲ្យព្រះអង្គអញ្ជើញចូលក្នុងផ្ទះទូលបង្គំទេ សូមទ្រង់គ្រាន់តែមានព្រះបន្ទូល
ប៉ុណ្ណោះ អ្នកបម្រើរបស់ទូលបង្គំនឹងជាសះស្បើយមិនខាន។ 9 ទូលបង្គំជាអ្នកនៅក្រោមបញ្ជាគេ ហើយក៏មានកូនទាហាននៅក្រោមបញ្ជាទូលបង្គំដែរ បើ
ទូលបង្គំបញ្ជាអ្នកណាម្នាក់ឲ្យទៅ គេនឹងទៅ បើប្រាប់ម្នាក់ទៀតឲ្យមក គេនឹងមក។ ពេលទូលបង្គំប្រាប់អ្នកបម្រើឲ្យធ្វើអ្វីមួយ គេនឹងធ្វើតាម»។ 10 ពេល
ព្រះយេស៊ូព្រះសណ្ដាប់ឮដូច្នេះ ទ្រង់ស្ងើចសរសើរ ហើយក៏មានព្រះបន្ទូលទៅកាន់អស់អ្នកដែលដើរតាមព្រះអង្គថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា ខ្ញុំ
មិនដែលឃើញនរណាមានជំនឿបែបនេះ នៅស្រុកអ៊ីស្រាអែលឡើយ។ 11 ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា នឹងមានមនុស្សជាច្រើន មកពីទិសខាងកើត និងទិសខាង
លិច មកអង្គុយជាមួយលោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុបក្នុងព្រះរាជ្យនៃស្ថានបរមសុខ។ 12 ប៉ុន្តែកូនប្រុសៗរបស់ព្រះរាជ្យនោះ នឹងត្រូវបោះចេញ
ទៅក្នុងទីងងឹត ជាកន្លែងដែលមានការយំសោក ខឹងសង្កៀតធ្មេញ។ 13 ព្រះយេស៊ូមានព្រះបន្ទូលទៅមេទ័ពរ៉ូម៉ាំងថា៖ «អញ្ជើញទៅវិញទៅចុះ សុំឲ្យបាន
សម្រេចតាមពាក្យដែលលោកជឿចុះ!»។ អ្នកបម្រើក៏បានជាសះស្បើយនៅពេលនោះឯង។ 14 ពេលព្រះយេស៊ូយាងទៅផ្ទះលោកពេត្រុស ទ្រង់ទតឃើញម្ដាយ
ក្មេករបស់លោកពេត្រុសកំពុងគ្រុនក្ដៅសម្រាន្តនៅលើគ្រែ។ 15 ព្រះអង្គពាល់ដៃគាត់ ហើយគាត់ក៏បាត់គ្រុន បន្ទាប់មកគាត់ក៏ក្រោកឡើងហើយបម្រើព្រះអង្គ។
16 លុះដល់ល្ងាច គេនាំមនុស្សដែលមានអារក្សចូលជាច្រើននាក់មករកព្រះអង្គ។ ទ្រង់ដេញវិញ្ញាណទាំងនោះដោយមានព្រះបន្ទូល ហើយប្រោសអ្នកជំងឺឲ្យបាន
ជាគ្រប់ៗគ្នា។ 17 ស្របនឹងសេចក្ដីដែលបានចែងទុក តាមរយៈព្យាការីអេសាយថា៖ «ទ្រង់បានទទួលយកអស់ទាំងរោគា និងជំងឺរបស់យើងមកផ្ទុកលើព្រះអង្គ»
។ 18 កាលព្រះយេស៊ូឃើញបណ្ដាជនចោមរោមព្រះអង្គ ទ្រង់ក៏បញ្ជាឲ្យគេចេញទូកទៅត្រើយម្ខាងនៃសមុទ្រកាលីឡេ។ 19 បន្ទាប់មក មានអាចារ្យម្នាក់ចូលមក
ជិតព្រះអង្គទូលថា៖ «លោកគ្រូ! ខ្ញុំនឹងទៅតាមលោក ទោះបីលោកអញ្ជើញទៅទីណាក៏ដោយ»។ 20 ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់វិញថា៖ «សត្វកញ្ជ្រោង
មានរូងរបស់វា បក្សាបក្សីនៅលើមេឃក៏មានសំបុករបស់វាដែរ ប៉ុន្តែរីឯបុត្រមនុស្សវិញ គ្មានទីជម្រកសម្រាប់សម្រាកសោះឡើយ»។ 21 មានសិស្សម្នាក់ទៀត
ទូលព្រះអង្គថា៖ «លោកម្ចាស់ សូមលោកអនុញ្ញាតឲ្យខ្ញុំត្រឡប់ទៅបញ្ចុះសពឪពុករបស់ខ្ញុំសិន»។ 22 ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «សុំមកតាម
ខ្ញុំចុះ ទុកឲ្យមនុស្សស្លាប់បញ្ចុះសពគ្នាគេចុះ»។ 23 ពេលព្រះយេស៊ូយាងចុះទូកហើយ ពួកសិស្សនាំគ្នាទៅជាមួយព្រះអង្គដែរ។ 24 ពេលនោះ មានខ្យល់ព្យុះបក់
បោកមកលើសមុទ្រយ៉ាងខ្លាំង ធ្វើឲ្យរលកជះមកគ្របពីលើទូក។ រីឯព្រះយេស៊ូវិញក៏ផ្ទំលក់។ 25 ពួកសិស្សចូលទៅជិត ហើយដាស់ព្រះអង្គ៖ «សូមជួយ
យើងផងលោកម្ចាស់អើយ យើងស្លាប់ឥឡូវហើយ»។ 26 ព្រះអង្គមានព្រះបន្ទូលទៅពួកគេថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាភិតភ័យដូច្នេះ មនុស្សមានជំនឿតិច
អើយ?»។ បន្ទាប់មកព្រះអង្គក្រោកឡើង ហើយមានព្រះបន្ទូលគំរាមខ្យល់ និងសមុទ្រ ពេលនោះសមុទ្រក៏ស្ងប់ឈឹង។ 27 ពួកគេនាំគ្នាស្ងើចសរសើរ ហើយ
ពោលថា៖ «តើលោកនេះមានឋានៈអ្វី សូម្បីតែខ្យល់ និងសមុទ្រ ក៏ស្ដាប់បង្គាប់លោកដូច្នេះ?។ 28 កាលព្រះយេស៊ូបានទៅដល់ត្រើយម្ខាង ក្នុងតំបន់គេរ៉ាស៊ីន
មានបុរសអារក្សចូលពីរនាក់ជួបព្រះអង្គ ពួកគេចេញពីទីបញ្ចុះសពមក ហើយបុរសទាំងពីរនោះកាចណាស់ គ្មាននរណាហ៊ានដើរកាត់តាមនោះទេ។ 29
បុរសទាំងពីរនោះស្រែកឡើងថា៖ «តើយើងបានធ្វើអីព្រះអង្គ ព្រះបុត្រារបស់ព្រះជាម្ចាស់អើយ? តើព្រះអង្គយាងមកទីនេះ ដើម្បីធ្វើទុក្ខទោសយើងខ្ញុំ មុនពេល
កំណត់ឬ?។ 30 មានជ្រូកមួយហ្វូងធំកំពុងរកស៊ី ដែលនៅឆ្ងាយពីទីនោះបន្តិច។ 31 ពួកអារក្សអង្វរព្រះយេស៊ូថា៖ «បើព្រះអង្គចង់ដេញពួកយើងចេញ សូម
បញ្ជូនពួកយើងឲ្យចូលទៅក្នុងជ្រូកមួយហ្វូងនេះទៅ»។ 32 ព្រះយេស៊ូមានព្រះបន្ទូលទៅអារក្សថា៖ «ទៅចុះ!»។ ពួកអារក្សក៏ចេញពីបុរសទាំងពីរ ហើយចូល
ទៅក្នុងហ្វូងជ្រូកទៅ។ ពេលនោះ ហ្វូងជ្រូកបោលចុះតាមជម្រាលភ្នំតម្រង់ទៅសមុទ្រ ហើយងាប់នៅក្នុងទឹកអស់ទៅ។ 33 ពួកអ្នកថែរក្សាហ្វូងជ្រូករត់ទៅប្រាប់
អ្នករស់នៅក្នុងក្រុង ពីរឿងអស់ទាំងនេះ ព្រមទាំងហេតុការណ៍អំពីបុរសអារក្សចូលទាំងពីរនាក់នោះផង។ 34 អ្នកក្រុងទាំងអស់ក៏នាំគ្នាចេញមកជួបព្រះយេស៊ូ
លុះពេលគេបានឃើញព្រះអង្គហើយ គេអង្វរព្រះអង្គឲ្យចាកចេញពីស្រុកភូមិរបស់ពួកគេទៅ។

## ជំពូក 9

1 ព្រះយេស៊ូយាងចុះទូកឆ្លងសមុទ្រ ទៅក្រុងរបស់ព្រះអង្គវិញ។ 2 មានគេសែងមនុស្សខ្វិនដៃខ្វិនជើងម្នាក់ ដែលដេកលើកន្ទេលមករកព្រះអង្គ។
ដោយយល់ដល់ជំនឿរបស់អ្នកទាំងនោះ ព្រះយេស៊ូក៏មានព្រះបន្ទូលទៅកាន់អ្នកពិការថា៖«កូនអើយ! ចូរត្រេកអរឡើង។
ខ្ញុំបានអត់ទោសកូនឲ្យរួចបាបហើយ»។ 3 ពេលនោះមានពួកអាចារ្យខ្លះ ក៏នឹកក្នុងចិត្តថា៖ «អ្នកនេះកំពុងប្រមាថព្រះជាម្ចាស់!»។ 4 ព្រះយេស៊ូឈ្វេងយល់គំនិត
ពួកគេ ហើយទ្រង់មានព្រះបន្ទូលថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាមានគំនិតអាក្រក់បែបនេះនៅក្នុងចិត្តដូច្នេះ? 5 តើឃ្លាមួយណាស្រួលនិយាយជាង
«ខ្ញុំបានអត់ទោសកូនឲ្យរួចពីបាប» ឬក៏ «ចូរក្រោកឡើងដើរទៅចុះ?» 6 ប៉ុន្តែ អ្នកគួរដឹងថា បុត្រមនុស្សមានអំណាចអត់ទោសអំពើបាបឲ្យមនុស្សនៅក្នុងលោក
នេះបាន។ ព្រះអង្គក៏មានព្រះបន្ទូលទៅអ្នកខ្វិនថា៖ «ក្រោកឡើង! ចូរយកគ្រែស្នែងរបស់អ្នក ហើយដើរទៅផ្ទះវិញទៅ»។ 7 បន្ទាប់អ្នកខ្វិនក៏ក្រោកឡើង
ហើយដើរត្រឡប់ទៅផ្ទះរបស់គាត់វិញ។ 8 កាលមហាជនបានឃើញដូច្នេះ គេស្ញែងខ្លាច ទាំងនាំគ្នាលើកតម្កើងព្រះជាម្ចាស់ ដែលបានប្រទានអំណាចដ៏អស្ចារ្យ
យ៉ាងនេះដល់មនុស្សលោក។ 9 កាលព្រះយេស៊ូយាងពីទីនោះទៅ ព្រះអង្គទតឃើញបុរសម្នាក់ឈ្មោះម៉ាថាយ ដែលកំពុងអង្គុយនៅកន្លែងយកពន្ធ។ ព្រះអង្គ
មានព្រះបន្ទូលទៅគាត់ថា៖ «ចូរមកតាមខ្ញុំចុះ»។ លោកម៉ាថាយក៏ក្រោកឡើង ហើយដើរតាមព្រះអង្គទៅ។ 10 ពេល ព្រះអង្គអង្គុយសោយព្រះស្ងោយនៅក្នុងផ្ទះ
នោះមានអ្នកយកពន្ធជាច្រើន ព្រមទាំងមនុស្សបាបមកអង្គុយរួមតុអាហារជាមួយព្រះយេស៊ូ និងពួកសិស្សរបស់ព្រះអង្គដែរ។ 11 ពេលពួកខាងគណៈផារីស៊ី
ឃើញដូច្នេះ គេក៏និយាយទៅកាន់សិស្សរបស់ព្រះអង្គថា៖ «ហេតុអ្វីបានជាគ្រូរបស់អ្នកបរិភោគជាមួយអ្នកយកពន្ធ និងមនុស្សមានបាបដូច្នេះ?»។ 12
ពេលព្រះយេស៊ូឮដូច្នេះ ព្រះអង្គក៏មានព្រះបន្ទូលថា៖ «មនុស្សមានសុខភាពល្អមិនត្រូវការគ្រូពេទ្យទេ មានតែអ្នកជំងឺប៉ុណ្ណោះដែលត្រូវការគ្រូពេទ្យ។ 13 អ្នក
រាល់គ្នាគួររិះគិតមើលទៅ ពីសេចក្ដីទាំងនេះមានន័យយ៉ាងម៉េច «យើងចង់បានតែសេចក្ដីមេត្តាករុណាប៉ុណ្ណោះ មិនមែនយញ្ញបូជាទេ» ព្រោះខ្ញុំមិនមែនមករក
មនុស្សសុចរិតទេ គឺមករកមនុស្សបាបវិញ»។ 14 បន្ទាប់មក ពួកសិស្សរបស់លោកយ៉ូហានចូលមកគាល់ព្រះអង្គ ហើយទូលថា៖ «ហេតុអ្វីបានជាពួកយើង និង
ពួកខាងគណៈផារីស៊ីតែងតែតមអាហារ តែសិស្សរបស់លោកមិនតមដូច្នេះ?»។ 15 ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយទៅវិញថា៖
«តើភ្ញៀវក្នុងពិធីមង្គលការអាចកាន់ទុក្ខកើតឬទេ ពេលដែលកូនកំលោះនៅជាមួយពួកគេដូច្នេះ? ប៉ុន្តែថ្ងៃមួយនឹងមកដល់ ពេលគេចាប់កូនកំលោះយកទៅ ទើប
ភ្ញៀវទាំងនោះនឹងតមអាហារវិញ។ 16 មិនដែលមាននរណាយកក្រណាត់ថ្មី មកប៉ះសម្លៀកបំពាក់ចាស់ឡើយ ព្រោះនឹងធ្វើឲ្យសម្លៀកបំពាក់នោះរហែកលើស
ដើមទៅទៀត។ 17 ក៏មិនដែលមាននរណាច្រកស្រាទំពាំងបាយជូរថ្មី ចូលក្នុងថង់ស្បែកចាស់ដែរ។ ប្រសិនបើធ្វើដូច្នេះថង់ស្បែកមុខជាធ្លាយ ស្រានឹងហូរចេញ
ហើយថង់ស្បែកត្រូវខូចខាតមិនខាន។ ផ្ទុយទៅវិញ គេតែងតែច្រកស្រាថ្មីទៅក្នុងថង់ស្បែកថ្មី ទើបទាំងស្រាទាំងថង់ស្បែកនៅគង់បាន»។ 18 កាលព្រះយេស៊ូ
កំពុងតែមានព្រះបន្ទូលការទាំងនេះទៅកាន់គេ ហើយមាននាម៉ឺនម្នាក់ចូលមកក្រាបថ្វាយបង្គំព្រះអង្គទាំងទូលថា៖ «កូនស្រីរបស់ខ្ញុំទើបនឹងស្លាប់ថ្មីៗនេះ សូម
លោកមេត្តាអញ្ជើញទៅដាក់ដៃលើនាង នោះនាងនឹងមានជីវិតរស់វិញពុំខាន»។ 19 បន្ទាប់មកព្រះយេស៊ូក្រោកឡើង ហើយយាងទៅជាមួយគាត់ ពួកសិស្សក៏
ទៅជាមួយព្រះអង្គដែរ។ 20 មានស្ត្រីម្នាក់ដែលមានជំងឺធ្លាក់ឈាម អស់រយៈពេលដប់ពីរឆ្នាំមកហើយ មកពីក្រោយព្រះយេស៊ូ ហើយពាល់ជាយព្រះពស្ត្រ
របស់ព្រះអង្គ 21 ដ្បិតនាងបានគិតក្នុងចិត្តថា៖ «បើខ្ញុំគ្រាន់តែពាល់អាវលោក ខ្ញុំនឹងជាពីជំងឺមិនខាន»។ 22 ព្រះយេស៊ូបែរទៅក្រោយ ហើយឃើញនាង ក៏មាន
ព្រះបន្ទូលថា៖ «កូនស្រីអើយ! ចូរមានចិត្តក្លាហានឡើង ជំនឿរបស់កូនបានប្រោសកូនឲ្យជាហើយ»។ ស្ត្រីធ្លាក់ឈាមក៏បានជាសះស្បើយនៅពេលនោះទៅ។
23 កាលព្រះយេស៊ូយាងចូលក្នុងផ្ទះនាម៉ឺននោះ ព្រះអង្គទតឃើញអ្នកលេងខ្លុយ និងឃើញមនុស្សម្នាជ្រួលច្របល់។ 24 ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «នាំ
គ្នាចេញទៅ! ដ្បិតក្មេងស្រីនេះមិនស្លាប់ទេ នាងគ្រាន់តែដេកលក់ប៉ុណ្ណោះ»។ ប៉ុន្តែពួកគេសើចចំអកដាក់ព្រះអង្គ។ 25 ពេលព្រះអង្គដេញពួកគេចេញទៅក្រៅ
អស់ហើយ ព្រះអង្គយាងចូលទៅក្នុងបន្ទប់ ហើយចាប់ដៃក្មេងស្រីនោះ បន្ទាប់មកនាងក៏ក្រោកឡើង។ 26 ដំណឹងនេះលេចឮពាសពេញក្នុងតំបន់នោះទាំង
មូល។ 27 កាលព្រះយេស៊ូយាងចេញពីទីនោះទៅ មានមនុស្សខ្វាក់ពីរនាក់ដើរតាមព្រះអង្គ ពួកគេស្រែកថា៖ «សូមអាណិតមេត្តាដល់យើងខ្ញុំផង ព្រះរាជវង្ស
ព្រះបាទដាវីឌអើយ!»។ 28 ពេលព្រះអង្គយាងចូលទៅក្នុងផ្ទះ មនុស្សខ្វាក់ទាំងពីរនោះចូលទៅជិតព្រះអង្គ។ ព្រះយេស៊ូមានព្រះបន្ទូលទៅអ្នកទាំងពីរនោះថា៖
«តើអ្នកជឿថាខ្ញុំអាចធ្វើការនេះបានឬទេ?»។ ពួកគេទូលព្រះអង្គវិញថា៖ «យើងខ្ញុំជឿហើយ ព្រះអម្ចាស់អើយ»។ 29 បន្ទាប់មកព្រះយេស៊ូក៏ពាល់ភ្នែកអ្នកទាំង
ពីរនោះ ទាំងមានព្រះបន្ទូលថា៖ «សុំឲ្យបានសម្រេចតាមជំនឿរបស់អ្នកចុះ»។ 30 ពេលនោះ ភ្នែករបស់ពួកគេក៏បានមើលឃើញ។ ក្រោយមកព្រះយេស៊ូ
ហាមពួកគេយ៉ាងតឹងតែងថា៖ «កុំឲ្យនរណាដឹងសោះឡើយ»។ 31 ប៉ុន្តែ បុរសទាំងពីរនោះចេញទៅផ្សព្វផ្សាយរឿងនោះឲ្យគេដឹងពាសពេញស្រុក។ 32 លុះ
ដល់អ្នកទាំងពីរចេញផុតទៅហើយ មានគេនាំមនុស្សគម្នាក់ដែលមានអារក្សចូល មកគាល់ព្រះយេស៊ូ។ 33 ពេលព្រះអង្គដេញអារក្សចេញហើយ មនុស្សគ
នោះក៏អាចនិយាយបាន។ មហាជននាំគ្នាស្ងើចសរសើរយ៉ាងខ្លាំងទាំងនិយាយថា៖ «មិនដែលឃើញការអស្ចារ្យបែបនេះ នៅស្រុកអ៊ីស្រាអែលពីមុនឡើយ»។ 34
ប៉ុន្តែ ពួកខាងគណៈផារីស៊ីពោលថា៖ «គាត់ដេញអារក្សបាន មកពីអារក្សប្រគល់អំណាចឲ្យគាត់ទេ»។ 35 ព្រះយេស៊ូយាងទៅតាមក្រុង និងតាមភូមិនានា
ព្រះអង្គបន្តបង្រៀនអ្នកស្រុកនៅក្នុងសាលាប្រជុំ ព្រមទាំងប្រកាសដំណឹងល្អអំពីព្រះរាជ្យ និងប្រោសអ្នកជំងឺ គ្រប់ប្រភេទឲ្យបានជាផង។ 36 កាលព្រះអង្គទត
ឃើញមហាជន ទ្រង់មានព្រះហឫទ័យអាណិតពួកគេណាស់ ព្រោះអ្នកទាំងនោះល្វើយ និងធ្លាក់ទឹកចិត្តពួកគេ ប្រៀបបីដូចជាចៀមដែលគ្មានគង្វាលថែទាំ។ 37
ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកសិស្សរបស់ព្រះអង្គថា៖ «ស្រូវដែលត្រូវច្រូតមានច្រើនណាស់ ប៉ុន្តមានអ្នកច្រូតតិចពេក។ 38 ហេតុនេះ
ចូរអធិស្ឋានទៅព្រះអម្ចាស់ដែលជាម្ចាស់ស្រែ សូមទ្រង់ចាត់អ្នកច្រូតមកក្នុងស្រែរបស់ព្រះអង្គ»។


generated on Thu Feb 8 15:37:30 2024

## ជំពូក 10

1 ព្រះយេស៊ូត្រាស់ហៅសិស្សទាំងដប់ពីររូបរបស់ព្រះអង្គមក ហើយទ្រង់ប្រទានឲ្យគេមានអំណាចលើវិញ្ញាណអាក្រក់ អាចដេញវិញ្ញាណអាក្រក់ចេញ មាន
អំណាចប្រោសជំងឺរោគា និងអ្នកជំងឺគ្រប់ប្រភេទឲ្យបានជាសះស្បើយ។ 2 ឈ្មោះសាវកទាំងដប់ពីរមានដូចតទៅ អ្នកទីមួយ គឺស៊ីម៉ូនហៅពេត្រុស និងអនទ្រេ
ជាប្អូនរបស់គាត់ យ៉ាកុបជាកូនរបស់លោកសេបេដេ និងយ៉ូហានជាប្អូនរបស់គាត់  3 ភីលីព និងបារថូឡូមេ ថូម៉ាស់ និងម៉ាថាយជាអ្នកទារពន្ធ យ៉ាកុបជាកូន
របស់លោកអាល់ផាយ និងថាដេ 4 ស៊ីម៉ូនជាអ្នកជាតិនិយម និងយូដាសអ៊ីស្ការីយ៉ុត ជាអ្នកដែលក្បត់ព្រះអង្គ។ 5 ព្រះយេស៊ូចាត់បញ្ជូនសិស្សទាំងដប់ពីររូប
ឲ្យចេញទៅទាំងមានការផ្ដែផ្ដាំថា៖ «កុំទៅកន្លែងដែលសាសន៍ដទៃរស់នៅឡើយ ហើយក៏កុំចូលទៅក្នុងក្រុងរបស់ជនជាតិសាម៉ារីដែរ 6 តែត្រូវទៅស្វែងរកចៀម
ដែលវង្វេង ក្នុងចំណោមជនជាតិអ៊ីស្រាអែលនោះវិញ។ 7 ពេលអ្នកធ្វើដំណើរទៅ ចូរប្រកាសប្រាប់គេថា ព្រះរាជ្យនៃស្ថានបរមសុខ មកជិតបង្កើយហើយ។ 8 ចូរ
មើលអ្នកជំងឺឲ្យជា ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ប្រោសមនុស្សឃ្លង់បានជាស្អាត និងដេញអារក្ស។ អ្នករាល់គ្នាបានទទួលដោយឥតគិតថ្លៃ ត្រូវជួយគេ
វិញដោយឥតគិតថ្លៃដែរ។ 9 កុំយកមាសប្រាក់ ឬលុយកាក់ដាក់ក្នុងថង់ឡើយ 10 កុំយកកាបូបស្ពាយ កុំយកអាវពីរបន្លាស់ កុំយកស្បែកជើង ឬដំបងទៅ
តាមខ្លួន ដ្បិតអ្នកធ្វើការត្រូវទទួលម្ហូបអាហារបរិភោគ។ 11 នៅក្នុងក្រុង ឬភូមិណាមួយដែលអ្្នកចូរ អ្នកត្រូវរកអ្នកដែលសក្តិសមហើយទទួលអ្នករាល់គ្នាឲ្យ
ស្នាក់នៅ ត្រូវស្នាក់នៅផ្ទះអ្នកនោះ រហូតដល់ពេលដែលអ្នកចាកចេញពីទីនោះ។ 12 ពេលអ្នកចូលទៅក្នុងផ្ទះណាត្រូវជម្រាបសួរអ្នកផ្ទះនោះ 13 ប្រសិនបើអ្នក
ផ្ទះនោះមានការគួរសម នោះសូមឲ្យសេចក្តីសុខសាន្តរបស់អ្នកកើតមានដល់គេ ។ ផ្ទុយទៅវិញ បើគេមិនទទួលអ្នកទេ សូមឲ្យក្តីសុខសាន្តរបស់អ្នកមកវិញចុះ។
14 បើសិនអ្នកណាមិនព្រមទទួលអ្នក ឬមិនព្រមស្ដាប់ពាក្យរបស់អ្នកទេនោះ ពេលអ្នកចាកចេញពីផ្ទះ ឬពីក្រុងនោះ ត្រូវរលាស់ធូលីដីចេញពីជើងរបស់អ្នករាល់
គ្នា។ 15 ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យដឹងប្រាកដថា ការវិនិច្ឆ័យទោសមនុស្្សក្នុងក្រុងសូដុម និងក្រុងកូម៉ូរ៉ា នោះទទួលទោសស្រាលជាងអ្នកនៅក្នុងក្រុង
នេះទៅទៀត។ 16 ខ្ញុំដឹងថា ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅ ដូចឲ្យចៀមទៅក្នុងកណ្តាលហ្វូងចចកអ៊ីចឹងដែរ។ ហេតុនេះ ត្រូវមានប្រាជ្ញាដូចជាសត្វពស់ ហើយមានចិត្ត
ស្លូតត្រង់ដូចសត្វព្រាប។ 17 ចូរប្រយ័ត្ននឹងមនុស្សលោក! ដ្បិតគេនឹងចាប់បញ្ជូនអ្នកទៅតុលាការ គេនឹងវាយអ្នកនឹងរំពាត់ខ្សែតីក្នុងសាលាប្រជុំរបស់ពួកគេ។
18 បន្ទាប់មកគេនឹងបញ្ជូនអ្នករាល់គ្នាទៅឲ្យលោកទេសាភិបាល និងឲ្យស្តេចនានាកាត់ទោស ដោយព្រោះតែខ្ញុំ។ អ្នករាល់គ្នាត្រូវធ្វើបន្ទាល់ដល់ពួកគេ និងឲ្យ
សាសន៍ដទៃបានឮផង។ 19 ពេលគេចាប់បញ្ជូនអ្នករាល់គ្នាទៅ ចូរកុំព្រួយបារម្ភនឹងរកពាក្យណា ដែលអ្នកគួរនិយាយនោះឡើយ ដ្បិតព្រះជាម្ចាស់នឹង
ប្រទានពាក្យឲ្យអ្នកត្រូវនិយាយ នៅពេលនោះ។ 20 ដ្បិត មិនមែនអ្នករាល់គ្នាទេដែលនឹងនិយាយ គឺព្រះវិញ្ញាណនៃព្រះបិតាដែលនឹងមានព្រះបន្ទូលនៅក្នុងចិត្ត
អ្នករាល់គ្នា។ 21 បងប្អូននឹងចាប់បញ្ជូនបងប្អូនខ្លួនឯង ទៅឲ្យគេសម្លាប់ ហើយឪពុកនឹងចាប់បញ្ជូនកូនខ្លួនឯងទៅឲ្យគេសម្លាប់ដែរ។ កូនៗនឹងនាំគ្នាប្រឆាំងនឹង
ឪពុកម្តាយរបស់ខ្លួន ព្រមទាំងបញ្ជូនទៅឲ្យគេសម្លាប់ទៀតផង។ 22 មនុស្សនឹងស្អប់អ្នក ព្រោះតែនាមខ្ញុំ។ ប៉ុន្តែ អ្នកណាស៊ូទ្រាំរហូតដល់ចុងបញ្ចប់
អ្នកនោះនឹងបានទទួលការសង្គ្រោះ។ 23 ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងប្រាកដថា ប្រសិនបើគេបៀតបៀនអ្នកនៅក្រុងនេះ ចូររត់ទៅក្រុងមួយទៀតទៅ
នោះអ្នករាល់គ្នានឹងមិនទៅដល់ក្រុងទាំងប៉ុន្មានក្នុងស្រុកអ៊ីស្រាអែលទេ មុនពេលបុត្រមនុស្សមកដល់។ 24 សិស្សមិនដែលចេះជាងគ្រូឡើយ ហើយអ្នកបម្រើក៏
ពុំដែលធំជាងម្ចាស់ដែរ។ 25 បើសិស្សចេះបានដូចគ្រូ និងអ្នកបម្រើបានដូចម្ចាស់ នោះវាល្មមគ្រប់គ្រាន់ហើយ។ ប្រសិនបើគេហៅឈ្មោះម្ចាស់ផ្ទះនោះថា
បេលសេប៊ូល គេមុខជាហៅឈ្មោះអ្នកនៅក្នុងផ្ទះនោះ រឹតតែអាក្រក់ជាងនេះទៅទៀតជាមិនខាន។ 26 ចូរកុំខ្លាចនិងពួកអ្នកទាំងនោះឡើយ ពីព្រោះគ្មានការលាក់
កំបាំងណាដែល មិនបើកឲ្យគេឃើញ ហើយក៏គ្មានអាថ៌កំបាំងណាដែល មិនបង្ហាញឲ្យគេដឹងដែរ។ 27 ការអ្វីដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នាក្នុងទីងងឹត ចូរ
និយាយនៅក្នុងពន្លឺថ្ងៃ ហើយអ្វីៗដែលគេឮក្នុងត្រចៀក ចូរយកទៅប្រកាសនៅពីលើដំបូលផ្ទះ។ 28 កុំខ្លាចអស់អ្នកដែលសម្លាប់បានត្រឹមតែរូបកាយ តែមិនអាច
សម្លាប់ព្រលឹងអ្នកបាននោះឲ្យសោះ គឺត្រូវខ្លាចព្រះជាម្ចាស់ដែលអាចធ្វើឲ្យទាំងព្រលឹង និងរូបកាយ ធ្លាក់ទៅក្នុងភ្លើងនរកបានវិញ។ 29 តើមិនមែនចាបពីរ គេ
លក់ថ្លៃមួយសេនឬអី? តែគ្មានចាបណាមួយធ្លាក់ចុះដល់ដី ហើយព្រះបិតារបស់អ្នករាល់គ្នាមិនដឹងនោះឡើយ។ 30 សូម្បីតែសក់នៅលើក្បាលអ្នករាល់គ្នា ក៏
ព្រះអង្គរាប់អស់ដែរ។ 31 ចូរកុំភ័យខ្លាចអ្វីឡើយ ព្រោះអ្នករាល់គ្នាមានតម្លៃលើសចាបទាំងអស់ទៅទៀត។ 32 ដូច្នេះអ្នកណាទទួលស្គាល់ខ្ញុំ នៅចំពោះមុខ
មនុស្ស ខ្ញុំនឹងទទួលស្គាល់អ្នកនោះវិញ នៅចំពោះព្រះបិតារបស់ខ្ញុំ ដែលគង់នៅស្ថានបរមសុខ។ 33 ប៉ុន្តែអ្នកណាដែលបដិសេធមិនទទួលស្គាល់ខ្ញុំនៅចំពោះមុខ
មនុស្ស ខ្ញុំក៏បដិសេធមិនទទួលស្គាល់អ្នកនោះនៅចំពោះព្រះបិតារបស់ខ្ញុំ ដែលគង់នៅស្ថានបរមសុខដែរ។ 34 កុំនឹកថា ខ្ញុំមកនេះដើម្បីនាំយកសន្តិភាពមក
ផែនដីឡើយ។ ខ្ញុំមិនបាននាំសន្តិភាពមកទេ តែខ្ញុំនាំដាវមកវិញ។ 35 ដ្បិតខ្ញុំមកដើម្បីធ្វើឲ្យកូនប្រុសប្រឆាំងជាមួយឪពុកខ្លួន កូនស្រីប្រឆាំងជាមួយម្ដាយខ្លួន
និងកូនប្រសាស្រីប្រឆាំងជាមួយម្ដាយក្មេក។ 36 សត្រូវរបស់មនុស្សគឺជាអ្នកដែលរស់នៅក្នុងផ្ទះជាមួយគ្នា។ 37 អ្នកណាដែលស្រឡាញ់ឪពុកម្តាយ ខ្លាំងជាង
ស្រឡាញ់ខ្ញុំ អ្នកនោះមិនសក្តិសមជាសិស្សខ្ញុំឡើយ។ អ្នកដែលស្រឡាញ់កូនប្រុសកូនស្រីរបស់ខ្លួន ខ្លាំងជាងស្រឡាញ់ខ្ញុំ ក៏មិនសក្តិសមធ្វើជាសិស្សខ្ញុំដែរ។ 38
អ្នកណាមិនលីឈើឆ្កាងរបស់ខ្លួន ដើរតាមខ្ញុំទេ អ្នកនោះមិនសក្តិសមធ្វើជាសិស្សខ្ញុំឡើយ។ 39 អ្នកណាចង់ស្វែងរកជីវិតរបស់ខ្លួន អ្នកនោះនឹងបាត់បង់ជីវិតវិញ
រីឯអ្នកដែលបាត់បង់ជីវិតព្រោះតែខ្ញុំ នឹងបានជីវិតនោះមកវិញ។ 40 អ្នកណាដែលទទួលអ្នករាល់គ្នា ក៏ដូចជាទទួលខ្ញុំដែរ ហើយអ្នកណាទទួលខ្ញុំ ក៏ដូចជាទទួល
ព្រះអង្គដែលចាត់ខ្ញុំអោយមកនោះដែរ។ 41 អ្នកណាទទួលព្យាការីម្នាក់ព្រោះគាត់ជាព្យាការី អ្នកនោះនឹងទទួលរង្វាន់ដូចព្យាការី។ អ្នកណាទទួលមនុស្សសុចរិត
ម្នាក់ ព្រោះគាត់ជាមនុស្សសុចរិត អ្នកនោះនឹងទទួលរង្វាន់ដូចមនុស្សសុចរិតដែរ។ 42 អ្នកណាឲ្យទឹកត្រជាក់មួយកែវ ដល់អ្នកតូចតាចម្នាក់ផឹក ព្រោះគាត់ជា
សិស្សរបស់ខ្ញុំ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកនោះនឹងមិនបាត់រង្វាន់គាត់ឡើយ។


generated on Thu Feb 8 15:37:30 2024

## ជំពូក 11

1 ក្រោយពេលព្រះយេស៊ូមានព្រះបន្ទូលផ្ដែផ្ដាំសិស្សទាំងដប់ពីររូបចប់សព្វគ្រប់ហើយ ព្រះអង្គក៏យាងចាកចេញពីទីនោះទៅបង្រៀន និងប្រកាសដំណឹងល្អនៅ
តាមក្រុងនានារបស់ពួកគេ។ 2 ពេលលោកយ៉ូហានដែលជាប់ក្នុងមន្ទីរឃុំឃាំង បានឮពីកិច្ចការទាំងប៉ុន្មានដែលព្រះគ្រិស្ដបានធ្វើ គាត់ក៏ចាត់សិស្សឲ្យទៅ 3
ហើយទូលសួរថា៖ «តើលោកគឺជាព្រះអង្គដែលត្រូវយាងមក ឬមួយយើងខ្ញុំត្រូវរង់ចាំមួយផ្សេងទៀត?» 4 ព្រះយេស៊ូមានព្រះបន្ទូលទៅពួកគេថា៖ «ចូរត្រឡប់
ទៅប្រាប់លោកយ៉ូហាន នូវអ្វីដែលអ្នករាល់គ្នាបានឮ និងបានឃើញនេះទៅ។ 5 មនុស្សខ្វាក់មើលឃើញ មនុស្សខ្វិនដើរបាន មនុស្សឃ្លង់បានជាស្អាត មនុស្ស
ថ្លង់ស្ដាប់ឮ មនុស្សស្លាប់បានរស់ឡើងវិញ ហើយមនុស្សក្រីក្របានឮដំណឹងល្អ។ 6 មានពរហើយអ្នកណាមិនរវាតចិត្តដោយព្រោះនាមខ្ញុំ»។ 7 ពេលពួកសិស្ស
របស់លោកយ៉ូហានចេញផុតទៅ ព្រះយេស៊ូចាប់ផ្ដើមមានព្រះបន្ទូលទៅមហាជនអំពីលោកយ៉ូហានថា៖ «តើអ្នករាល់គ្នាទៅវាលរហោស្ថានមើលអ្វី មើលដើម
ត្រែងដែលត្រូវខ្យល់បក់ឬ? 8 តើអ្នករាល់គ្នាទៅក្រៅមើលអ្វី? មើលមនុស្សស្លៀកពាក់ខោអាវទន់ភ្លន់ឬ? តាមពិត! អ្នកដែលស្លៀកពាក់ខោអាវទន់ភ្លន់ គេរស់នៅ
ក្នុងដំណាក់ស្ដេចឯណោះ»។ 9 ដូច្នេះ តើអ្នករាល់គ្នាទៅក្រៅ រកមើលព្យាការីម្នាក់ឬ?។ ត្រូវហើយ! ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា លោកនោះប្រសើរជាងព្យាការីទៅ
ទៀត។ 10 ដ្បិតគឺអ្នកនោះហើយ មានចែងមកថា៖ «មើល! យើងចាត់ទូតយើងឲ្យទៅមុនព្រះអង្គ គឺជាអ្នកដែលនឹងរៀបចំផ្លូវមុខព្រះអង្គ»។ 11 ខ្ញុំសុំប្រាប់
ឲ្យអ្នករាល់គ្នាដឹងប្រាកដថា ក្នុងចំណោមមនុស្សដែលកើតចេញពីផ្ទៃម្ដាយមក គ្មាននរណាមានឋានៈធំជាងលោកយ៉ូហានបាទីស្ដនោះឡើយ។ តែអ្នកណា
មានឋានៈតូចជាងគេនៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ អ្នកនោះប្រសើរលើសលោកយ៉ូហានទៅទៀត។ 12 ចាប់តាំងពីជំនាន់លោកយ៉ូហានបាទីស្ដ មកទល់
សព្វថ្ងៃនេះ ព្រះរាជ្យនៃស្ថានបរមសុខបានរងនូវអំពើឃោរឃៅ ហើយមនុស្សដែលប្រព្រឹត្តអំពើឃោរឃៅនោះ បាននាំគ្នាប្រើកម្លាំងយកព្រះរាជ្យនេះផង។ 13
ព្យាការីទាំងអស់ និងក្រឹត្យវិន័យ បានថ្លែងទុករហូតមកដល់ជំនាន់លោកយ៉ូហាន។ 14 ប្រសិនបើអ្នកព្រមទទួលការនេះ គឺលោកហ្នឹងហើយជាព្យាការីអេលីយ៉ា
ដែលត្រូវមក។ 15 អ្នកដែលមានត្រចៀកចូរស្ដាប់ ហើយយកទៅពិចារណាទៅ!។ 16 តើខ្ញុំអាចប្រៀបធៀបមនុស្សជំនាន់នេះទៅនឹងអ្វី? គឺដូចទៅនឹងកូនក្មេង
ដែលកំពុងលេងនៅតាមទីផ្សារ ដែលហៅគ្នាទៅវិញទៅមក 17 ព្រមទាំងនិយាយថា៖ «យើងបានផ្លុំខ្លុយឲ្យអ្នក តែអ្នកពុំព្រមរាំទេ។ យើងបានកាន់ទុក្ខ តែអ្នកពុំ
ព្រមយំដែរ»។ 18 ដ្បិតលោកយ៉ូហានកើតមកមិនបានបរិភោគនំប៉័ង និងសុរាទេ តែគេថា «លោកមានអារក្សចូល»។ 19 រីឯបុត្រមនុស្សមក លោកបរិភោគ
អាហារ និងពិសាសុរា តែគេថា «មើល៍! អ្នកនេះល្មោភសីុ និងជាមនុស្សប្រមឹក ហើយសេពគប់ជាមួយពួកទារពន្ធ និងមនុស្សមានបាប»។ ប៉ុន្ដែ ប្រាជ្ញាដែល
ល្អត្រឹមត្រូវវិនិច្ឆ័យទង្វើ ដែលគេបានប្រព្រឹត្តវិញ»។ 20 បន្ទាប់មក ព្រះយេស៊ូចាប់ផ្ដើមស្ដីបន្ទោសដល់ក្រុងនានា ដែលបានឃើញព្រះអង្គសម្ដែងការអស្ចារ្យ
ផ្សេងៗក្នុងក្រុងនោះ ប៉ុន្ដែ ពួកគេពុំព្រមកែប្រែចិត្តគំនិតសោះ។ 21 «អ្នកត្រូវវេទនាជាពុំខាន ក្រុងខូរ៉ាស៊ីនអើយ! ។ អ្នកក៏ត្រូវវេទនាដែរ ក្រុងបេតសៃដាអើយ! ។
ប្រសិនបើមានការអស្ចារ្យនៅក្រុងទីរ៉ូស និងក្រុងស៊ីដូន ដូចដែលអ្នករាល់គ្នាឃើញនៅទីនេះ ម្ល៉េះក្រុងទាំងនោះកែប្រែចិត្តគំនិត ហើយស្លៀកបាវអង្គុយក្នុងផេះជា
មិនខាន។ 22 ប៉ុន្ដែ នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោស ក្រុងទីរ៉ូស និងអ្នកក្រុងស៊ីដូនទទួលទោសស្រាលជាងអ្នករាល់គ្នា។ 23 អ្នកក្រុងកាពើណិមអើយ!
តើអ្នកគិតថាខ្លួនអ្នកនឹងបានតម្កើងឡើងដល់ស្ថានសួគ៌ឬ? ពុំមែនដូច្នោះឡើយ! អ្នកនឹងធ្លាក់ទៅស្ថាននរកវិញ។ ប្រសិនបើអ្នកក្រុងសូដុមបានឃើញការអស្ចារ្យ
ដូចដែលអ្នកបានឃើញ ម្ល៉េះសមក្រុងសូដុមនឹងនៅស្ថិតស្ថេរ មកទល់សព្វថ្ងៃជាមិនខាន។ 24 ប៉ុន្ដែខ្ញុំសុំប្រាប់អ្នករាល់គ្នាថា នៅថ្ងៃព្រះជាម្ចាស់វិនិច្ឆ័យទោស
អ្នកក្រុងសូដុមនឹងទទួលទោសស្រាលជាងអ្នករាល់គ្នា។ 25 នៅគ្រានោះ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ទូលបង្គំសូមសរសើរតម្កើងព្រះបិតា ជាព្រះអម្ចាស់នៃ
ស្ថានបរមសុខ និងផែនដី ព្រោះព្រះអង្គបានលាក់មិនឲ្យអ្នកប្រាជ្ញ និងអ្នកចេះដឹងយល់ទេ តែបង្ហាញការទាំងនេះឲ្យមនុស្សតូចតាចយល់វិញ។ 26 មែនហើយ!
ព្រះបិតាអើយ ដ្បិតព្រះអង្គសព្វព្រះហឫទ័យធ្វើដូច្នេះ។ 27 អ្វីៗទាំងអស់ព្រះបិតារបស់ខ្ញុំបានប្រគល់មកខ្ញុំហើយ គ្មានអ្នកណាស្គាល់ព្រះបុត្រា ក្រៅពី
ព្រះបិតាឡើយ ហើយក៏គ្មាននរណាស្គាល់ព្រះបិតា ក្រៅពីព្រះបុត្រាដែរ ហើយនិងអ្នកណាដែលព្រះបុត្រាសព្វព្រះហឫទ័យ សម្ដែងឲ្យស្គាល់នោះដែរ។ 28 អស់
អ្នកដែលនឿយហត់ និងបន្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ! ខ្ញុំនឹងឲ្យអ្នករាល់គ្នាបានសម្រាក។ 29 ចូរយកនឹមរបស់ខ្ញុំដាក់លើអ្នករាល់គ្នា ហើយរៀនពីខ្ញុំទៅ ដ្បិត ខ្ញុំ
ស្លូត និងមានចិត្តសុភាពនោះព្រលឹងរបស់អ្នករាល់គ្នានឹងជាបានសម្រាកមិនខាន។ 30 ព្រោះនឹមរបស់ខ្ញុំស្រួល ហើយបន្ទុករបស់ខ្ញុំក៏ស្រាលដែរ»។

## ជំពូក 12

1 នៅគ្រានោះ ព្រះយេស៊ូយាងកាត់តាមវាលស្រែ នៅថ្ងៃសប្ប័ទ សិស្សរបស់ព្រះអង្គឃ្លានពេក ក៏នាំគ្នាបូតកួរស្រូវមកបរិភោគ។ 2 ពេលពួកខាងគណៈផារីស៊ី
ឃើញដូចនេះ គេក៏ទូលព្រះអង្គថា៖ «មើល! សិស្សរបស់លោកនាំគ្នាធ្វើការនៅថ្ងៃសប្ប័ទ ដែលបញ្ញត្តិហាម»។ 3 ប៉ុន្តែ ព្រះយេស៊ូតបវិញថា៖
«តើអ្នកមិនធ្លាប់បានអានអត្ថបទមួយពីការដែលព្រះបាទដាវីឌ និងពួកអ្នកដែលនៅជាមួយព្រះអង្គបានប្រព្រឹត្តនៅពេលឃ្លានទេឬ? 4 ព្រះអង្គបានយាងចូល
ទៅក្នុងដំណាក់របស់ព្រះជាម្ចាស់ ហើយបរិភោគនំប៉័ងដែលគេតាំងថ្វាយព្រះជាម្ចាស់ គឺផ្ទុយនឹងបញ្ញត្តិហាមឃាត់ គឺមានតែពួកបូជាចារ្យប៉ុណ្ណោះ ដែលអាច
បរិភោគនំប៉័ងនេះបាន។ 5 តើអ្នករាល់គ្នាមិនដែលអានគម្ពីរវិន័យដែលថា នៅថ្ងៃសប្ប័ទពួកបូជាចារ្យបំពេញមុខងារនៅក្នុងព្រះវិហារ សុទ្ធតែរំលោភលើ
ក្រឹត្យវិន័យថ្ងៃសប្ប័ទទាំងអស់ ឬឥតមានទោសឡើយ? 6 ប៉ុន្តែ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ម្នាក់ដែលប្រសើរជាងព្រះវិហារទៅទៀតនោះ គឺនៅទីនេះហើយ។ 7
ប្រសិនបើអ្នករាល់គ្នាយល់ពីអត្ថន័យនេះ «ខ្ញុំមិនចង់បានយញ្ញបូជានោះទេ គឺចង់បានតែចិត្តមេត្តាករុណាប៉ុណ្ណោះ” អ្នករាល់គ្នាមុខជាមិនប្រកាន់ទោសដល់ជន
ដែលគ្មានទោសទាំងនេះឡើយ 8 ដ្បិតបុត្រមនុស្សជាម្ចាស់របស់ថ្ងៃសប្ប័ទ»។ 9 បន្ទាប់មក ព្រះយេស៊ូចាកចេញពីទីនោះ ហើយយាងចូលទៅក្នុងសាលាប្រជុំ
របស់ពួកគេ។ 10 មើល! នៅទីនោះមានបុរសស្វិតដៃម្នាក់នៅក្នុងសាលាប្រជុំនោះដែរ។ ពួកផារីស៊ីគេនាំគ្នាទូលសួរព្រះអង្គថា៖ «តើយើងមានសិទ្ធិប្រោសអ្នកជំងឺ
ឲ្យជានៅថ្ងៃសប្ប័ទបានដែរឬទេ?» គេសួរដូច្នេះ ក្នុងបំណងរកលេសដើម្បីចោទប្រកាន់ព្រះអង្គថាបានប្រព្រឹត្តអំពើបាប។ 11 ព្រះយេស៊ូមានព្រះបន្ទូលទៅគេ
ថា៖ «ក្នុងចំណោមអ្នករាល់គ្នា បើនរណាម្នាក់មានចៀមតែមួយ ហើយចៀមនោះធ្លាក់រណ្ដៅដ៏ជ្រៅនៅថ្ងៃសប្ប័ទ តើអ្នកនោះមិនទៅស្រង់យកចៀមឡើងមកវិញ
ទេឬ?។ 12 រីឯមនុស្សវិញ គឺមានតម្លៃថ្លៃលើសចៀមឆ្ងាយណាស់! ដូច្នេះយើងមានសិទ្ធិធ្វើអំពើល្អនៅថ្ងៃសប្ប័ទបាន»។ 13 បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូល
ទៅកាន់បុរសស្វិតដៃនោះថា៖ «ចូរលាតដៃរបស់អ្នកមើល៍!។ បុរសនោះលាតដៃ ហើយដៃគាត់ក៏បានជាដូចដៃម្ខាងទៀត។ 14 ប៉ុន្តែពួកខាងគណៈផារីស៊ីចេញពី
សាលាប្រជុំ ហើយពិគ្រោះគ្នាប្រឆាំងព្រះអង្គ។ ពួកគេថែមទាំងរកមធ្យោបាយធ្វើគុតព្រះអង្គទៀតផង។ 15 កាលព្រះយេស៊ូជ្រាបពីការនេះហើយ ទ្រង់យាងចាក
ចេញពីទីនោះទៅ មានមហាជនជាច្រើនដើរតាមព្រះអង្គ ហើយព្រះអង្គបានប្រោសពួកគេឲ្យជាពីជំងឺទាំងអស់គ្នា 16 ព្រះអង្គហាមគេយ៉ាងម៉ឺងម៉ាត់ មិនឲ្យ
និយាយអំពីព្រះអង្គប្រាប់អ្នកដទៃឡើយ 17 ដើម្បីឲ្យស្របនឹងសេចក្ដីដែលបានចែងទុកមក តាមរយៈព្យាការីអេសាយថា៖ 18 «មើល! នេះហើយយជាអ្នកបម្រើ
ដែលយើងបានជ្រើសរើស ជាអ្នកដែលយើងស្រឡាញ់ ហើយជាអ្នកដែលធ្វើឲ្យចិត្តយើងរីករាយ។ យើងនឹងដាក់វិញ្ញាណរបស់យើងឲ្យសណ្ឋិតលើលោក ហើយ
លោកនឹងប្រកាសប្រាប់ឲ្យសាសន៍ដទៃដឹងពីការវិនិច្ឆ័យទោសរបស់ព្រះអង្គ។ 19 លោកនឹងមិនឈ្លោះប្រកែក ឬក៏ស្រែកដាក់នរណាឡើយ ហើយក៏គ្មាននរណា
ឮសំឡេងរបស់លោកនៅតាមផ្លូវដែរ។ 20 លោកនឹងមិនកាច់ដើមត្រែងណាដែលទក់ហើយនោះឡើយ ហើយលោកក៏មិនផ្លុំពន្លត់ភ្លើងណា ដែលហៀបនឹង
រលត់ហើយនោះដែរ រហូតដល់លោកនាំសេចក្ដីសុចរិតឲ្យមានជ័យជម្នះ។ 21 សាសន៍ដទៃនឹងមានសង្ឃឹមដោយសារលោក»។ 22 បន្ទាប់មក មានគេនាំបុរស
ខ្វាក់ភ្នែក និងថ្លង់ផង ដែលត្រូវបានអារក្សចូល មកគាល់ព្រះអង្គ។ ព្រះអង្គប្រោសគាត់ឲ្យជា បុរសនោះក៏អាចនិយាយបាន និងមើលឃើញទៀតផង។ 23
មហាជនទាំងអស់ស្ញប់ស្ញែងហើយពោលថា៖ «តើលោកនេះពិតជាព្រះរាជវង្សរបស់ព្រះបាទដាវីឌមែនឬ?» 24 ប៉ុន្តែ ពេលពួកខាងគណៈ
ផារីស៊ីបានឮពីការអស្ចារ្យនោះដ៏ពោលថា៖ អ្នកនេះដេញអារក្សបាន គឺដោយបេលសេប៊ូល ជាស្ដេចអារក្សទេ»។ 25 ប៉ុន្តែព្រះយេស៊ូឈ្វេងយល់គំនិតរបស់គេ
ព្រះអង្គក៏មានព្រះបន្ទូលទៅគេថា៖ «នគរណាមានការបាក់បែកទាស់ទែងគ្នាឯង នគរនោះមុខជាត្រូវវិនាសមិនខាន រីឯក្រុង ឬផ្ទះណាមានការបាក់បែក
ទាស់ទែងគ្នាឯង ក៏មិនអាចនៅស្ថិតស្ថេរបានដែរ។ 26 ប្រសិនបើមារសាតាំងបណ្ដេញមារសាតាំង វាគឺមានការបាក់បែកទាស់ទែងនឹងខ្លួនវា។ តើធ្វើម្ដេចឲ្យរាជ្យ
របស់វានៅស្ថិតស្ថេរបាន? 27 ហើយប្រសិនបើខ្ញុំដេញអារក្ស ដោយសារបេលសេប៊ូលមែននោះ តើកូនចៅរបស់អ្នកដេញអារក្ស ដោយអាងលើនរណាវិញ?
ដោយហេតុផលនេះ គេនឹងដាក់ទោសអ្នករាល់គ្នាជាពុំខាន។ 28 ប៉ុន្តែ បើខ្ញុំដេញអារក្សដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ នោះបានសេចក្ដីថា ព្រះរាជ្យរបស់
ព្រះអង្គបានមកដល់អ្នករាល់គ្នាហើយ។ 29 តើមាននរណាចូលទៅក្នុងផ្ទះមនុស្សខ្លាំងពូកែ ហើយរឹបអូសយកទ្រព្យសម្បត្តិរបស់គាត់ ដោយមិនចងមនុស្សខ្លាំង
ពូកែនោះជាមុនសិន? 30 អ្នកណាមិននៅខាងខ្ញុំ អ្នកនោះប្រឆាំងនឹងខ្ញុំ ហើយអ្នកណាមិនជួយប្រមូលផ្ដុំជាមួយខ្ញុំទេ អ្នកនោះជាអ្នកកំចាត់កំចាយហើយ។ 31
ហេតុដូច្នេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា រាល់អំពើបាបនិង ពាក្យប្រមាថព្រះជាម្ចាស់ ព្រះអង្គនឹងលើកលែងទោសឲ្យបាន ប៉ុន្តែការប្រមាថព្រះវិញ្ញាណ
វិញ ព្រះអង្គនឹងមិនលើកលែងទោសឲ្យសោះឡើយ។ 32 បើអ្នកណានិយាយទាស់នឹងបុត្រមនុស្ស ព្រះជាម្ចាស់នឹងលើកលែងទោសឲ្យគេបាន ប៉ុន្តែអ្នក
ដែលនិយាយទាស់នឹងព្រះវិញ្ញាណដ៏វិសុទ្ធវិញ ព្រះអង្គមិនលើកលែងទោសឲ្យទេ ទោះបីនៅក្នុងលោកនេះ ឬនៅបរលោកក្ដី ។ 33 ដាំដើមឈើល្អ ផ្លែក៏ល្អដែរ
តែបើដាំដើមឈើអាក្រក់វិញ ផ្លែវាក៏អាក្រក់ដែរ ដ្បិតគេស្គាល់ដើមឈើតាមផ្លែរបស់វា។ 34 ពួកពូជពស់វែកអើយ! អ្នករាល់គ្នាជាសុទ្ធតែមនុស្សអាក្រក់
តើអាចឲ្យអ្នកនិយាយសេចក្ដីល្អៗបានយ៉ាងដូចម្ដេចទៅ? ដ្បិតមាត់របស់មនុស្សតែងនិយាយនូវសេចក្ដីណា ដែលមាននៅក្នុងចិត្តរបស់ខ្លួន។ 35 មនុស្សល្អតែង
ប្រព្រឹត្តល្អ ចេញពីចិត្តរបស់ខ្លួន រីឯមនុស្សអាក្រក់វិញ តែងប្រព្រឹត្តអាក្រក់ ព្រោះចិត្តគេមានសុទ្ធតែគំនិតអាក្រក់។ 36 ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា នៅថ្ងៃ
ព្រះជាម្ចាស់វិនិច្ឆ័យទោស ព្រះអង្គនឹងវិនិច្ឆ័យមនុស្សតាមពាក្យសម្ដីដែលគេបាននិយាយ។ 37 ដ្បិតគេនឹងរាប់អ្នកថាសុចរិតដោយសារពាក្យសម្ដីរបស់អ្នក
ហើយគេនឹងថ្កោលទោសអ្នករាល់គ្នា ដោយសារពាក្យសម្ដីដែរ។ 38 បន្ទាប់មក ពួកអាចារ្យ និងពួកខាងគណៈផារីស៊ី ឆ្លើយតបទៅព្រះយេស៊ូ និងទូលព្រះអង្គ
ថា៖ «លោកគ្រូ! យើងចង់ឃើញទីសម្គាល់អស្ចារ្យមួយពីលោកគ្រូ»។ 39 ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖ «មនុស្សជំនាន់នេះអាក្រក់ណាស់ ហើយ
មានចិត្តក្បត់ទៀត គេចង់តែឃើញទីសម្គាល់អស្ចារ្យ។ ប៉ុន្ត ព្រះជាម្ចាស់នឹងមិនប្រទានទីសម្គាល់ណាផ្សេងទៀត ក្រៅពីទីសម្គាល់របស់ព្យាការីយ៉ូណាសឡើយ។
40 លោកយ៉ូណាសនៅក្នុងពោះត្រីធំរយៈពេលបីថ្ងៃបីយប់យ៉ាងណា នោះបុត្រមនុស្សក៏នឹងស្ថិតនៅក្នុងដីរយៈបីថ្ងៃបីយប់យ៉ាងនោះដែរ។ 41 អ្នកក្រុងនីនីវេនឹង
ក្រោកឡើងជាមួយមនុស្សជំនាន់នេះ នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោក ព្រមទាំងចោទប្រកាន់គេផង។ ដ្បិតពួកគេបានកែប្រែចិត្តគំនិត
ពេលបានឮសេចក្ដីដែលលោកយ៉ូណាសប្រកាសប្រាប់។ រីឯនៅទីនេះ មានម្នាក់ដែលប្រសើរជាងលោកយ៉ូណាសទៅទៀត។ 42 មហាក្សត្រីស្រុកខាងត្បូង នឹង
ក្រោកឡើងនៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោក ជាមួយមនុស្សជំនាន់នេះ ព្រមទាំងចោទប្រកាន់គេផង។ ព្រះនាងបានយាងមកពី
ទីដាច់ស្រយាលនៃផែនដី ដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះបាទសាឡូម៉ូន ប្រកបដោយប្រាជ្ញាឈ្លាសវៃ។ រីឯនៅទីនេះ មានម្នាក់ប្រសើរជាងព្រះបាទសាឡូម៉ូនទៅ
ទៀត។ 43 ពេលវិញ្ញាណអាក្រក់ចេញពីមនុស្សណាម្នាក់ហើយ វាតែងតែទៅចុះឡើងនៅកន្លែងហួតហែង រកមើលកន្លែងសម្រាក តែវារកពុំឃើញទេ។ 44
បន្ទាប់មក វាមុខជានិយាយថា អញនឹងវិលត្រឡប់ទៅផ្ទះ ដែលអញទើបចេញមក លុះទៅដល់ហើយ វាឃើញផ្ទះនោះនៅទំនេរ បោសស្អាត ហើយតុបតែង
យ៉ាងល្អនោះ។ 45 វានឹងទៅបបួលវិញ្ញាណអាក្រក់ប្រាំពីរផ្សេងទៀត ដែលសុទ្ធតែអាក្រក់ជាងវា មកចូលនៅក្នុងផ្ទះនោះ ក្រោយមកមនុស្សនោះរឹតតែអាក្រក់
លើសដើមទៅទៀត។ មនុស្សនៅជំនាន់នេះអាក្រក់ណាស់»។ 46 ខណៈពេលព្រះយេស៊ូកំពុងតែមានព្រះបន្ទូលទៅកាន់មហាជននៅឡើយ មាតា និងបងប្អូន
របស់ព្រះអង្គ មកឈរចាំនៅខាងក្រៅ ចង់រកនិយាយជាមួយព្រះអង្គ។ 47 មានម្នាក់ទូលព្រះអង្គថា៖ «មើល៍! ម្ដាយលោក និងបងប្អូនលោកនៅខាងក្រៅ ចង់
និយាយជាមួយលោក»។ 48 ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់វិញថា៖ «តើនរណាជាម្ដាយខ្ញុំ ហើយនរណាជាបងប្អូនខ្ញុំ?»។ 49 ព្រះអង្គលើក
ព្រះហស្ដចង្អុលទៅពួកសិស្ស ហើយមានព្រះបន្ទូលថា៖ «មើល! អ្នកទាំងនេះហើយជាមាតា និងជាបងប្អូនរបស់ខ្ញុំ 50 ដ្បិតអ្នកណាធ្វើតាមព្រះហឫទ័យរបស់
ព្រះបិតាខ្ញុំ ដែលគង់នៅស្ថានបរមសុខ អ្នកនោះហើយគឺជាបងប្អូនប្រុសស្រី និងជាម្ដាយរបស់ខ្ញុំ»។


generated on Thu Feb 8 15:37:30 2024

## ជំពូក 13

1 នៅថ្ងៃនោះ ព្រះយេស៊ូបានចាកចេញពីផ្ទះ ហើយយាងទៅគង់នៅមាត់សមុទ្រ។ 2 មានមហាជនជាច្រើនកុះករ មកចោមរោមព្រះអង្គ ដូច្នេះ ព្រះអង្គក៏យាងចុះ
ទៅគង់ក្នុងទូកមួយ រីឯបណ្តាជនឈរនៅមាត់ច្រាំង។ 3 បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅគេយ៉ាងច្រើន ដោយប្រើប្រស្នា។ ព្រះអង្គមានព្រះបន្ទូលថា៖
«មើល! មានកសិករម្នាក់ចេញទៅព្រោះគ្រាប់ពូជ។ 4 ពេលគាត់ព្រោះគ្រាប់ពូជ នោះមានគ្រាប់ពូជខ្លះធ្លាក់ទៅលើផ្លូវ ហើយសត្វស្លាបមកចឹកស៊ីអស់ទៅ។ 5
គ្រាប់ពូជខ្លះទៀតធ្លាក់ទៅលើកន្លែងមានថ្ម ពុំសូវមានដី ភ្លាមនោះគ្រាប់ពូជក៏ដុះឡើងលើដីមិនជ្រៅ។ 6 ប៉ុន្តែ លុះដល់ថ្ងៃរះឡើង វាក៏ក្រៀមស្វិតអស់ទៅ ព្រោះ
វាមិនមានឫស។ 7 គ្រាប់ពូជខ្លះទៀតធ្លាក់ទៅលើដីមានបន្លា ពេលបន្លានោះដុះឡើង ក៏បាំងគ្រប់ពូជនោះមិនឲ្យដុះបានឡើយ។ 8 មានគ្រាប់ពូជខ្លះទៀត ធ្លាក់
ទៅលើដីមានជីជាតិល្អ ហើយគ្រាប់ពូជមួយគ្រាប់ ឲ្យផលជាមួយរយគ្រាប់ មួយជាហុកសិប និងមួយទៀតជាសាមសិប។ 9 អ្នកដែលមានត្រចៀក សូម
ស្តាប់យកទៅពិចារណាចុះ»។ 10 ពួកសិស្សនាំគ្នាចូលមកជិតព្រះយេស៊ូ ហើយទូលសួរថា៖ «ហេតុអ្វីបានជាព្រះអង្គមានព្រះបន្ទូលទៅកាន់បណ្តាជន ដោយ
ប្រើពាក្យប្រស្នាដូច្នេះ?» 11 ព្រះយេស៊ូតបទៅគេវិញថា៖ «មកពីព្រះជាម្ចាស់បានប្រទានឲ្យអ្នករាល់គ្នាយល់ ពីគម្រោងការដ៏លាក់កំបាំងនៃព្រះរាជ្យរបស់ស្ថាន
បរមសុខ ប៉ុន្តែ រីឯពួកគេវិញ ព្រះអង្គពុំបានប្រទានឲ្យគេយល់ឡើយ។ 12 ដ្បិតអ្នកណាដែលមានហើយ អ្នកនោះនឹងបានបរិបូរណ៍ថែមទៀត រីឯអ្នកដែល
គ្មានវិញ សូម្បីអ្វីដែលគេមាននឹងត្រូវដកហូតពីអ្នកនោះទៀតផង។ 13 នេះជាមូលហេតុ ដែលខ្ញុំនិយាយទៅពួកគេ ដោយប្រើពាក្យប្រស្នា ទោះបីគេប្រឹងមើល
ក៏មើលពុំឃើញ ហើយទោះបីគេស្តាប់ក៏ស្តាប់ពុំឮ ហើយក៏មិនយល់ដែរ។ 14 ដើម្បីឲ្យបានសម្រេចស្របនឹងសេចក្តីដែលព្យាការី អេសាយថ្លែងទុកពីគេថា៖
«អ្នករាល់គ្នាស្តាប់មែនតែមិនយល់ទេ ហើយអ្នករាល់គ្នាមើលមែន តែមើលមិនឃើញដែរ។ 15 ដ្បិត ចិត្តរបស់មនុស្សទាំងនេះរឹងណាស់ ហើយពួកគេក៏
ពិបាកស្តាប់ដែរ គេខំបិទភ្នែក មិនឲ្យមើលឃើញ មិនឲ្យត្រចៀកស្តាប់ឮមិនឲ្យចិត្តយល់ ដូច្នេះ គេនឹងវិលត្រឡប់មកវិញម្តងទៀត ហើយយើងនឹងប្រោសគេ
ឲ្យបានជា»។ 16 ប៉ុន្តែ ភ្នែករបស់អ្នកមានពរហើយ ដ្បិតភ្នែកអ្នករាល់គ្នាមើលឃើញ ត្រចៀកស្តាប់ឮ។ 17 ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យដឹងប្រាកដថា មានព្យាការី
និងមនុស្សសុចរិតជាច្រើនមានបំណងចង់ឃើញការណ៍ ដែលអ្នករាល់គ្នាឃើញនេះណាស់ តែគេមិនបានឃើញទេ គេមានបំណងចង់ឮសេចក្តីដែលអ្នករាល់គ្នា
ឮណាស់ តែមិនបានឮឡើយ។ 18 សុំស្តាប់ពីការបកស្រាយប្រស្នាអំពីអ្នកព្រោះគ្រាប់ពូជ។ 19 ពេលអ្នកណាដែលបានឮព្រះបន្ទូលអំពីព្រះរាជ្យ តែមិន
យល់នោះ ព្រោះមារកំណាចមកឆក់យកព្រះបន្ទូលដែលបានធ្លាក់ក្នុងចិត្តគេនោះចេញទៅ នេះគឺជាគ្រាប់ពូជធ្លាក់នៅតាមផ្លូវ ។ 20 រីឯគ្រាប់ពូជដែលធ្លាក់លើដី
មានថ្ម គឺអ្នកដែលបានឮព្រះបន្ទូលហើយ ក៏ទទួលយកភ្លាមដោយអំណរ 21 តែគេពុំបានឲ្យព្រះបន្ទូលចាក់ឫសនៅក្នុងខ្លួនគេឡើយ ហើយគេជាប់ចិត្តតែ
មួយភ្លែតប៉ុណ្ណោះ ដល់ពេលមានទុក្ខលំបាកកើតឡើង ឬមានគេបៀតបៀនដោយសារតែព្រះបន្ទូល គេក៏បោះបង់អ្វីដែលគេជឿនោះភ្លាម។ 22 គ្រាប់ពូជ
ដែលធ្លាក់លើដីមានបន្លា គឺអ្នកដែលឮព្រះបន្ទូលហើយ ប៉ុន្តែមានការខ្វល់ខ្វាយអំពីជីវិតក្នុងលោកីយ៍ និងការបោកបញ្ឆោតនៃទ្រព្យសម្បត្តិ គឺនាំឲ្យព្រះបន្ទូល
មិនបង្កើតផលក្នុងគេឡើយ។ 23 រីឯគ្រាប់ពូជដែលធ្លាក់លើដីមានជីជាតិល្អ គឺអស់អ្នកដែលបានឮព្រះបន្ទូលហើយយល់ គេបង្កើតផល ខ្លះបានមួយជាមួយរយ
មួយជាហុកសិប និងខ្លះទៀតបានមួយជាសាមសិប។ 24 ព្រះយេស៊ូមានព្រះបន្ទូលជាពាក្យប្រស្នាទៅគេទៀតថា៖ «ព្រះរាជ្យនៃស្ថានបរមសុខប្រៀបដូចនឹង
បុរសម្នាក់ ដែលបានព្រោះគ្រាប់ពូជល្អទៅក្នុងស្រែរបស់គាត់។ 25 ប៉ុន្តែ ពេលមនុស្សដេកលក់អស់ទៅ ហើយសត្រូវរបស់គាត់បានមក ថែមទាំងព្រោះស្រងែនៅ
ក្នុងស្រែនោះដែរ រួចក៏ចេញបាត់ទៅ។ 26 ពេលស្រូវដុះឡើងហើយដាក់គ្រាប់ ស្រងែក៏ដុះឡើងមកជាមួយដែរ។ 27 ពួកអ្នកបម្រើបានចូលមកជម្រាបម្ចាស់ស្រែ
ថា៖ «លោកម្ចាស់! តើលោកមិនបានព្រោះតែគ្រាប់ពូជល្អក្នុងស្រែរបស់លោកទេឬអី? ចុះស្រងែនេះមកបានដោយរបៀបណាទៅ?» 28 ម្ចាស់តបវិញថា៖ «
មានមារសត្រូវមកព្រោះស្រងែ»។ ពួកអ្នកបម្រើសួរលោកទៀតថា៖ «តើលោកចង់ឲ្យយើងទៅដកស្រងែនោះចេញឬទេ?» 29 ម្ចាស់ស្រែតបថា៖ «កុំអី!
ពីព្រោះបើអ្នករាល់គ្នាដកស្រងែ ក្រែងលោដោយស្រូវទៅជាមួយដែរ 30 ទុកឲ្យវាដុះជាមួយគ្នារហូតដល់ស្រូវទុំចុះ លុះដល់ពេលចម្រូត ខ្ញុំនឹងប្រាប់ពួកអ្នកច្រូត
មុនដំបូងត្រូវប្រមូលស្រងែចងជាបាច់ យកទៅដុតចោលជាមុនសិន រួចសឹមប្រមូលស្រូវមកដាក់ក្នុងជង្រុករបស់ខ្ញុំ»។ 31 បន្ទាប់មកព្រះយេស៊ូមានព្រះបន្ទូល
ជាពាក្យប្រស្នាមួយទៀតទៅពួកគេថា៖ «ព្រះរាជ្យនៃស្ថានបរមសុខប្រៀបដូចជាគ្រាប់ពូជតូចល្អិតម្យ៉ាង ដែលបុរសម្នាក់យកទៅដាំនៅក្នុងស្រែរបស់ខ្លួន។ 32
គ្រាប់ពូជនោះគឺពិតជាគ្រាប់ពូជដែលតូចជាងគេទាំងអស់ ប៉ុន្តែពេលវាដុះឡើង វាធំជាងដំណាំឯទៀតៗ គឺវាទៅជាដើមឈើមួយយ៉ាងធំ ហើយ
បក្សាបក្សីដែលហោះនៅលើើអាកាស មកធ្វើសំបុកស្នាក់អាស្រ័យនៅតាមមែករបស់វា»។ 33 ព្រះយេស៊ូមានព្រះបន្ទូលជាពាក្យប្រស្នាមួយទៀតទៅគេថា៖
«ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបីដូចជាមេនំប៉័ង ដែលស្ត្រីម្នាក់យកទៅលាយនឹងម្សៅបីរង្វាល់ រហូតដល់ធ្វើឲ្យម្សៅនោះដោរឡើងទាំងអស់»។ 34
គ្រប់សេចក្តីដែលព្រះយេស៊ូមានព្រះបន្ទូលទៅកាន់មហាជនគឺជាពាក្យប្រស្នាទាំងអស់ ព្រះអង្គមិនដែលមានព្រះបន្ទូលទៅគេ ដោយឥតប្រើពាក្យប្រស្នានោះ
ឡើយ។ 35 ដើម្បីឲ្យស្របនឹងសេចក្តីដែលបានចែងទុកតាមរយៈពួកព្យាការីមកថា៖ យើងនឹងនិយាយជាពាក្យប្រស្នាទៅគេ យើងនឹងនិយាយការលាក់កំបាំង
តាំងពីដើមកំណើតពិភពលោកមក ឲ្យគេដឹង»។ 36 បន្ទាប់មក ព្រះយេស៊ូយាងចេញពីមហាជនចូលទៅក្នុងផ្ទះ។ ពួកសិស្សរបស់ព្រះអង្គនាំគ្នាចូលមកគាល់
ព្រះអង្គទាំងទូលថា៖ «សូមលោកគ្រូបកស្រាយប្រស្នាអំពីស្រងែក្នុងស្រែ ឲ្យយើងខ្ញុំបានយល់ផង»។ 37 ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេវិញថា៖ «អ្នកព្រោះ
គ្រាប់ពូជល្អ គឺបុត្រមនុស្ស។ 38 ស្រែគឺពិភពលោកនេះ ហើយគ្រាប់ពូជល្អ គឺកូននៃព្រះរាជ្យរបស់ព្រះអង្គ ស្រងែគឺកូនចៅរបស់មារកំណាច 39 ហើយសត្រូវ
ដែលព្រោះស្រងែគឺមារ។ រដូវចម្រូត គឺជាអវសានកាលនៃពិភពលោក ហើយអ្នកច្រូត គឺជាទេវតា។ 40 ដូច្នេះកាលស្រងែត្រូវគេយកទៅដុតក្នុងភ្លើងយ៉ាងណា
នៅអវសានកាលនៃពិភពលោក ក៏នឹងកើតមានយ៉ាងនោះដែរ។ 41 បុត្រមនុស្សនឹងចាត់បញ្ជូនទេវតារបស់លោកឲ្យមក ហើយទេវតាទាំងនោះនឹងប្រមូលអ្នក
ដែលនាំគេឲ្យប្រព្រឹត្តអំពើបាប និងអ្នកដែលប្រព្រឹត្តអំពើទុច្ចរិតយកចេញពីព្រះរាជ្យរបស់ព្រះអង្គ។ 42 ទេវតានឹងបោះអ្នកទាំងនោះទៅក្នុងភ្លើងដែលឆេះ
សន្ធោសន្ធៅ ជាកន្លែងមានតែសំរែកយំសោក ខឹងសង្កៀតធ្មេញ។ 43 រីឯមនុស្សសុចរិតវិញ គេនឹងមានរស្មីភ្លឺឡើងដូចព្រះអាទិត្យ នៅក្នុងព្រះរាជ្យនៃព្រះបិតា
របស់គេ។ អ្នកណាមានត្រចៀក សូមស្តាប់ហើយយកទៅពិចារណាចុះ! 44 ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបដូចជាកំណប់ដែលគេកប់ទុកនៅក្នុងវាលស្រែ។
មានបុរសម្នាក់រកកំណប់នោះឃើញ ហើយក៏កប់ទុកវិញ។ គាត់មានចិត្តត្រេកអរជាខ្លាំង ហើយក៏ចេញទៅលក់ទ្រព្យសម្បត្តិទាំងប៉ុន្មានដែលគាត់មាន យកប្រាក់
មកទិញដីស្រែនោះ។ 45 ខ្ញុំសូមប្រាប់អ្្នកម្តងទៀតថា ព្រះរាជ្យនៃស្ថានបរមសុខប្រៀបដូចជាអ្នកជំនួញម្នាក់ ដែលស្វែងរកទិញត្បូងគុជដ៏មានតម្លៃ។ 46
កាលគាត់បានឃើញត្បូងគុជមួយដ៏មានតម្លៃហើយ គាត់ក៏ទៅលក់អ្វីៗទាំងអស់ដែលគាត់មាន ហើយយកប្រាក់មកទិញត្បូងគុជនោះ។ 47
ខ្ញុំសូមប្រាប់អ្នកម្តងទៀតថា ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបីដូចជាអួនដែលគេបោះទម្លាក់នៅក្នុងសមុទ្រ ហើយជាប់បានត្រីគ្រប់ប្រភេទ។ 48 ពេលបានជាប់
ត្រីពេញហើយ អ្នកនេសាទអូសអួននោះឡើងមកលើឆ្នេរ រួចហើយអង្គុយរើសត្រីល្អៗដាក់ក្នុងកញ្ជ្រោ ប៉ុន្តែចំណែកត្រីមិនល្អវិញ គេបោះចោល។ 49 នៅ
គ្រាអវសានកាលនៃពិភពលោក ក៏នឹងកើតមានដូច្នេះដែរ។ ពួកទេវតានឹងមកញែកមនុស្សទុច្ចរិត ចេញពីចំណោមមនុស្សសុចរិត។ 50 មនុស្ស
ទុច្ចរិតនឹងត្រូវបោះទៅក្នុងភ្លើងដែលឆេះសន្ធោសន្ធៅ ជាកន្លែងដែលមានតែសម្រែកយំសោកខឹងសង្កៀតធ្មេញ។ 51 តើអ្នករាល់គ្នាយល់សេចក្តីទាំងនេះឬទេ?
ពួកសិស្សទូលព្រះអង្គថា៖ «យល់ហើយ!» 52 បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅពួកគេទៀតថា៖ «ហេតុនេះហើយបានជាពួកអាចារ្យដែលទទួលការ
បង្រៀនពីព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបបានទៅនឹងម្ចាស់ផ្ទះដែលយកទ្រព្យចាស់ និងទ្រព្យថ្មីទាំងអស់ចេញពីឃ្លាំងរបស់គាត់ដូច្នោះដែរ»។ 53 បន្ទាប់ពី
ព្រះយេស៊ូមានព្រះបន្ទូលពីរឿងប្រស្នាទាំងនេះចប់សព្វគ្រប់ហើយ ព្រះអង្គក៏យាងចេញពីទីនោះទៅ។ 54 បន្ទាប់មក ព្រះយេស៊ូត្រឡប់ទៅស្រុករបស់ព្រះអង្គវិញ

ហើយព្រះអង្គបង្រៀនអ្នកស្រុកទាំងនោះនៅក្នុងសាលាប្រជុំរបស់គេ ដោយធ្វើឲ្យគេងឿងឆ្ងល់ ហើយគេបានពោលថា៖ «តើគាត់បានទទួលប្រាជ្ញា និង
ឫទ្ធានុភាពធ្វើការអស្ចារ្យទាំងនេះមកពីណាមក? 55 តើអ្នកនេះមិនមែនជាកូនរបស់ជាងឈើទេឬ? តើម្ដាយរបស់គាត់ពុំមែនមានឈ្មោះថានាងម៉ារីទេឬ?
ហើយតើយបងប្អូនគាត់ពុំមែនមានឈ្មោះយ៉ាកុប យ៉ូសែប ស៊ីម៉ូន និងយូដាសទេឬ? 56 តើប្អូនស្រីរបស់គាត់ទាំងប៉ុន្មានមិនមែនរស់នៅក្នុងភូមិជាមួយយើង
ដែរទេឬ? តើគាត់ដឹងសេចក្ដីទាំងនេះពីណាមក?» 57 ពួកគេបែរចិត្តចេញពីព្រះអង្គ។ ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ជាធម្មតា ព្យាការីមនុស្សតែងតែ
មិនទទួលស្គាល់នៅក្នុងស្រុកកំណើត និងក្នុងផ្ទះខ្លួន»។ 58 ទ្រង់មិនអាចធ្វើការអស្ចារ្យនៅទីនោះឡើយ ព្រោះគេមិនមានជំនឿ។


generated on Thu Feb 8 15:37:30 2024

## ជំពូក 14

1 នៅគ្រានោះ ហេរ៉ូដ ជាស្ដេចអនុរាជបានជ្រាបអំពីព្រះនាមរបស់ព្រះយេស៊ូ។ 2 ទ្រង់មានរាជឱង្ការទៅពួកអ្នកបម្រើថា៖ «នេះជាលោកយ៉ូហានបាទីស្ដ ដែល
បានរស់ឡើងវិញ។ ដូច្នេះ គាត់មានឫទ្ធានុភាពសម្ដែងការអស្ចារ្យនៅក្នុងគាត់»។ 3 ដ្បិត ព្រះបាទហេរ៉ូដបានចាប់លោកយ៉ូហានយកទៅដាក់ច្រវាក់ ហើយ
ឃុំឃាំងគាត់នៅក្នុងគុកហើយ ពីព្រោះដោយសារតែទ្រង់ជឿតាមពាក្យព្រះនាងហេរ៉ូឌាស ដែលត្រូវជាមហេសីរបស់ស្ដេចភីលីពជាអនុជ។ 4 ដ្បិតលោកយ៉ូហាន
បានបន្ទោសស្ដេចថា៖ «ខុសនឹងច្បាប់ហើយ បើព្រះករុណាយកព្រះនាងមកធ្វើជាមហេសី»។ 5 ស្ដេចហេរ៉ូដចង់សម្លាប់លោកយ៉ូហាន តែទ្រង់ខ្លាចបណ្ដាជន
ព្រោះពួកគេទុកលោកជាព្យាការីមួយរូប។ 6 ប៉ុន្ដែ នៅថ្ងៃបុណ្យចម្រើនព្រះជន្មរបស់ព្រះបាទហេរ៉ូដ បុត្រីរបស់ព្រះនាងហេរ៉ូឌាសចូលមករាំនៅមុខភ្ញៀវ ហើយធ្វើ
ឲ្យស្ដេចហេរ៉ូដពេញចិត្ដខ្លាំងណាស់។ 7 រហូតធ្វើឲ្យស្ដេចស្បថស្បែទាំងសន្យាឲ្យនាង នូវអ្វីៗដែលនាងចង់បាន។ 8 ក្រោយពីបានទទួលពាក្យបង្គាប់របស់មាតា
របស់ព្រះនាង នាងទូលទៅស្ដេចថា៖ «សូមទ្រង់ប្រទានក្បាលរបស់លោកយ៉ូហានបាទីស្ដ ដាក់លើថាសមកឲ្យខ្ញុំម្ចាស់មក»។ 9 ព្រះរាជាទ្រង់ព្រួយព្រះហឫទ័យ
យ៉ាងខ្លាំង ដោយព្រោះសំណើរនេះ ប៉ុន្ដែដោយព្រោះទ្រង់បានស្បថនៅមុខភ្ញៀវទាំងអស់ ជ្រុលហួសទៅហើយ ទ្រង់ក៏បញ្ជាឲ្យគេធ្វើតាមពាក្យសុំរបស់នាងទៅ។
10 ទ្រង់ចាត់គេឲ្យទៅកាត់កលោកយ៉ូហាននៅក្នុងគុក។ 11 ហើយយកក្បាលមកដាក់លើថាសរួចប្រគល់ឲ្យនាង ហើយនាងក៏យកទៅថ្វាយមាតារបស់ខ្លួន។
12 ក្រោយមកពួកសិស្សរបស់លោកយ៉ូហាន បានមកយកសពលោកទៅបញ្ចុះ។ បន្ទាប់មកពួកគេនាំគ្នាយកដំណឹងទៅទូលព្រះយេស៊ូ។ 13 ពេលព្រះយេស៊ូ
បានជ្រាបដំណឹងនេះហើយ ទ្រង់ក៏យាងចុះទូក ចាកចេញពីទីនោះ ឆ្ពោះទៅកាន់កន្លែងមួយស្ងាត់ដាច់ឡែកពីគេ។ ពេលមហាជនបានដឹងថា ព្រះអង្គចាកចេញ
គេនាំគ្នាចេញពីក្រុងនានាដើរទៅតាមព្រះអង្គ។ 14 លុះព្រះយេស៊ូយាងឡើងពីទូកមក ព្រះអង្គឃើញមហាជនដ៏ច្រើនយ៉ាងនេះ ព្រះអង្គក៏មានព្រះហឫទ័យ
អាណិតអាសូរដល់គេ ហើយទ្រង់ក៏ប្រោសអ្នកជំងឺឲ្យបានជាសះស្បើយ។ 15 លុះដល់ពេលល្ងាច សិស្សនាំគ្នាចូលមកជិតព្រះអង្គហើយទូលថា៖ «ទីនេះស្ងាត់
ណាស់ ហើយក៏ជិតយប់ផង សូមប្រាប់ឲ្យបណ្ដាជនទាំងនេះត្រឡប់ទៅវិញចុះ ហើយរកទិញម្ហូបអាហារនៅតាមភូមិនានារៀងៗខ្លួនទៅ»។ 16 ប៉ុន្ដែ ព្រះយេស៊ូ
មានព្រះបន្ទូលទៅគេថា៖ «មិនបាច់ឲ្យពួកគេវិលត្រឡប់ទៅវិញទេ អ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ»។ 17 ពួកសិស្សទូលព្រះអង្គថា៖ «យើង
មានតែនំប៉័ងប្រាំដុំ និងត្រីងៀតពីរកន្ទុយប៉ុណ្ណោះ»។ 18 ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ចូរយកនំប៉័ង និងត្រីនោះមកឲ្យខ្ញុំ»។ 19 បន្ទាប់មក ព្រះយេស៊ូប្រាប់
បណ្ដាជនអោយអង្គុយលើស្មៅ ទ្រង់យកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមក ទ្រង់ងើបព្រះភក្ដ្រមើលទៅឋានសួគ៌ ទាំងសរសើរតម្កើងព្រះជាម្ចាស់ហើយ
កាច់នំប៉័ងប្រទានឲ្យពួកសិស្ស ពួកសិស្សក៏ចែកឲ្យបណ្ដាជនបរិភោគ។ 20 អ្នកទាំងនោះបានបរិភោគឆ្អែតគ្រប់គ្នា ហើយពួកសិស្សក៏ប្រមូលនំប៉័ងដែលនៅសល់
ដាក់បានពេញដប់ពីរល្អី។ 21 អ្នកដែលបានបរិភោគនំប៉័ងនោះ មានប្រុសៗទាំងអស់ប្រមាណប្រាំពាន់នាក់ ឥតគិតស្រីៗ និងក្មេងៗទេ។ 22 រំពេចនោះ
ព្រះយេស៊ូបញ្ជាឲ្យពួកសិស្សចុះទូកឆ្លងទៅត្រើយម្ខាងមុនព្រះអង្គ ខណៈពេលដែលព្រះអង្គបានប្រាប់មហាជនឲ្យវិលត្រឡប់ទៅផ្ទះវិញដែរ។ 23 បន្ទាប់ពីទ្រង់
បានឲ្យមហាជនចេញផុតអស់ហើយ ព្រះអង្គឡើងទៅលើភ្នំ ដើម្បីអធិស្ឋាន។ លុះដល់ពេលយប់ ទ្រង់គង់នៅទីនោះតែមួយព្រះអង្គឯង។ 24 ពេលនោះ ទូក
បានចេញឆ្ងាយពីច្រាំងទៅហើយ ក៏ត្រូវរលកបក់បោក ព្រោះតែទៅបញ្ច្រាសខ្យល់។ 25 ដល់ម៉ោងបួនទាបភ្លឺ ព្រះយេស៊ូយាងលើទឹកឆ្ពោះទៅរកពួកគេ។ 26
ពេលពួកសិស្សបានឃើញព្រះអង្គយាងលើទឹកសមុទ្រដូច្នេះ ពួកគេភ័យរន្ធត់ ហើយស្រែកឡើងថា៖ «ខ្មោចលង!» ព្រោះគេភ័យពេក។ 27 ប៉ុន្ដែរំពេចនោះ
ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ចូរតាំងចិត្តក្លាហានឡើង នេះគឺខ្ញុំទេតើ! កុំខ្លាចអី!» 28 លោកពេត្រុសទូលតបថា៖ «លោកម្ចាស់ ប្រសិនបើពិតជាលោក
មែន សូមបញ្ជាឲ្យខ្ញុំអាចដើរលើទឹកទៅរកលោកផង»។ 29 ព្រះយេស៊ូមានព្រះបន្ទូលថា៖ «អញ្ជើញមក!» លោកពេត្រុសក៏ចុះពីទូក ហើយដើរលើទឹកឆ្ពោះទៅ
រកព្រះយេស៊ូ។ 30 ប៉ុន្ដែ ពេលពេត្រុសឃើញខ្យល់បក់បោក លោកក៏ភ័យណាស់ ហើយចាប់ផ្ដើមលិចទៅក្នុងទឹក លោកស្រែកឡើងថា៖ «លោកម្ចាស់អើយ
សូមជួយខ្ញុំផង!»។ 31 ព្រះយេស៊ូក៏លូកព្រះហស្ដរបស់ព្រះអង្គទាញលោកពេត្រុសឡើងភ្លាម ទាំងមានព្រះបន្ទូលថា៖ «មនុស្សមានជំនឿតិចអើយ! ហេតុ
អ្វីបានជាអ្នកមានចិត្ដសង្ស័យដូច្នេះ?។ 32 បន្ទាប់មក ព្រះយេស៊ូ និងលោកពេត្រុសចូលមកក្នុងទូក ហើយខ្យល់ក៏ស្ងប់ទៅ។ 33 សិស្សនៅក្នុងទូកនាំគ្នាក្រាប
ថ្វាយបង្គំព្រះយេស៊ូ ទាំងពោលថា៖ «ព្រះអង្គពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន»។ 34 ពេលពួកគេបានឆ្លងទៅដល់ត្រើយម្ខាង ពួកគេទៅស្រុក
គេនេសារ៉ែត។ 35 នៅពេលអ្នកស្រុកនោះស្គាល់ព្រះអង្គភ្លាម គេយកដំណឹងទៅផ្សព្វផ្សាយពាសពេញតំបន់ជិតនោះទាំងមូល ហើយគេនាំអ្នកជំងឺមករកព្រះអង្គ
36 ពួកគេអង្វរសូមគ្រាន់តែពាល់ជាយព្រះពស្ត្ររបស់ព្រះអង្គប៉ុណ្ណោះ ហើយអស់អ្នកដែលបានពាល់ បានជាសះស្បើយគ្រប់ៗគ្នា។

## ជំពូក 15

1 មានពួកខាងគណៈផារីស៊ី និងពួកអាចារ្យមកពីក្រុងយេរូសាឡឹម ចូលមកគាល់ព្រះយេស៊ូ ពួកគេទូលថា៖ 2 «ហេតុអ្វីបានជាសិស្សរបស់លោកមិនគោរពតាម
ទំនៀមទម្លាប់របស់ចាស់បុរាណដូច្នេះ? ដ្បិតពួកគេមិនបានលាងដៃមុន ពេលគេបរិភោគអាហារ»។ 3 ព្រះអង្គមានព្រះបន្ទូលឆ្លើយតបទៅគេវិញថា៖ «ចុះហេតុ
ដូចម្ដេចបានជាអ្នករាល់គ្នាប្រព្រឹត្តល្មើសនឹងបទបញ្ជារបស់ព្រះជាម្ចាស់ ដោយទៅកាន់តាមទំនៀមទម្លាប់របស់អ្នករាល់គ្នាវិញដូច្នេះ»? 4 ព្រោះព្រះជាម្ចាស់មាន
ព្រះបន្ទូលថា៖ ចូរគោរពមាតាបិតារបស់អ្នក ហើយអ្នកណាជេរប្រទេចផ្ដាសាមាតាបិតារបស់ខ្លួន នឹងត្រូវស្លាប់ជាមិនខាន។ 5 ប៉ុន្តែអ្នករាល់គ្នាវិញ បែរជាពោល
ថា៖ បើអ្នកណានិយាយទៅឪពុកម្ដាយថា អ្វីៗដែលឪពុកអ្នកម្ដាយត្រូវទទួលពីខ្ញុំនោះ ខ្ញុំបានទុកសម្រាប់ថ្វាយព្រះជាម្ចាស់ទេ 6 អ្នកនោះមិនបាច់គោរពឪពុក
ទេ។ ត្រង់នេះហើយ ដែលអ្នករាល់គ្នាមិនគោរពព្រះបន្ទូលរបស់ព្រះជាម្ចាស់ បែរទៅប្រព្រឹត្តតាមទំនៀមទម្លាប់របស់ខ្លួនវិញ។ 7 មនុស្សមានពុតអើយ! ពាក្យ
ដែលព្យាការីអេសាយបានថ្លែងទុកអំពីអ្នករាល់គ្នាត្រូវណាស់ 8 គឺថា៖ «ប្រជារាស្ត្រនេះគោរពយើងតែបបូរមាត់ប៉ុណ្ណោះ តែចិត្តគេនៅឆ្ងាយពីយើងណាស់។ 9
គេថ្វាយបង្គំយើងដោយឥតការអ្វីសោះ ពីព្រោះគេបង្រៀនតែក្បួនច្បាប់របស់មនុស្សតែប៉ុណ្ណោះ»។ 10 បន្ទាប់មក ព្រះអង្គហៅបណ្ដាជនឲ្យមក ហើយព្រះអង្គ
មានព្រះបន្ទូលប្រាប់គេថា៖ «ចូរស្ដាប់ ហើយឲ្យយល់ផង។ 11 គ្មានអ្វីមួយដែលចូលតាមមាត់មនុស្ស ហើយធ្វើឲ្យមនុស្សទៅជាមិនបរិសុទ្ធឡើយ ផ្ទុយទៅវិញ
មានតែអ្វីដែលចេញពីមាត់មនុស្សប៉ុណ្ណោះ ដែលធ្វើឲ្យមនុស្សត្រឡប់ទៅជាមិនបរិសុទ្ធវិញ»។ 12 បន្ទាប់មក ពួកសិស្សនាំគ្នាចូលមក ហើយទូលព្រះអង្គថា៖
«តើលោកគ្រូជ្រាបទេថា ពួកខាងគណៈផារីស៊ីទាស់ចិត្តខ្លាំងណាស់ ពេលគេឮលោកគ្រូមានប្រសាសន៍ដូច្នេះ»។ 13 ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេវិញថា៖
«គ្រប់រុក្ខជាតិទាំងឡាយណា ដែលព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខមិនបានដាំទេ ទ្រង់នឹងដកវាចោល។ 14 កុំខ្វល់ពីគេឡើយ អ្នកទាំងនោះសុទ្ធតែ
ជាមនុស្សខ្វាក់ទេ។ បើមនុស្សខ្វាក់ដឹកដៃមនុស្សខ្វាក់ គេទាំងពីរមុខជាធ្លាក់រណ្ដៅមិនខាន»។ 15 លោកពេត្រុសទូលព្រះយេស៊ូថា៖ «សូម
លោកគ្រូជួយបកស្រាយពាក្យប្រស្នានេះឲ្យយើងយល់ផង»។ 16 ព្រះយេស៊ូមានព្រះបន្ទូលថា៖ «តើអ្នករាល់គ្នានៅតែគ្មានការយល់ដឹងដូចគេដែរឬ? 17 តើអ្នក
រាល់គ្នាមិនយល់ទេឬអី ថាអ្វីៗដែលចូលតាមមាត់មនុស្ស ត្រូវចូលទៅក្នុងពោះ រួចធ្លាក់ទៅកន្លែងបន្ទោរបង់? 18 ប៉ុន្តែ អ្វីៗដែលចេញពីមាត់មនុស្ស សុទ្ធតែកើត
ចេញពីចិត្តមក។ សេចក្ដីទាំងនោះហើយដែលធ្វើឲ្យមនុស្សទៅជាមិនបរិសុទ្ធ។ 19 ដ្បិតសេចក្ដីដែលចេញពីចិត្តមក គឺជាគំនិតអាក្រក់ ការកាប់សម្លាប់ អំពើផិត
ក្បត់ កាមគុណថោកទាប ការលួចប្លន់ សាក្សីក្លែងក្លាយ និងពាក្យត្មះតិះដៀល។ 20 សេចក្ដីទាំងនេះហើយដែលធ្វើឲ្យមនុស្សក្លាយទៅជាមិនបរិសុទ្ធនោះ។
ចំណែកឯការបរិភោគដោយមិនបានលាងដៃនោះ មិនធ្វើឲ្យមនុស្សក្លាយទៅជាមិនបរិសុទ្ធនោះឡើយ»។ 21 បន្ទាប់មក ព្រះយេស៊ូយាងចេញពីទីនោះ ឆ្ពោះទៅ
កាន់តំបន់ជិតក្រុងទីរ៉ូស និងក្រុងស៊ីដូន។ 22 មើល! មានស្ត្រីសាសន៍កាណានម្នាក់នៅស្រុកនោះ។ នាងចូលមកគាល់ព្រះអង្គ ហើយទូលព្រះអង្គថា៖ «សូម
អាណិតមេត្តាដល់នាងខ្ញុំផង ឱព្រះអម្ចាស់ ជារាជវង្សរបស់ព្រះបាទដាវីឌអើយ! កូនស្រីរបស់នាងខ្ញុំត្រូវអារក្សចូលបណ្ដាលឲ្យវេទនាខ្លាំងណាស់»។ 23 ប៉ុន្តែ
ព្រះយេស៊ូពុំបានឆ្លើយតបទៅនាងសោះឡើយ។ ពួកសិស្សរបស់ព្រះអង្គនាំគ្នាចូលមកជិតព្រះអង្គ ហើយអង្វរទូលថា៖ «សូមលោកគ្រូដេញនាងចេញទៅ! ដ្បិត
នាងចេះតែស្រែកអង្វរតាមពីក្រោយយើងដូច្នេះ»។ 24 ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ព្រះជាម្ចាស់មិនបានចាត់ឲ្យខ្ញុំមករកអ្នកផ្សេង ក្រៅពីជនជាតិ
អ៊ីស្រាអែលដែលវង្វេងនោះទេ»។ 25 ប៉ុន្តែ ស្ត្រីនោះបានចូលមកចំពោះព្រះអង្គហើយទូលថា៖ «ព្រះអម្ចាស់អើយ សូមជួយនាងខ្ញុំផង!» 26 ព្រះអង្គមាន
ព្រះបន្ទូលតបថា៖ «មិនគួរយកនំប៉័ងកូនរបស់ខ្លួន បោះទៅឲ្យកូនឆ្កែស៊ីឡើយ»។ 27 នាងទូលព្រះអង្គថា៖ «ពិតមែនហើយព្រះអម្ចាស់អើយ! ប៉ុន្តែ កូនឆ្កែ
វាគ្រាន់តែស៊ីកំទេចអាហារ ដែលជ្រុះពីតុរបស់ម្ចាស់វា»។ 28 រួចព្រះយេស៊ូក៏មានព្រះបន្ទូលតបទៅនាងថា៖ «នាងអើយ នាងមានជំនឿមាំមួនណាស់ សូម
ឲ្យបានសម្រេចដូចដែលចិត្តនាងប្រាថ្នាចុះ!» ពេលនោះ កូនស្រីរបស់នាងក៏បានជាសះស្បើយ។ 29 ព្រះយេស៊ូចាកចេញពីទីនោះ ឆ្ពោះទៅកាន់ជិតឆ្នេរសមុទ្រ
កាលីឡេ។ បន្ទាប់មក ទ្រង់ក៏យាងឡើងទៅលើភ្នំ ហើយព្រះអង្គគង់ចុះនៅទីនោះ។ 30 មានមហាជនច្រើនកុះករនាំគ្នាចូលមករកព្រះអង្គ ពួកគេនាំមនុស្សខ្វិន
មនុស្សខ្វាក់ មនុស្សគថ្លង់ មនុស្សពិការជើង និងអ្នកមានជំងឺផ្សេងទៀតមកជាមួយដែរ។ គេដាក់អ្នកទាំងនោះនៅទៀបព្រះបាទារបស់ព្រះយេស៊ូ ហើយព្រះអង្គក៏
ប្រោសពួគេឲ្យបានជាគ្រប់គ្នា។ 31 មហាជននាំគ្នាកោតស្ញប់ស្ញែងក្រៃលែង ពេលឃើញមនុស្សគនិយាយបាន មនុស្សពិការជើងជាដូចធម្មតា មនុស្សខ្វិនដើរ
បាន និងមនុស្សខ្វាក់មើលឃើញ ពួកគេលើកតម្កើងព្រះជាម្ចាស់នៃជនជាតិអ៊ីស្រាអែល។ 32 ព្រះយេស៊ូហៅពួកសិស្សមកឯទ្រង់ ហើយមានព្រះបន្ទូលថា៖ «ខ្ញុំ
អាណិតបណ្ដាជននេះខ្លាំងណាស់ ព្រោះពួកគេនៅជាមួយខ្ញុំអស់រយៈពេលបីថ្ងៃមកហើយ ហើយគ្មានអ្វីបរិភោគសោះ។ ខ្ញុំមិនចង់ឲ្យគេត្រឡប់ទៅវិញ
ទាំងអត់មានអីបរិភោគនោះឡើយ ក្រែងលោកគេអស់កម្លាំងដួលនៅតាមផ្លូវ»។ 33 ពួកសិស្សទូលព្រះអង្គថា៖ «តើយើងទៅរកម្ហូបអាហារឯណាមក ឲ្យ
បណ្ដាជនច្រើនយ៉ាងនេះបរិភោគគ្រាន់ទៅ ព្រោះទីនេះស្ងាត់ណាស់?» 34 ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «តើអ្នករាល់គ្នាមាននំប៉័ងប៉ុន្មានដុំ?» ពួកគេទូល
ថា៖ «មានប្រាំពីរដុំ និងមានត្រីតូចៗខ្លះទៀតដែរ»។ 35 បន្ទាប់មក ព្រះយេស៊ូក៏ប្រាប់បណ្ដាជនឲ្យអង្គុយផ្ទាល់នៅលើដី។ 36 ទ្រង់យកនំប៉័ងទាំងប្រាំពីរដុំ និង
ត្រីមកកាន់ ហើយបន្ទាប់ពីអរព្រះគុណព្រះជាម្ចាស់ហើយ ទ្រង់ក៏កាច់ហើយប្រទានឲ្យពួកសិស្ស ពួកសិស្សក៏យកទៅចែកឲ្យបណ្ដាជន។ 37
បណ្ដាលជនទាំងនោះគេបរិភោគឆ្អែតគ្រប់ៗគ្នា ហើយពួកសិស្សប្រមូលនំប៉័ង និងត្រីដែលនៅសល់ បានប្រាំពីរល្អី។ 38 មនុស្សដែលបានបរិភោគនោះមាន
ចំនួនបួនពាន់នាក់ មិនគិតស្រីៗ និងក្មេងៗទេ។ 39 បន្ទាប់មក ព្រះយេស៊ូប្រាប់មហាជនឲ្យវិលត្រឡប់ទៅផ្ទះវិញ រួចហើយទ្រង់យាងចុះទូក ឆ្ពោះទៅតំបន់
ម៉ាកាដាន។


generated on Thu Feb 8 15:37:30 2024

## ជំពូក 16

1 ពួកខាងគណៈផារីស៊ី និងពួកខាងគណៈសាឌូស៊ី នាំគ្នាចូលមកគាល់ព្រះអង្គ ក្នុងគោលបំណងចាប់កំហុសព្រះអង្គ ដោយសុំឲ្យព្រះអង្គសម្ដែងទី
សម្គាល់ពីលើមេឃមក។ 2 ប៉ុន្តែ ព្រះអង្គមានព្រះបន្ទូលតបទៅគេថា៖ «នៅពេលថ្ងៃល្ងាច«អ្នករាល់គ្នានិយាយថា «អាកាសធាតុល្អ ព្រោះផ្ទៃមេឃពណ៌ក្រហម
»។ 3 នៅពេលព្រឹក អ្នករាល់គ្នានិយាយថា៖ «ថ្ងៃនេះនឹងមានភ្លៀងហើយ ព្រោះផ្ទៃមេឃក្រហមស្រទំ»។ អ្នករាល់គ្នាយល់ហេតុការណ៍ផ្សេងៗនៅលើមេឃបាន
តែអ្នករាល់គ្នាមិនយល់ទីសម្គាល់នាសម័យនេះសោះ! 4 មនុស្សជំនាន់នេះអាក្រក់ ហើយផិតក្បត់ទៀត គេចង់តែឃើញទីសម្គាល់ដ៏អស្ចារ្យ ប៉ុន្តែនឹងមិនទី
សម្គាល់ណាផ្សេងក្រៅពីទីសម្គាល់របស់លោកយ៉ូណាសឡើយ។ បន្ទាប់មក ព្រះយេស៊ូយាងចាកចេញពីគេទៅ។ 5 ពេលពួកសិស្សឆ្លងទៅដល់ត្រើយម្ខាងហើយ
ពួកគេភ្លេចយកនំប៉័ងទៅជាមួយ។ 6 ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ចូរអ្នករាល់គ្នាត្រូវប្រយ័ត្ននឹងដំបែររបស់ពួកខាងគណៈផារីស៊ី និងពួកខាងគណៈ
សាឌូស៊ី»។ 7 ពួកសិស្សជជែកគ្នាគេថា៖ «មកពីយើងមិនបានយកនំប៉័ងមកជាមួយ»។ 8 ព្រះយេស៊ូជ្រាបពីគំនិតរបស់គេ ក៏មានព្រះបន្ទូលថា៖ «មនុស្សមាន
ជំនឿតិចអើយ! ម្ដេចក៏ជជែកគ្នាអំពីរឿងគ្មាននំប៉័ងដូច្នេះ? 9 តើអ្នករាល់គ្នានៅតែពុំទាន់យល់ និងមិនចាំទេឬអី នំប៉័ងត្រឹមតែប្រាំដុំអាចចម្អែតមនុស្សប្រាំពាន់
នាក់ ហើយអ្នករាល់គ្នាប្រមូលនៅសល់បានប៉ុន្មានល្អី? 10 ឬនំប៉័ងប្រាំពីរដុំ ចម្អែតមនុស្សបួនពាន់នាក់ ហើយអ្នករាល់គ្នាប្រមូលនៅសល់បានប៉ុន្មានល្អី? 11
ហេតុដូចម្ដេចបានជាអ្នករាល់គ្នានៅតែមិនយល់ថា ខ្ញុំមិនបាននិយាយទៅអ្នករាល់គ្នាអំពីនំប៉័ងទេនោះទេ? គឺចង់ឲ្យអ្នករាល់គ្នាប្រយ័ត្ននឹងដំបែររបស់ពួកខាង
គណៈផារីស៊ី និងពួកខាងគណៈសាឌូស៊ីឯណោះទេ។ 12 ពេលនោះ ពួកសិស្សយល់ថា ព្រះអង្គចង់ឲ្យគេប្រយ័ត្ននឹងសេចក្ដី ដែលពួកខាងគណៈផារីស៊ី និងពួក
ខាងគណៈសាឌូស៊ីបង្រៀន មិនមែនប្រយ័ត្នអំពីមេម្សៅនោះឡើយ។ 13 កាលព្រះយេស៊ូយាងមកដល់ជិតស្រុកសេសារាភីលីព ព្រះអង្គមានព្រះបន្ទូលសួរពួក
សិស្សរបស់ព្រះអង្គថា៖ «តើមនុស្សថាបុត្រមនុស្សជានរណា?» 14 ពួកគេទូលថា៖ «អ្នកខ្លះថាលោកជាលោកយ៉ូហានបាទីស្ដ អ្នកខ្លះថាលោកជាព្យាការី
អេលីយ៉ា ហើយអ្នកខ្លះទៀតថា លោកជាព្យាការីយេរេមា ឬជាព្យាការីណាមួយរូប»។ 15 ព្រះអង្គនិយាយទៅគេថា៖ «ប៉ុន្តែ ចុះអ្នករាល់គ្នាវិញ តើថាខ្ញុំជានរណា
ដែរ?» 16 លោកស៊ីម៉ូនពេត្រុសទូលព្រះអង្គថា៖ «លោកជាព្រះគ្រិស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ»។ 17 ព្រះយេស៊ូមានព្រះបន្ទូលតប
ទៅគាត់វិញថា៖ «មានពរ ហើយ ស៊ីម៉ូនកូនលោកយ៉ូណាសអើយ! មិនមែនដោយគំនិតប្រាជ្ញាខាងលោកីយ៍ទេ ប៉ុន្តែព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខ
បានសម្ដែងឲ្យអ្នកដឹង។ 18 ខ្ញុំសុំប្រាប់អ្នកថាអ្នកឈ្មោះពេត្រុស ហើយនៅលើផ្ទាំងសិលានេះ ខ្ញុំនឹងសង់ក្រុមជំនុំរបស់ខ្ញុំ ទ្វារមច្ចុរាជពុំមានអំណាចលើក្រុមជំនុំ
នេះបានឡើយ។ 19 ខ្ញុំនឹងប្រគល់កូនសោព្រះរាជ្យនៃស្ថានបរមសុខឲ្យអ្នក។ អ្វីៗដែលអ្នកចងនៅលើផែនដី ព្រះជាម្ចាស់នឹងចងនៅស្ថានបរមសុខដែរ ហើយ
អ្វីៗដែលអ្នកស្រាយនៅលើផែនដីនេះ ព្រះជាម្ចាស់ក៏នឹងស្រាយនៅស្ថានបរមសុខដែរ»។ 20 បន្ទាប់មក ព្រះយេស៊ូហាមពួកសិស្ស មិនឲ្យប្រាប់នរណាថា
ព្រះអង្គជាព្រះគ្រិស្ដឡើយ។ 21 តាំងពីពេលនោះមក ព្រះយេស៊ូចាប់ផ្ដើមប្រាប់ឲ្យពួកសិស្សរបស់ព្រះអង្គដឹងថា ព្រះអង្គត្រូវតែយាងទៅក្រុងយេរូសាឡឹម។ ពួក
ព្រឹទ្ធាចារ្យ ពួកនាយកបូជាចារ្យនឹងនាំគ្នាធ្វើបាបព្រះអង្គឲ្យរងទុក្ខលំបាកយ៉ាងខ្លាំង ថែមទាំងធ្វើគុតព្រះអង្គទៀតផង តែបីថ្ងៃក្រោយមក ព្រះអង្គនឹងមានព្រះជន្ម
រស់ឡើងវិញ។ 22 បន្ទាប់មកលោកពេត្រុស នាំព្រះអង្គទៅដាច់ឡែកពីគេ ហើយទូលជំទាស់ថា៖ «ព្រះអម្ចាស់អើយ! សូមកុំឲ្យហេតុការណ៍នេះ កើតមានដល់
ព្រះអង្គឡើយ»។ 23 ព្រះយេស៊ូ បែរមកមានព្រះបន្ទូលទៅលោកពេត្រុសថា៖ «នែ៎ មារសាតាំងអើយ! ថយទៅខាងក្រោយខ្ញុំ ដ្បិតអ្នកកំពុងរារាំងផ្លូវខ្ញុំ
ព្រោះគំនិតរបស់អ្នកមិនមែនមកពីព្រះជាម្ចាស់ទេ គឺជាគំនិតរបស់មនុស្សលោកសុទ្ធសាធ»។ 24 បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកសិស្ស
របស់ព្រះអង្គថា៖ «បើអ្នកណាចង់មកតាមក្រោយខ្ញុំ អ្នកនោះត្រូវលះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរបស់ខ្លួន ហើយមកតាមខ្ញុំចុះ 25 បើអ្នកណាចង់បានរួច
ជីវិត អ្នកនោះនឹងបាត់បង់ជីវិត ប៉ុន្តែ អ្នកណាបាត់បង់ជីវិតព្រោះតែខ្ញុំ អ្នកនោះនឹងបានជីវិតវិញ។ 26 តើនឹងមានប្រយោជន៍អ្វី បើមនុស្សម្នាក់បានពិភពលោក
ទាំងមូល តែបាត់បង់ជីវិតវិញនោះ? តើមនុស្សអាចយកអ្វីមកប្ដូរនឹងជីវិតរបស់ខ្លួនបាន? 27 ដ្បិតបុត្រមនុស្សយាងមក ប្រកបដោយសិរីរុងរឿងព្រះបិតារបស់
ព្រះអង្គ ហើយមកជាមួយពួកទេវតារបស់ព្រះអង្គដែរ។ ព្រះអង្គនឹងប្រទានរង្វាន់តាមអំពើដែលខ្លួនបានប្រព្រឹត្ត។ 28 ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា អ្នក
ខ្លះដែលឈរនៅទីនេះនឹងមិនស្លាប់ទេ រហូតទាល់តែបានឃើញបុត្រមនុស្សយាងមកគ្រងព្រះរាជ្យ»។

## ជំពូក 17

1 ប្រាំមួយថ្ងៃក្រោយមក ព្រះយេស៊ូនាំពេត្រុស យ៉ាកុប និងយ៉ូហានជាប្អូនទៅជាមួយ ហើយទ្រង់នាំគេឡើងទៅលើភ្នំដាច់ឡែកពីគេ។ 2 ព្រះអង្គប្រែជាមានទ្រង់
ទ្រាយប្លែកនៅមុខពួកសិស្ស គឺព្រះភក្ត្ររបស់ព្រះអង្គបញ្ចេញរស្មីចែងចាំងដូចពន្លឺព្រះអាទិត្យ ហើយព្រះពស្ត្ររបស់ព្រះអង្គត្រឡប់ជាមានពណ៌សដូចពន្លឺ។ 3
លោកម៉ូសេ និងព្យាការីអេលីយ៉ាបានលេចមកសន្ទនាជាមួយព្រះអង្គ។ 4 ពេត្រុសទូលព្រះអង្គថា៖ «ព្រះអម្ចាស់! ជាការប្រសើរណាស់ដែលយើងខ្ញុំបាននៅទី
នេះ។ បើសិនព្រះអង្គសព្វព្រះហឫទ័យ ទូលបង្គំនឹងសង់ជម្រកបី គឺមួយសម្រាប់ព្រះអង្គ មួយសម្រាប់លោកម៉ូសេ និងមួយទៀតសម្រាប់លោកអេលីយ៉ា។ 5
កាលពេត្រុសកំពុងតែមានប្រសាសន៍នៅឡើយ ស្រាប់តែមានពពកដ៏ភ្លឺមកគ្របបាំងគេទាំងអស់គ្នា ហើយមានព្រះសូរសៀងបន្លឺពីក្នុងពពកមកថា៖ «នេះជា
បុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ព្រះហឫទ័យនឹងព្រះអង្គណាស់ ចូរស្ដាប់ព្រះអង្គចុះ!» 6 ពេលដែលពួកសិស្សឮដូច្នោះ ពួកគេនាំគ្នាក្រាបចុះ អោន
មុខដល់ដី ព្រោះគេភ័យខ្លាចខ្លាំងណាស់។ 7 បន្ទាប់មកព្រះយេស៊ូយាងមក ហើយដាក់ព្រះហស្ដលើគេ ទាំងមានព្រះបន្ទូលថា៖ «ចូរនាំគ្នាក្រោកឡើង កុំខ្លាច
អី!» 8 កាលពួកសិស្សងើបមុខឡើង ឃើញតែព្រះយេស៊ូមួយព្រះអង្គប៉ុណ្ណោះ។ 9 ពេលទ្រង់យាងចុះពីលើភ្នំជាមួយពួកសិស្សវិញ ព្រះយេស៊ូហាមប្រាមគេថា៖
«កុំនិយាយប្រាប់នរណា អំពីហេតុការណ៍ដែលអ្នករាល់គ្នាបានឃើញនេះឡើយ ត្រូវចាំរហូតដល់បុត្រមនុស្ស មានជីវិតរស់ឡើងវិញ»។ 10 ពួក
សិស្សរបស់ព្រះអង្គទូលសួរព្រះអង្គថា៖ «ហេតុដូចម្ដេចបានជាពួកអាចារ្យតែងតែនិយាយថា ព្យាការីអេលីយ៉ាត្រូវអញ្ជើញមកមុនដូច្នោះ?» 11 ព្រះយេស៊ូមាន
ព្រះបន្ទូលតបថា៖ «លោកអេលីយ៉ាអញ្ជើញមកមែន ដើម្បីរៀបចំសព្វគ្រប់ទាំងអស់ឡើងវិញ។ 12 ប៉ុន្តែ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា លោកអេលីយ៉ាបានអញ្ជើញ
មករួចហើយ តែពួកគេមិនស្គាល់លោកទេ។ មិនតែប៉ុណ្ណោះ គេថែមទាំងបានធ្វើបាបលោកសព្វបែបយ៉ាងតាមអំពើចិត្តរបស់គេទៀត។ បុត្រមនុស្សក៏នឹងត្រូវគេ
ធ្វើបាបដូច្នោះដែរ»។ 13 ពេលនោះ ពួកសិស្សយល់ថា ព្រះអង្គមានព្រះបន្ទូលមកកាន់ពួកគេអំពីលោកយ៉ូហានបាទីស្ដ។ 14 កាលទ្រង់ និងពួកសិស្ស មកដល់
កន្លែងដែលបណ្ដាជននៅជុំគ្នា មានបុរសម្នាក់ចូលមកគាល់ព្រះអង្គ គាត់លុតជង្គង់ចុះ ទូលថា៖ 15 «លោកម្ចាស់អើយ! សូមអាណិតមេត្តាដល់កូនប្រុសរបស់
ខ្ញុំប្របាទផង គ្មាមានជំងឺឆ្កួតជ្រូក បណ្ដាលឲ្យឈឺចុកចាប់ខ្លាំងណាស់ ពេលខ្លះដួលទៅក្នុងភ្លើង និងធ្លាក់ទឹកជាញឹកញាប់។ 16 ខ្ញុំប្របាទបាននាំកូនប្រុសខ្ញុំមក
ជួបសិស្សរបស់លោកដែរ តែគេពុំអាចមើលកូនប្រុសខ្ញុំឲ្យជាបានទេ»។ 17 ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «នែ៎ ពួកមនុស្សដែលមិនព្រមជឿ
ហើយមានចិត្តវៀចវេរអើយ! តើត្រូវឲ្យខ្ញុំទ្រាំនៅជាមួយអ្នករាល់គ្នាដល់ពេលណាទៀត? តើត្រូវឲ្យខ្ញុំទ្រាំងនឹងអ្នករាល់គ្នាដល់កាលណា? ចូរនាំក្មេងនោះមកឲ្យ
ខ្ញុំ»។ 18 ព្រះយេស៊ូមានព្រះបន្ទូលគំរាមអារក្ស រួចអារក្សក៏ចេញ ហើយក្មេងនោះបានជាតាំងពីពេលនោះមក។ 19 បន្ទាប់មក ពួកសិស្សនាំគ្នាចូលមកគាល់
ព្រះយេស៊ូដាច់ឡែកពីគេ ហើយទូលសួរថា៖ «ហេតុអ្វីបានជាពួកយើងពុំអាចដេញអារក្សនោះបាន?» 20 ព្រះអង្គមានព្រះបន្ទូលតបទៅគេថា៖ «មកពីអ្នករាល់
គ្នាមានជំនឿតិចពេក។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យដឹងប្រាកដថា បើអ្នករាល់គ្នាមានជំនឿប៉ុនគ្រាប់ពូជដ៏ល្អិត អ្នករាល់គ្នាអាចបញ្ជាទៅភ្នំនោះថា៖ «ចូរចេញពីនេះ
ទៅនៅកន្លែងផ្សេងទៅ!«ភ្នំមុខជាធ្វើតាមពាក្យអ្នករាល់គ្នាជាមិនខាន ដ្បិតគ្មានការអ្វីដែលអ្នករាល់គ្នាធ្វើមិនកើតឡើយ។ 21 គេអាចដេញអារក្សប្រភេទនេះឲ្យ
ចេញបាន លុះត្រាតែអធិស្ឋាន និងតមអាហារ។ 22 កាលពួកគេនៅជុំគ្នាក្នុងស្រុកកាលីឡេ ព្រះយេស៊ូមានព្រះបន្ទូលទៅពួកសិស្សរបស់ព្រះអង្គថា៖ «បុត្រ
មនុស្សនឹងត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃរបស់មនុស្សលោក 23 ហើយគេនឹងសម្លាប់ព្រះអង្គ តែនៅថ្ងៃទីបីព្រះអង្គនឹងមានជីវិតរស់ឡើងវិញ»។ ឮដូច្នោះ ពួក
សិស្សព្រួយចិត្តជាខ្លាំង។ 24 ពេលព្រះអង្គ និងពួកសិស្សយាងមកដល់ក្រុងកាពើណិម មានបុរសម្នាក់ជាអ្នកយកពន្ធសម្រាប់ព្រះវិហារ នាំគ្នាចូលមករកលោក
ពេត្រុសហើយសួរថា៖ «តើលោកគ្រូរបស់អ្នកបង់ពន្ធសំរាប់ព្រះវិហារឬទេ?» 25 លោកតបវិញថា៖ «បាទ! លោកបង!» កាលពេត្រុសទៅដល់ផ្ទះ ព្រះយេស៊ូ
មានព្រះបន្ទូលទៅគាត់មុនថា៖ «ស៊ីម៉ូន! តាមយោបល់អ្នក ស្ដេចនៅផែនដីនេះយកពន្ធអាករពីនរណា? ពីបុត្ររបស់ស្ដេច ឬពីអ្នកផ្សេង?» 26
ពេលលោកពេត្រុសទូលថា៖ «ពីអ្នកផ្សេង»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «បើដូច្នេះ បុត្ររបស់ស្ដេចមិនត្រូវបង់ពន្ធឡើយ 27 ប៉ុន្តែ ដើម្បីកុំឲ្យអ្នក
ហូតពន្ធទាំងនោះទាស់ចិត្ត ចូរទៅស្ទូចត្រីសមុទ្រ ហើយយកត្រីដែលស្ទូចបានមុនគេមកបើកមាត់ អ្នកនឹងឃើញកាក់មួយ ចូរយកកាក់នោះទៅបង់ពន្ធឲ្យខ្ញុំ និង
ឲ្យអ្នកចុះ»។


generated on Thu Feb 8 15:37:30 2024

## ជំពូក 18

1 ពេលនោះ ពួកសិស្សបាននាំគ្នាចូលមកគាល់ព្រះយេស៊ូហើយទូលថា៖ «តើអ្នកណាមានឋានៈធំជាងគេនៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ?» 2 ព្រះយេស៊ូហៅ
ក្មេងតូចម្នាក់ឲ្យមកឈរនៅកណ្ដាលចំណោមពួកសិស្ស 3 ហើយមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា បើអ្នករាល់គ្នាមិនដូរចិត្តគំនិត ឲ្យ
ដូចជាក្មេងតូចៗទេ អ្នករាល់គ្នាមិនអាចចូលទៅក្នុងព្រះរាជ្យ នៃស្ថានបរមសុខបានឡើយ។ 4 ដូច្នេះបើអ្នកណាដាក់ខ្លួនដូចក្មេងតូចនេះ អ្នកនោះគឺមានឋានៈធំ
ជាងគេ ក្នុងព្រះរាជ្យនៃស្ថានបរមសុខ។ 5 អ្នកណាទទួលក្មេងតូចណាម្នាក់ដូចក្មេងនេះ ក្នុងនាមខ្ញុំ ក៏ដូចជាទទួលខ្ញុំដែរ។ 6 ប៉ុន្ដែអ្នកណាធ្វើឲ្យអ្នកតូចតាចម្នាក់
ក្នុងបណ្ដាអ្នកដែលជឿលើខ្ញុំនេះឲ្យប្រព្រឹត្ដអំពើបាប អ្នកនោះគួរតែយកត្បាល់ថ្មយ៉ាងធំមកចងកខ្លួនឯង ហើយទម្លាក់ខ្លួនទៅក្នុងបាតសមុទ្រឲ្យលង់
ទឹកស្លាប់ទៅនោះប្រសើរជាង! 7 មនុស្សលោកមុខជាត្រូវវេទនាមិនខាន ដ្បិតមានហេតុផ្សេងៗជាច្រើននាំឲ្យគេភ្លាត់ដួល។ ការផ្សេងៗ ដែលនាំឲ្យគេភ្លាត់ដួល
នោះ ត្រូវតែមានចៀសមិនផុតឡើយ ប៉ុន្ដែត្រូវវេទនាហើយអ្នកណាដែលភ្លាត់ដួលនោះ! 8 ប្រសិនបើដៃ ឬជើងរបស់អ្នក នាំអ្នកឲ្យភ្លាត់ដួលនោះ ចូរកាត់វាបោះ
ចោល ឲ្យឆ្ងាយពីអ្នកទៅ បើអ្នកមានតែដៃម្ខាង ឬជើងម្ខាងតែរួចជីវិត នោះប្រសើរជាងមានដៃពីរ ឬមានជើងពីរ ហើយត្រូវធ្លាក់ទៅក្នុងភ្លើងដែលឆេះអស់កល្ប
ជានិច្ច។ 9 ប្រសិនបើភ្នែករបស់អ្នក នាំអ្នកឲ្យភ្លាត់ដួល ចូរខ្វេះវាចេញ ហើយបោះចោលឲ្យឆ្ងាយពីអ្នកទៅ បើអ្នកមានតែភ្នែកម្ខាងតែរួចជីវិត នោះប្រសើរជាង
មានភ្នែកពីរ ហើយត្រូវធ្លាក់ទៅក្នុងភ្លើងនរក។ 10 កុំមើលងាយនរណាម្នាក់ក្នុងចំណោមអ្នកតូចតាចនេះឡើយ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថាទេវតារបស់ពួកគេស្ថិត
នៅឯស្ថានបរមសុខ តែងតែឃើញព្រះភក្ត្ររបស់ព្រះបិតា ដែលគង់នៅស្ថានបរមសុខគ្រប់ពេលវេលាផង 11 ដ្បិតបុត្រមនុស្សបានមកសង្គ្រោះមនុស្សដែល
វិនាសបាត់បង់។ 12 តើអ្នករាល់គ្នាយល់យ៉ាងណាដែរ? ប្រសិនបើបុរសម្នាក់មានចៀមមួយរយក្បាល ហើយចៀមមួយវង្វេងបាត់ តើគាត់មិនទុកចៀមកៅសិប
ប្រាំបួននៅលើភ្នំ ហើយទៅតាមរកចៀម ដែលវង្វេងបាត់នោះទេឬអី? 13 ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងប្រាកដថា បើគាត់រកចៀមនោះឃើញវិញហើយ គាត់
មុខតែត្រេកអរសប្បាយ គឺសប្បាយលើសពីឃើញចៀមកៅសិបប្រាំបួនដែលមិនវង្វេងបាត់ទៅទៀត។ 14 ដូច្នោះ រីឯព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថាន
បរមសុខ ទ្រង់មិនសព្វព្រះហឫទ័យឲ្យអ្នកណាម្នាក់ ក្នុងចំណោមអ្នកតូចតាចទាំងនេះ វិនាសបាត់បង់ឡើយ។ 15 ប្រសិនបើមានបងប្អូនណាបានប្រព្រឹត្តអំពើ
បាបទាស់នឹងអ្នក ចូរទៅជួបអ្នកនោះ ស្ងាត់ៗតែពីរនាក់ ហើយស្ដីប្រដៅគាត់ទៅ បើគាត់ស្ដាប់អ្នក អ្នកនឹងរក្សាបងប្អូននោះ 16 តែបើគាត់មិនព្រមស្ដាប់អ្នក
នោះទេ ចូរនាំម្នាក់ ឬពីរនាក់ទៀតទៅជាមួយ ដើម្បីបញ្ជាក់រឿងទាំងអស់ដោយមានសាក្សីពីរ ឬបីនាក់។ 17 ហើយប្រសិនបើគាត់ នៅតែមិនព្រមស្ដាប់ពាក្យអ្នក
ទាំងនោះ ត្រូវនាំរឿងនេះទៅប្រាប់ក្រុមជំនុំឲ្យដឹង បើគាត់នៅតែមិនព្រមស្ដាប់ក្រុមជំនុំទៀតនោះ ត្រូវចាត់ទុកគាត់ដូចជាសាសន៍ដទៃ ឬដូចជាអ្នកទារពន្ធចុះ។
18 ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាឲ្យដឹងប្រាកដថា អ្វីៗទាំងអស់ដែលអ្នករាល់គ្នាចងនៅលើផែនដីនេះ នឹងត្រូវចងនៅស្ថានបរមសុខដែរ ហើយអ្វីៗដែលអ្នករាល់គ្នា
ស្រាយនៅលើផែនដី ក៏នឹងត្រូវស្រាយនៅស្ថានបរមសុខដែរ។ 19 ខ្ញុំសុំប្រាប់អ្នករាល់គ្នាម្ដងទៀតថា ប្រសិនបើមានពីរនាក់នៅលើផែនដីនេះ រួមចិត្តគំនិតគ្នា
ទូលសូមអ្វីក៏ដោយ ព្រះបិតារបស់ខ្ញុំ ដែលគង់នៅស្ថានបរមសុខនឹងប្រទានឲ្យជាមិនខាន 20 ដ្បិតនៅទីណាមានពីរ ឬបីនាក់ជួបជុំគ្នាក្នុងនាមខ្ញុំ នោះខ្ញុំក៏ស្ថិត
នៅកណ្ដាលចំណោមគេដែរ»។ 21 បន្ទាប់មក លោកពេត្រុសចូលមកជិតព្រះយេស៊ូ ហើយទូលថា៖ «ព្រះអម្ចាស់ តើទូលបង្គំត្រូវអត់ទោសឲ្យបងប្អូន ដែលតែ
ប្រព្រឹត្តអំពើបាបមកលើទូលបង្គំប៉ុន្មានដង? រហូតដល់ប្រាំពីរដងឬ?»។ 22 ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំសុំប្រាប់អ្នកថា អ្នកមិនត្រូវអត់ទោសឲ្យគេ
ត្រឹមតែប្រាំពីរដងប៉ុណ្ណោះទេ គឺត្រូវអត់ទោសឲ្យគេចិតសិបដងប្រាំពីរដង។ 23 ហេតុនេះ ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបានទៅនឹងស្ដេចមួយអង្គ ដែលចង់
គិតបញ្ជីជាមួយអ្នកបម្រើ។ 24 ពេលដែលព្រះរាជាចាប់ផ្ដើមគិតបញ្ជី មានគេនាំកូនបំណុលម្នាក់ដែលជំពាក់ប្រាក់មួយមឺុនណែនមក។ 25 ប៉ុន្ដែដោយអ្នកនោះ
គ្មានប្រាក់បង់សង ស្ដេចក៏ចេញបញ្ជាឲ្យលក់ទាំងគាត់ ទាំងប្រពន្ធ ទាំងកូន ទាំងរបស់របរដែលគាត់មាន ដើម្បីយកប្រាក់មកសងបំណុល។ 26 អ្នកបម្រើនោះ
ក៏លុតជង្គង់ក្រាបទៀបព្រះបាទាស្ដេច ទាំងទូលអង្វរថា៖ «សូមទ្រង់មេត្ដាអត់ឱន ឲ្យទូលបង្គំផង ទូលបង្គំនឹងសងព្រះអង្គវិញគ្រប់ចំនួន»។ 27 ព្រះរាជាមាន
ព្រះហឫទ័យអាណិតអាសូរអ្នកបម្រើនោះពន់ពេកណាស់ ព្រះអង្គក៏ឲ្យគាត់ទៅវិញ ទាំងលុបបំណុលទាំងអស់ចោលថែមទៀតផង។ 28 ប៉ុន្ដែពេលអ្នក
បម្រើនោះចេញទៅ គាត់បានជួបនឹងអ្នកបម្រើម្នាក់ ដែលជំពាក់ប្រាក់គាត់មួយរយដួង គាត់ចាប់អ្នកនោះដាក់ច្របាច់កទាំងពោលថា៖ «សងប្រាក់អញទាំងអស់
មក!»។ 29 ប៉ុន្ដែអ្នកបម្រើរបស់អ្នកនោះក៏លុតជង្គង់ចុះអង្វរថា សុំអត់ឱនឲ្យខ្ញុំផង ខ្ញុំនឹងវិញគ្រប់ចំនួន។ 30 ប៉ុន្ដែ អ្នកបម្រើរូបនោះពុំព្រមទេ មិនតែប៉ុណ្ណោះ
គាត់ចាប់អ្នកជំពាក់ប្រាក់នោះយកទៅឃុំឃាំង រហូតទាល់តែបានសងបំណុលគ្រប់ចំនួន។ 31 ពេលអ្នកបម្រើឯទៀតៗឃើញដូច្នោះ ទាស់ចិត្តជាខ្លាំង គេយក
រឿងនេះទៅទូលស្ដេច។ 32 ស្ដេចក៏ហៅអ្នកបម្រើនោះមកសួរថា៖ «អ្នកបម្រើអាក្រក់អើយ! យើងបានលុបបំណុលឯងទាំងប៉ុន្មានចោលអស់ហើយ ព្រោះឯង
បានទទូចអង្វរយើង។ 33 ហេតុដូចម្ដេចបានជាឯងពុំព្រមអាណិតមេត្ដាដល់អ្នកបម្រើរបស់ឯង ដូចជាយើងបានអាណិតមេត្ដាដល់ឯងដែរ?»។ 34 ស្ដេចទ្រង់
ខ្ញាល់ក្រៃលែង ហើយក៏បញ្ជាឲ្យគេយកអ្នកនោះទៅធ្វើទារុណកម្ម រហូតទាល់តែសងបំណុលគ្រប់ចំនួន។ 35 ព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខ ក៏នឹង
ធ្វើទារុណកម្មអ្នករាល់គ្នាដូច្នោះដែរ ចំពោះអ្នកណាដែលមិនព្រមលើកលែងទោសឲ្យបងប្អូនដោយស្មោះអស់ពីចិត្តនោះ។


generated on Thu Feb 8 15:37:30 2024

## ជំពូក 19

1 ក្រោយព្រះយេស៊ូមានព្រះបន្ទូលទាំងនេះចប់សព្វគ្រប់ហើយ ព្រះអង្គក៏យាងចាកចេញពីស្រុកកាលីឡេ ឆ្ពោះទៅត្រើយខាងនាយទន្លេយ័រដាន់ ក្នុងស្រុក
យូដា។ 2 មហាជនយ៉ាងច្រើនកុះករនាំគ្នាមកតាមព្រះអង្គ ហើយព្រះអង្គក៏ប្រោសអ្នកជំងឺឲ្យបានជានៅទីនោះដែរ។ 3 ពួកខាងគណៈផារីស៊ីបានចូលមកជិត
ហើយទូលសួរក្នុងគោលបំណងល្បងលមើលព្រះអង្គថា៖ «តើស្វាមីមានសិទ្ធិនឹងលែងភរិយា ដោយសំអាងលើមូលហេតុអ្វីមួយបានឬទេ?»។ 4 ព្រះយេស៊ូមាន
ព្រះបន្ទូលតបថា៖ «តើអ្នករាល់គ្នាមិនដែលធ្លាប់អានគម្ពីរទេឬអី កាលដើមដំបូងព្រះជាម្ចាស់ បានបង្កើតមនុស្សមក ជាបុរស ជាស្ត្រី? 5 ព្រះអង្គមានព្រះបន្ទូល
ថា ហេតុនេះហើយបានជាបុរសត្រូវចាកចេញពីឪពុកម្ដាយ ទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយអ្នកទាំងពីរនឹងត្រឡប់ទៅជារូបកាយតែមួយ។ 6 គេមិនមែន
មនុស្សពីរនាក់ទៀតទេ គឺជារូបកាយតែមួយវិញ។ ដូច្នេះ អ្វីដែលព្រះជាម្ចាស់បានផ្សំផ្គុំឡើយ មនុស្សមិនត្រូវបំបាក់បំបែកគេឡើយ។ 7 ពួកគេទូលសួរព្រះអង្គថា៖
«ចុះតើហេតុដូចម្ដេចបានជាម៉ូសេបញ្ជាឲ្យស្វាមីធ្វើលិខិតលែងលះភរិយា ហើយឲ្យនាងចាកចេញទៅ?» 8 ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «ម៉ូសេអនុញ្ញាត
ឲ្យអ្នករាល់គ្នាលែងភរិយាបាន ព្រោះអ្នករាល់គ្នាមានចិត្តរឹងរូសពេក តែកាលដើមឡើយមិនមែនដូច្នោះទេ។ 9 ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា បុរសណាលែងភរិយា
(លើកលែងតែរួមរស់ជាមួយគ្នា ដោយឥតបានរៀបការ) ហើយទៅរៀបការនឹងស្ត្រីម្នាក់ទៀត បុរសនោះឯងជាអ្នកប្រព្រឹត្តអំពើផិតក្បត់។ 10 ពួកសិស្សនាំគ្នាទូល
ព្រះអង្គថា៖ «បើមានលក្ខខណ្ឌរវាងប្ដីប្រពន្ធបែបនេះ គួរកុំរៀបការប្រសើរជាង»។ 11 ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលទៅគេវិញថា៖ «មិនមែនមនុស្សគ្រប់រូប
អាចយល់សេចក្ដីនេះបានឡើយ ប៉ុន្តែមានតែអ្នកដែលព្រះជាម្ចាស់ប្រោសប្រទានឲ្យយល់ប៉ុណ្ណោះទេ ទើបអាចយល់បាន។ 12 គឺមានអ្នកខ្លះមិនអាចរៀបការ
បានតាំងពីកំណើតមក ហើយអ្នកខ្លះទៀតមិនអាចរៀបការបានមកពីត្រូវគេក្រៀវ រីឯអ្នកខ្លះទៀតមិនរៀបការមកពីយល់ដល់ព្រះរាជ្យនៃស្ថានបរមសុខ អ្នកណា
ដែលអាចទទួលយកការបង្រៀននេះបាន ចូរយកទៅរិះគិតចុះ»។ 13 មានក្មេងតូចៗមកឯព្រះអង្គ ដើម្បីទ្រង់ដាក់ព្រះហស្តលើ និងអធិស្ឋានឲ្យ។ ប៉ុន្តែពួកសិស្ស
ស្តីបន្ទោសអ្នកទាំងនោះ 14 តែព្រះយេស៊ូមានព្រះបន្ទូលថា៖ «ទុកឲ្យក្មេងតូចៗទាំងនេះមករកខ្ញុំចុះ កុំឃាត់ពួកគេឡើយ ដ្បិតមានតែអ្នកមានចិត្តដូចក្មេងៗទាំង
នេះប៉ុណ្ណោះ គឺអាចចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខបាន»។ 15 ព្រះអង្គដាក់ព្រះហស្តលើក្មេងទាំងនោះ រួចទ្រង់យាងចាកចេញពីទីនោះទៅ។ 16 មាន
បុរសម្នាក់ចូលមកគាល់ព្រះយេស៊ូ ហើយទូលថា៖ «លោកគ្រូ! តើខ្ញុំត្រូវប្រព្រឹត្តអំពើល្អអ្វីខ្លះទៅ ដើម្បីឲ្យមានជីវិតអស់កល្បជានិច្ច?» 17 ព្រះយេស៊ូមាន
ព្រះបន្ទូលទៅគាត់ថា៖ «តើហេតុដូចម្ដេចបានជាអ្នកសួរខ្ញុំអំពីអ្វីដែលជាការល្អដូច្នេះ? មានតែព្រះជាម្ចាស់មួយប៉ុណ្ណោះដែលល្អសប្បុរស បើអ្នកចង់
មានជីវិតអស់កល្ប ត្រូវប្រតិបត្តិតាមបទបញ្ជាទៅ»។ 18 បុរសនោះក៏ទូលសួរព្រះអង្គថា៖ «តើបទបញ្ជាមួយណា? ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា៖ កុំសម្លាប់
មនុស្ស កុំប្រព្រឹត្តអំពើផិតក្បត់ កុំលួច កុំធ្វើជាសាក្សីក្លែងក្លាយ 19 ចូរគោរពមាតាបិតា ហើយត្រូវស្រឡាញ់បងប្អូនឯទៀតៗឲ្យបានដូចស្រឡាញ់ខ្លួនឯងដែរ»។
20 បុរសវ័យក្មេងនោះទូលព្រះអង្គថា៖ «ខ្ញុំបានប្រតិបត្តិតាមបទបញ្ជាទាំងនេះហើយ តើនៅមានអ្វីទៀតដែលខ្ញុំត្រូវធ្វើ?។ 21 ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់
ថា៖ បើអ្នកចង់បានល្អឥតខ្ចោះនោះ ចូរទៅលក់ទ្រព្យសម្បត្តិរបស់អ្នកទាំងប៉ុន្មានដែលមាន ហើយចែកឲ្យអ្នកក្រីក្រទៅ នោះទើបអ្នកបានសម្បត្តិសួគ៌ រួចសឹមមក
តាមខ្ញុំចុះ»។ 22 កាលបុរសវ័យក្មេងនោះឮព្រះយេស៊ូមានព្រះបន្ទូលដូច្នេះ គាត់ត្រឡប់ទៅវិញទាំងព្រួយចិត្ត ដ្បិតគាត់មានទ្រព្យសម្បត្តិច្រើនណាស់។ 23
ព្រះយេស៊ូមានព្រះបន្ទូលទៅពួកសិស្សថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា ពួកអ្នកមានពិបាកចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខណាស់។ 24 ខ្ញុំសុំ
ប្រាប់អ្នករាល់គ្នាម្ដងទៀតថា ដែលឲ្យសត្វអូដ្ឋចូលតាមប្រហោងម្ជុល គឺងាយជាងឲ្យអ្នកមានចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខទៀត»។ 25 កាលពួកសិស្ស
ឮដូច្នោះ គេងឿងឆ្ងល់យ៉ាងខ្លាំង ហើយពោលថា៖ «បើដូច្នេះ តើអ្នកណានឹងអាចទទួលការសង្គ្រោះទៅ?» 26 ព្រះយេស៊ូទតមើលទៅពួកគេ រួចមានព្រះបន្ទូល
ថា៖ «ការនេះមនុស្សធ្វើពុំបានទេ តែងព្រះជាម្ចាស់វិញ អ្វីក៏ដោយព្រះអង្គធ្វើបានទាំងអស់»។ 27 បន្ទាប់មក ពេត្រុសទូលព្រះអង្គថា៖ «យើងខ្ញុំបានលះបង់អ្វីៗ
ទាំងអស់ ដើម្បីមកតាមព្រះអង្គ តើយើងខ្ញុំនឹងទទួលបានអ្វីទៅ?» 28 ព្រះយេស៊ូមានព្រះបន្ទូលទៅពួកសិស្សថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា នៅ
ក្នុងជីវិតថ្មីនេះ ពេលបុត្រមនុស្សគង់លើបល្ល័ង្កប្រកបដោយសិរីរុងរឿង អ្នករាល់គ្នាដែលមកតាមខ្ញុំនោះ ក៏នឹងអង្គុយលើបល្ល័ង្កទាំងដប់ពីរ ដែលនឹងវិនិច្ឆ័យ
កុលសម្ព័ន្ធទាំងដប់ពីរនៃជនជាតិអ៊ីស្រាអែលផងដែរ។ 29 អ្នកណាលះបង់ផ្ទះសំបែង បងប្អូនប្រុសស្រី ឪពុកម្ដាយ កូន ឬស្រែចម្ការ ដោយព្រោះតែខ្ញុំ អ្នកនោះ
នឹងបានទទួលវិញមួយជាមួយរយ ព្រមទាំងមានជីវិតអស់កល្បជានិច្ច។ 30 មានមនុស្សជាច្រើនដែលនៅខាងមុខ នឹងត្រឡប់ទៅនៅខាងក្រោយវិញ រីឯអ្នក
ដែលនៅក្រោយ នឹងត្រឡប់ទៅនៅមុខវិញ។


generated on Thu Feb 8 15:37:30 2024

## ជំពូក 20

1 ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបបានទៅនិងម្ចាស់ចម្ការម្នាក់ ដែលចាកចេញពីផ្ទះតាំងពីព្រលឹម ទៅរកជួលកម្មករមកធ្វើការនៅក្នុងចម្ការទំពាំងបាយជូររបស់
ខ្លួន។ 2 ក្រោយគាត់ព្រមព្រៀងជាមួយនិងកម្មករថា នឹងឲ្យប្រាក់មួយដួងក្នុងមួយថ្ងៃហើយ ក៏ចាត់ពួកគេឲ្យទៅធ្វើការក្នុងចម្ការរបស់គាត់ទៅ។ 3 ប្រមាណជា
ម៉ោងប្រាំបួនព្រឹក គាត់ចេញទៅម្តងទៀតហើយក៏ឃើញអ្នកផ្សេងទៀតកំពុងតែឈរនៅតាមទីផ្សារ។ 4 គាត់ក៏និយាយទៅកាន់ពួកគេថា៖ «ចូរអ្នករាល់គ្នាទៅធ្វើ
ការនៅឯចម្ការខ្ញុំដែរទៅ ខ្ញុំនឹងឲ្យប្រាក់ឈ្នួលត្រឹមត្រូវដល់អ្នក អ្នកទាំងនោះក៏នាំគ្នាទៅធ្វើការនៅចម្ការរបស់គាត់។ 5 ម្ចាស់ចំការក៏ចេញទៅសារជាថ្មីទៀតនៅ
ម៉ោងដប់ពីរ និងម៉ោងបីរសៀល ហើយជួលអ្នកផ្សេងតាមរបៀបដដែល។ 6 ប្រហែលជាម៉ោងប្រាំល្ងាចគាត់ក៏ចេញទៅសាជាថ្មីម្តងទៀត ហើយឃើញអ្នកខ្លះ
ទៀតឈរនៅតាមទីផ្សារ គាត់ក៏សួរពួកគេថា ហេតុអ្វីបានជាអ្នករាល់គ្នាឈរនៅទីនេះ មួយថ្ងៃវាល់ល្ងាច ឥតធ្វើអ្វីសោះដូច្នេះ 7 ពួកគេឆ្លើយថា មកពីគ្មាននរណា
ជួលយើងខ្ញុំឲ្យធ្វើការនោះទេ! គាត់ក៏ពោលទៅពួកអ្នកទាំងនោះថា ចូរអ្នករាល់គ្នាទៅធ្វើការនៅចម្ការខ្ញុំដែរទៅ។ 8 លុះដល់ពេលល្ងាច ម្ចាស់ចម្ការបានប្រាប់ទៅ
អ្នកកាន់ប្រាក់ថា ចូរហៅពួកកម្មករមក ហើយបើកប្រាក់ឲ្យពួកគេទៅ គឺចាប់ផ្តើមពីអ្នកដែលធ្វើការក្រោយគេបង្អស់ រហូតដល់អ្នកមកមុនគេបង្អស់។ 9 ពេលពួក
អ្នកដែលបានចាប់ផ្តើមធ្វើការម៉ោងប្រាំល្ងាចមកដល់ ទទួលប្រាក់ម្នាក់មួយដួងៗ។ 10 ហើយពួកអ្នកដែលចាប់ផ្តើមធ្វើការមុនគេ ក៏មកដល់ដែរពួកគេគិតថា នឹង
បានប្រាក់ច្រើនជាងអ្នកផ្សេង ប៉ុន្តែ ពួកគេទទួលម្នាក់ត្រឹមតែមួយដួងដូចៗគ្នា។ 11 ពេលគេទទួលយកប្រាក់ឈ្នួល ហើយពួកគេរក៏អ៊ូរទាំដាក់ម្ចាស់ចំការ 12
ដោយនិយាយថា ពួកអ្នកដែលមកក្រោយនេះ បានធ្វើការតែមួយម៉ោងប៉ុណ្ណោះ តែលោកបែរជាបើកប្រាក់ឲ្យគេស្មើនឹងយើងខ្ញុំ ដែលធ្វើការហាលថ្ងៃហាលក្តៅ។
13 ប៉ុន្តែ ម្ចាស់ចម្ការនិយាយទៅកាន់ម្នាក់ក្នុងចំណោមកម្មករទាំងនោះថា៖ «សម្លាញ់អើយ! ខ្ញុំមិនបានបោកបញ្ឆោតអ្នកទេ។ តើអ្នកមិនបានយល់ព្រមធ្វើការឲ្យ
ខ្ញុំក្នុងតម្លៃមួយដួងក្នុងមួយថ្ងៃ មែនទេ?» 14 ចូរយកប្រាក់ឈ្នួលរបស់អ្នកហើយចេញទៅចុះ! ខ្ញុំចង់ឲ្យអ្នកដែលមកដល់ក្រោយ ទទួលប្រាក់ស្មើនឹងអ្នកដែរ។ 15
តើខ្ញុំគ្មានសិទ្ធិនឹងយកប្រាក់របស់ខ្លួន ទៅធ្វើអ្វីតាមបំណងចិត្តខ្ញុំទេឬអី? ឬក៏អ្នកមានចិត្តច្រណែន ព្រោះតែខ្ញុំមានចិត្តសប្បុរស? 16 ហេតុនេះ អ្នកដែលនៅ
ក្រោយនឹងត្រឡប់ទៅជាមុន រីឯអ្នកដែលមុននោះ នឹងត្រឡប់ទៅខាងក្រោយវិញ។ 17 កាលព្រះយេស៊ូកំពុងយាងឡើងទៅក្រុងយេរូសាឡឹម ទ្រង់ក៏នាំ
សិស្សទាំងដប់ពីររូប ចេញដាច់ឡែកពីគេ ហើយព្រះអង្គមានព្រះបន្ទូលទៅគេនៅតាមផ្លូវថា៖ 18 «មើល! យើងកំពុងឡើងទៅក្រុងយេរូសាឡឹម ហើយបុត្រ
មនុស្សនឹងត្រូវគេបញ្ជូនទៅក្នុងកណ្តាប់ដៃរបស់ពួកនាយកបូជាចារ្យ និងពួកអាចារ្យ។ ពួកគេនឹងកាត់ទោសប្រហារជីវិតលោក។ 19 ហើយគេនឹងបញ្ជូនលោក
ទៅក្នុងកណ្តាប់ដៃរបស់សាសន៍ដទៃ ឲ្យពួកនោះចំអកដាក់លោក យករំពាត់វាយលោក ព្រមទាំងឆ្កាងសម្លាប់លោកថែមទៀតផង ប៉ុន្តែ បីថ្ងៃក្រោយមកលោក
នឹងរស់ឡើងវិញ»។ 20 ពេលនោះ ភរិយារបស់លោកសេបេដេ បាននាំកូនទាំងពីរចូលមករកព្រះយេស៊ូ គាត់ក្រាបទៀបព្រះបាទារបស់ព្រះអង្គចង់ទូលសុំអ្វី
មួយ។ 21 ព្រះអង្គមានព្រះបន្ទូលសួរគាត់ថា៖ «តើអ្នកចង់បានអ្វី?» គាត់ទូលព្រះអង្គវិញថា៖ «សូមឲ្យកូនរបស់ខ្ញុំម្ចាស់បានអង្គុយអមនិងព្រះអង្គផង គឺម្នាក់
នៅខាងស្តាំ និងម្នាក់ទៀតនៅខាងឆ្វេងដៃរបស់ព្រះអង្គផង នៅពេលព្រះអង្គគ្រងរាជ្យ» ។ 22 ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «អ្នកមិនដឹងថាខ្លួនកំពុង
សុំអ្វីនោះឡើយ តើអ្នកទាំងពីរអាចទទួលពែង ដែលខ្ញុំត្រូវទទួលនោះបានឬទេ?» យ៉ាកុប និងយ៉ូហានទូលថា៖ «យើងខ្ញុំអាចទទួលបាន»។ 23 ព្រះអង្គមាន
ព្រះបន្ទូលទៅអ្នកទាំងពីរថា៖ «អ្នកនឹងទទួលពែងរបស់ខ្ញុំបានមែន តែការអង្គុយនៅខាងស្តាំ ឬនៅខាងឆ្វេងដៃរបស់ខ្ញុំនោះ ខ្ញុំមិនអាចសម្រេចអោយបានឡើយ
ព្រោះកន្លែងនោះបម្រុងទុកសម្រាប់តែអស់អ្នកដែលព្រះបិតារបស់ខ្ញុំ បានសំរេចអោយតែប៉ុណ្ណោះ»។ 24 កាលសិស្សដប់រូបទៀតបានឮដូច្នោះ គេក៏ខឹងនិងបង
ប្អូនទាំងពីរនាក់នេះខ្លាំងណាស់។ 25 ប៉ុន្តែ ព្រះយេស៊ូត្រាស់ហៅសិស្សទាំងអស់មក ហើយមានព្រះបន្ទូលថា៖ «អ្នករាល់គ្នាដឹងស្រាប់ហើយថា ពួកអ្នកគ្រប់គ្រង
សាសន៍ដ៏ទៃតែងតែជិះជាន់ប្រជារាស្ត្ររបស់ខ្លួន រីឯអ្នកធំក៏តែងតែប្រើអំណាចលើប្រជារាស្ត្ររបស់ខ្លួនដែរ។ 26 ប៉ុន្តែ ក្នុងចំណោមអ្នករាល់គ្នា មិនមែនដូច្នោះ
ទេផ្ទុយទៅវិញ បើមានអ្នកណាចង់ធ្វើធំជាងគេក្នុងចំណោមអ្នករាល់គ្នា ត្រូវឲ្យអ្នកនោះបម្រើអ្នករាល់គ្នាវិញ។ 27 ហើយបើមានអ្នកណាចង់ធ្វើមេគេក្នុងចំណោម
អ្នករាល់គ្នា អ្នកនោះត្រូវធ្វើជាអ្នកបម្រើដល់អ្នករាល់គ្នាសិន។ 28 ដូចគ្នាដែលបុត្រមនុស្សមកក្នុងពិភពលោកនេះ មិនមែនដើម្បីឲ្យមនុស្សបម្រើលោកនោះទេ
ប៉ុន្តែលោកមកបម្រើគ្រប់គ្នាវិញ ហើយព្រមទាំងបូជាជីវិត ដើម្បីលោះមនុស្សទាំងអស់ផង»។ 29 ពេលព្រះយេស៊ូ និងពួកសិស្សយាងចេញពីក្រុងយេរីខូ មាន
បណ្តាជនច្រើនកុះករនាំគ្នាដើរតាមព្រះអង្គ 30 មានមនុស្សខ្វាក់ពីរនាក់អង្គុយនៅក្បែរផ្លូវ ក្រោយអ្នកទាំងពីរឮថា ព្រះយេស៊ូយាងមក ក៏ស្រែកឡើងថា៖ «ឱ
ព្រះអម្ចាស់ ជាព្រះរាជវង្សព្រះបាទដាវីឌអើយ! សូមអាណិតមេត្តាយើងខ្ញុំផង»។ 31 បណ្តាជនស្តីបន្ទោសដល់អ្នកទាំងពីរឲ្យនៅស្ងៀម ប៉ុន្តែគេស្រែករឹតតែខ្លាំង
ឡើងថា៖ «ឱព្រះអម្ចាស់ ជាព្រះរាជវង្សព្រះបាទដាវីឌអើយ! សូមអាណិតមេត្តាដល់យើងខ្ញុំផង»។ 32 បន្ទាប់មកព្រះយេស៊ូក៏ឈប់ហើយនៅស្ងៀម ដោយហៅ
ពួកគេមកសួរថា៖ «តើអ្នកចង់ឲ្យខ្ញុំធ្វើអ្វីសម្រាប់អ្នក?» 33 គេទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! សូមប្រោសឲ្យភ្នែកយើងខ្ញុំបានភ្លឺផង»។ 34 ព្រះយេស៊ូមាន
ព្រះហឫទ័យអាណិតអាសូរដល់អ្នកទាំងពីរនោះយ៉ាងពន់ពេក ព្រះអង្គក៏ពាល់ភ្នែកគេភ្លាមនោះពួកគេក៏មើលឃើញ ហើយនាំគ្នាដើរតាមព្រះយេស៊ូទៅ។

## ជំពូក 21

1 កាលព្រះយេស៊ូ និងពួកសិស្សរបស់ព្រះអង្គយាងមកជិតដល់ក្រុងយេរូសាឡឹម ហើយកាលមកដល់ភូមិបេតផាសេ ដែលនៅភ្នំដើមអូលីវ ព្រះអង្គចាត់សិស្ស
ពីរនាក់ឲ្យទៅ 2 ទាំងមានព្រះបន្ទូលថា៖ «ចូរទៅភូមិដែលនៅមុខអ្នករាល់គ្នា ពេលទៅដល់ភ្លាម អ្នកនឹងឃើញមេលាមួយដែលគេចងនៅទីនោះ ហើយមានកូន
វានៅជាមួយដែរ។ ចូរស្រាយវាហើយដឹកមករកខ្ញុំ។ 3 ប្រសិនបើមាននរណាសួរអ្នក ចូរប្រាប់គេថា ព្រះអម្ចាស់ត្រូវការវា ហើយគេដឹកវាមកវិញភ្លាមជាមិន
ខាន»។ 4 ការណ៍នេះកើតឡើង ឲ្យស្របនឹងសេចក្ដីដែលបានចែងទុកតាមរយៈព្យាការីថា៖ 5 ចូរប្រាប់កូនស្រីក្រុងស៊ីយ៉ូនថា៖ «មើលហ្ន៎ ព្រះមហាក្សត្ររបស់
អ្នកយាងមករកអ្នកហើយ ព្រះអង្គមានព្រះហឫទ័យស្លូតបូត ទ្រង់សុភាព គង់លើខ្នងលា ហើយគង់លើខ្នងកូនលាផងដែរ»។ 6 បន្ទាប់មកសិស្សទាំងពីរនាំគ្នា
ចេញទៅ ធ្វើតាមបញ្ជារបស់ព្រះយេស៊ូុ។ 7 គេដឹកមេលា និងកូនវាមក ហើយគេយកអាវក្រាលពីលើខ្នងលា និងលើខ្នងកូនលាផង ហើយព្រះយេស៊ូឡើងគង់
លើខ្នងវានោះ។ 8 មានបណ្ដាជនជាច្រើននាំគ្នាយកអាវរបស់ខ្លួនក្រាលតាមផ្លូវ ហើយអ្នកខ្លះ ទៀតកាច់មែកឈើយកមកក្រាលលើផ្លូវដែរ។ 9 បន្ទាប់មក
មហាជនដែលដើរហែហមព្រះយេស៊ូ ពីមុខពីក្រោយនាំគ្នាស្រែកឡើងថា៖ «ហូសាណាថ្វាយព្រះរាជវង្សរបស់ព្រះបាទដាវីឌ! សូមព្រះជាម្ចាស់ប្រទានពរដល់
ព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់! ហូសាណាថ្វាយព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត»។ 10 កាលព្រះយេស៊ូយាងទៅដល់ក្រុងយេរូសាឡឹម
ហើយ នៅក្នុងទីក្រុងទាំងមូល នាំគ្នាជ្រួលច្របល់សួរថា៖ «តើលោកនោះជានរណា?» 11 មហាជនឆ្លើយថា៖ «លោកជាយេស៊ូ ដែលជាព្យាការី មកពីភូមិ
ណាសារ៉ែតក្នុងស្រុកកាលីឡេ»។ 12 បន្ទាប់មក ព្រះយេស៊ូយាងចូលក្នុងព្រះវិហារ ហើយព្រះអង្គដេញអ្នកលក់ដូរចេញពីទីនោះ ហើយទ្រង់ផ្ដួលតុអ្នកដូរប្រាក់
ផ្ដួលកៅអីរបស់អ្នកលក់ព្រាប។ 13 ព្រះអង្គមានព្រះបន្ទូលទៅពួកគេថា៖ «ក្នុងគម្ពីរបានចែងថា ដំណាក់របស់យើងត្រូវធ្វើជាកន្លែងសម្រាប់អធិស្ឋាន តែអ្នក
រាល់គ្នាបែរជាយកធ្វើជាសំបុកចោរទៅវិញ»។ 14 បន្ទាប់មកមានមនុស្សខ្វាក់ និងមនុស្សខ្វិន នាំគ្នាមករកព្រះអង្គនៅក្នុងព្រះវិហារ ហើយព្រះអង្គក៏ប្រោសពួកគេ
ឲ្យបានជា។ 15 ប៉ុន្តែ កាលពួកនាយកបូជាចារ្យ និងពួកអាចារ្យឃើញការអស្ចារ្យដែលព្រះអង្គបានធ្វើ ហើយឮក្មេងៗស្រែកនៅក្នុងព្រះវិហារថា៖
«ហូសាណាថ្វាយព្រះរាជវង្សព្រះបាទដាវីឌ! ពួកគេបានខឹងយ៉ាងខ្លាំង» 16 ពួកគេទូលព្រះអង្គថា៖ «តើលោកឮមនុស្សទាំងនោះស្រែកថាដូចម្ដេចទេ?»
ព្រះយេស៊ូមានព្រះបន្ទូលទៅពួកគេវិញថា៖ «ខ្ញុំឮហើយ! តើអ្នកមិនដែលដឹងទេថា គឺព្រះអង្គនឹងធ្វើឲ្យពាក្យសរសើរតម្កើង ហូរចេញពីបបូរមាត់ក្មេងតូចៗ និង
ទារកដែលនៅបៅ?» 17 បន្ទាប់មកព្រះយេស៊ូយាងចេញពីគេ ហើយទ្រង់យាងចេញពីទីក្រុងឆ្ពោះទៅភូមិបេថានី ហើយក៏ស្នាក់នៅទីនោះ។ 18 ព្រលឹមឡើង
ទ្រង់យាងត្រឡប់ទៅទីក្រុងវិញ ពេលនោះ ព្រះអង្គឃ្លាន។ 19 ព្រះអង្គទតឃើញឧទុម្ពរមួយដើមនៅតាមផ្លូវ ទ្រង់យាងចូលទៅជិត ហើយមិនឃើញមានផ្លែសោះ
មានសុទ្ធតែស្លឹក ទ្រង់មានព្រះបន្ទូលទៅកាន់ដើមឧទុម្ពរនោះថា៖ «ឯងនឹងមិនដែលបង្កើតផ្លែទៀតឡើយ»។ ពេលនោះ ស្រាប់តែដើមឧទុម្ពរក្រៀមស្វិតជាមួយ
រំពេច។ 20 ពេលពួកសិស្សឃើញដូច្នោះ គេងឿងឆ្ងល់ជាខ្លាំងពួកគេពោលថា៖ «ហេតុដូចម្ដេចបានជាដើមឧទុម្ពរក្រៀមស្វិតមួយរំពេចដូច្នេះ?» 21 ព្រះយេស៊ូ
មានព្រះបន្ទូលឆ្លើយទៅគេថា៖ «ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យដឹងប្រាកដថា ប្រសិនបើអ្នករាល់គ្នាមានជំនឿដោយឥតសង្ស័យនោះ អ្នករាល់គ្នាមិនត្រឹមតែអាចធ្វើ
ឲ្យដើមឧទុម្ពរនេះក្រៀមស្វិតប៉ុណ្ណោះទេ គឺអ្នករាល់គ្នាអាចនិយាយទៅកាន់ភ្នំនេះថា៖ ចូរចេញពីទីនេះ ធ្លាក់ក្នុងសមុទ្រទៅ! នោះនឹងសំរេចដូច្នោះជាមិនខាន។
22 អ្វីក៏ដោយអោយតែអ្នករាល់គ្នាអធិស្ឋានសុំដោយមានជំនឿ អ្នករាល់គ្នាមុខជាបានទទួលបានជាមិនខាន»។ 23 ពេលព្រះយេស៊ូយាងចូលក្នុងព្រះវិហារ
ហើយនៅពេលព្រះអង្គកំពុងតែបង្រៀន ពួកនាយកបូជាចារ្យ និងពួកព្រឹទ្ធាចារ្យរបស់ប្រជាជននាំគ្នាចូលមកសួរព្រះអង្គថា៖ «តើលោកធ្វើការទាំងនេះដោយអាង
អំណាចអ្វី? អ្នកណាប្រគល់អំណាចនេះឲ្យលោក?» 24 ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ ខ្ញុំក៏សុំសួរសំណួរមួយដល់អ្នកដែល បើអស់លោកប្រាប់ខ្ញុំបាន នោះខ្ញុំ
នឹងប្រាប់អស់លោកវិញនូវ អំណាចអ្វីដែលខ្ញុំធ្វើការទាំងនេះបាន។ 25 អំពីពិធីជ្រមុជទឹករបស់លោកយ៉ូហាន តើកើតឡើងពីណាមក? មកពីស្ថានសួគ៌ ឬពី
មនុស្ស? ពួកគេពិគ្រោះគ្នាពីការនេះ៖ «បើយើងនិយាយថា មកពីស្ថានសួគ៌ គាត់មុខជាសួរយើងថា ហេតុអ្វីបានជាអ្នករាល់គ្នាមិនជឿលោកយ៉ូហាន»។ 26 ប៉ុន្តែ
បើយើងឆ្លើយថា មកពីមនុស្សនោះយើងខ្លាចប្រជាជនរករឿង ដ្បិតមនុស្សគ្រប់ៗគ្នាចាត់ទុកលោកយ៉ូហានជាព្យាការីមួយរូបដែរ»។ 27 ដូច្នេះ ពួកគេឆ្លើយទៅ
ព្រះយេស៊ូថា៖ «យើងមិនដឹងទេ»។ ព្រះអង្គក៏មានព្រះបន្ទូលគេទៅវិញថា៖ «រីឯខ្ញុំវិញ ខ្ញុំក៏មិនប្រាប់អស់លោកថា ខ្ញុំធ្វើការទាំងនេះដោយអាងលើអំណាចអ្វី
ដែរ។ 28 តើអ្នករាល់គ្នាយល់យ៉ាងណាដែរ? បុរសម្នាក់មានកូនប្រុសពីរ គាត់និយាយទៅកាន់កូនច្បងថា៖ «កូនអើយ! ថ្ងៃនេះ ចូរកូនទៅធ្វើការ នៅចំការ
ទំពាំងបាយជូរទៅ»។ 29 កូនតបមកវិញថា៖ «ខ្ញុំមិនចង់ទៅទេ! ប៉ុន្តែ ក្រោយមក កូននោះក៏ដូរគំនិត ហើយក៏ទៅចំការវិញ។ 30 បន្ទាប់មក ឪពុកនិយាយពាក្យ
ដដែលទៅកាន់កូនពៅ តែកូនពៅឆ្លើយថា៖ «បាទ! កូននឹងទៅ»។ តែកូនពៅអត់ទៅទេ។ 31 តើក្នុងចំណោមកូនទាំងពីរនាក់នេះ មួយណាបានធ្វើតាមបំណង
ឪពុក? ពួកគេទូលព្រះអង្គថា៖ «កូនច្បង»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា ពួកអ្នកទារពន្ធ និងពួកស្ត្រីពេស្យា នឹង
ចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ មុនអ្នករាល់គ្នា។ 32 ដ្បិតលោកយ៉ូហានបានមកណែនាំអ្នករាល់គ្នាឲ្យដើរតាមផ្លូវសុចរិត តែអ្នករាល់គ្នាមិនព្រមជឿលោក
ទេ តែពួកអ្នកទារពន្ធ និងស្ត្រីពេស្យាបានជឿលោក រីឯអ្នករាល់គ្នាវិញ ទោះបីអ្នករាល់គ្នាបានឃើញហេតុការណ៍ទាំងនោះក្ដី ក៏អ្នករាល់គ្នាមិនបានដូរចិត្តគំនិត
ហើយជឿលោកដែរ។ 33 សុំស្ដាប់ប្រស្នាមួយទៀត គឺមានបុរសម្នាក់ជាម្ចាស់ចម្ការ គាត់បានដាំទំពាំងបាយជូរ រួចធ្វើរបងព័ទ្ធជុំវិញ គាត់រៀបចំកន្លែងមួយ ដើម្បី
បញ្ជាន់ផ្លែទំពាំងបាយជូរ ព្រមទាំងសង់ខ្ទមមួយផងហើយគាត់ក៏ប្រវាស់ឲ្យទៅពួកកសិករមើលថែទាំ រួចចេញដំណើរទៅស្រុកផ្សេងបាត់ទៅ។ 34 លុះដល់ពេល
រដូវទំពាំងបាយជូរទុំ គាត់ក៏ចាត់ពួកអ្នកបម្រើឲ្យមកជួបអ្នកថែចម្ការទាំងនោះ ដើម្បីទទួលយកផលរបស់គាត់។ 35 ប៉ុន្តែ ពួកកសិករនាំគ្នាចាប់ពួកអ្នកបម្រើមក
វាយដំម្នាក់ ប្រហារជីវិតម្នាក់ និងយកដុំថ្មគប់សម្លាប់ម្នាក់ទៀត។ 36 ម្ចាស់ចំការក៏ចាត់អ្នកបម្រើផ្សេងទៀត ដែលមានគ្នាច្រើនជាងមុនឲ្យមកម្ដងទៀត ប៉ុន្តែ ពួក
អ្នកថែចម្ការបានធ្វើបាបអ្នកបម្រើទាំងនោះដូចពួកមុនៗដែរ។ 37 ក្រោយមក ម្ចាស់ចម្ការចាត់កូនប្រុសរបស់គាត់ ឲ្យមកជួបគេដោយគិតថា៖ «គេមុខជាគោរព
កោតខ្លាចកូនប្រុសគាត់ជាមិនខាន»។ 38 ប៉ុន្តែ ពេលពួកកសិករឃើញកូនប្រុសរបស់ម្ចាស់ចម្ការមកដល់ គេពិគ្រោះគ្នាថា៖ «អ្នកនេះជាអ្នកទទួលកេរមត៌កពី
ម្ចាស់ចម្ការបើយើងនាំគ្នាសម្លាប់វា មត៌កនេះនឹងត្រូវបានមកយើងជាមិនខាន។ 39 គេក៏ចាប់កូនប្រុសម្ចាស់ចម្ការបោះទៅខាងក្រៅ ហើយសម្លាប់គាត់ចោល
ទៅ។ 40 លុះដល់ពេលម្ចាស់ចម្ការមក តើគាត់នឹងធ្វើយ៉ាងណាចំពោះកសិករទាំងនោះ? 41 ពួកគេទូលព្រះអង្គថា៖ «គាត់មុខជាសម្លាប់ជនពាលទាំងនោះឥត
ត្រាប្រណីឡើយ រួចហើយប្រវាស់ចម្ការឲ្យអ្នកផ្សេងទៀត ដែលជាអ្នកនឹងប្រគល់ផលជាចំណែករបស់គាត់ជូនដល់គាត់ នៅរដូវទំពាំងបាយជូរទុំ»។ 42
ព្រះយេស៊ូមានព្រះបន្ទូលទៅពួកគេថា៖ «តើអ្នកធ្លាប់បានអានគម្ពីរទេថា ថ្មដែលពួកជាងសង់បោះចោល បានត្រឡប់មកជាថ្មគ្រឹះដ៏សំខាន់បំផុត។ ព្រះអម្ចាស់
បានសម្រេចការទាំងនេះឲ្យយើងឃើញ ហើយឲ្យយើងស្ងើចសរសើរផង»? 43 ដូចនេះហើយ បានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់នឹងដកព្រះរាជ្យចេញ
ពីអ្នករាល់គ្នា ហើយប្រគល់ទៅឲ្យសាសន៍មួយទៀត ដែលចេះបង្កើតផលរបស់ព្រះរាជ្យ។ 44 អ្នកណាដួលលើថ្មនេះ អ្នកនោះមុខជាត្រូវបាក់បែកខ្ទេចខ្ទាំមិនខាន
ប៉ុន្តែបើថ្មនេះសង្កត់លើអ្នកណា មុខជាកិនកំទេចអ្នកនោះជាប្រាកដដែរ។ 45 ពេលពួកនាយកបូជាចារ្យ និងពួកខាងគណៈផារីស៊ីបានឮពីប្រស្នានេះក៏ដឹងថា
ព្រះអង្គមានព្រះបន្ទូលសំដៅទៅលើពួកគេ។ 46 ពួកគេនាំគ្នារកមធ្យោបាយចាប់ព្រះអង្គ ប៉ុន្តែគេខ្លាចមហាជន ពីព្រោះមហាជនចាត់ទុកព្រះយេស៊ូជាព្យាការី
មួយរូប។


generated on Thu Feb 8 15:37:30 2024

## ជំពូក 22

1 ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នាទៅពួកគេម្តងទៀតថា៖ 2 «ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបបាននឹងស្តេចមួយអង្គដែលរៀបចំវិវាហមង្គលការ
សម្រាប់ព្រះរាជបុត្រ។ 3 ព្រះអង្គបានចាត់រាជបម្រើឲ្យទៅអញ្ជើញភ្ញៀវមកជប់លៀង ក្នុងឱកាសមង្គលការនោះ ប៉ុន្តែគ្មាននរណាមកសោះ។ 4 ព្រះអង្គចាត់រាជ
បម្រើផ្សេង ឲ្យទៅជម្រាបភ្ញៀវម្តងទៀតថា៖ «សូមអញ្ជើញមកពិសាការ។ មើល! យើងបានរៀបចំភោជនាហារសម្រាប់ជប់លៀង។ ខ្ញុំបានសម្លាប់គោ និងសម្លាប់
សត្វដែលបានបំប៉ននោះរួចរាល់អស់ហើយ»។ 5 ប៉ុន្តែ ភ្ញៀវមិនរវីរវល់អើពើឡើយ ហើយដើរចេញ អ្នកខ្លះទៅចម្ការ អ្នកខ្លះទៅធ្វើជំនួញ។ 6 អ្នកខ្លះទៀតចាប់ពួក
រាជបម្រើរបស់ស្តេចវាយធ្វើបាប ព្រមទាំងសម្លាប់ចោលថែមទៀត។ 7 ព្រះរាជាទ្រង់ពិរោធយ៉ាងខ្លាំង ក៏ចាត់ទាហានឲ្យទៅប្រហារជីវិតឃាតកទាំងនោះ ហើយ
ដុតស្រុកភូមិរបស់គេផង។ 8 បន្ទាប់មក ទ្រង់មានរាជឱង្ការទៅពួករាជបំរើថា៖ «ពិធីមង្គលការត្រូវបានរៀបចំរួចស្រេចហើយ ប៉ុន្តែ ភ្ញៀវទាំងនោះមិនសមនឹងមក
ចូលរួមទេ។ 9 ហេតុនេះ ចូរនាំគ្នាចេញទៅតាមផ្លូវកែង ហើយអញ្ជើញមនុស្សទាំងអស់ដែលអ្នករាល់គ្នាជួប ឲ្យមកជប់លៀង»។ 10 ពួករាជបម្រើក៏ចេញទៅ
តាមផ្លូវ ប្រមូលមនុស្សម្នា ដែលគេបានជួបទាំងប៉ុន្មានមក ទាំងមនុស្សអាក្រក់ហើយនិងមនុស្សល្អផង។ ពេលនោះ មានភ្ញៀវពេញរោងការ។ 11 ប៉ុន្តែ
ពេលព្រះរាជាយាងចូលមកមើលភ្ញៀវនៅក្នុងរោងការ ទតឃើញបុរសម្នាក់ស្លៀកពាក់មិនត្រូវនឹងរបៀបពិធីការ 12 ស្តេចក៏មានរាជឱង្ការទៅអ្នកនោះថា៖
«សម្លាញ់អើយ! ហេតុអ្វីបានជាអ្នកចូលមកទីនេះ ដោយមិនស្លៀកសម្លៀកបំពាក់សម្រាប់មង្គលការដូច្នេះ?» ប៉ុន្តែបុរសនោះរកនិយាយអ្វីមិនចេញឡើយ។ 13
បន្ទាប់មកព្រះរាជាបង្គាប់ទៅពួករាជបម្រើថា៖ «ចូរចងដៃចងជើងអ្នកនេះ ហើយយកទៅចោលនៅទីងងឹតខាងក្រៅ ជាកន្លែងយំសោកខឹងសង្កៀតធ្មេញនោះ
ទៅ»។ 14 មានមនុស្សជាច្រើនដែលព្រះត្រាស់ហៅ តែព្រះអង្គជ្រើសរើសយកបានចំនួនតិចទេ។ 15 បន្ទាប់មកពួកខាងគណៈផារីស៊ី ចេញទៅពិគ្រោះគ្នា រិះរក
មធ្យោបាយចាប់កំហុសព្រះយេស៊ូ 16 ក្រោយមកគេក៏ចាត់សិស្សរបស់ពួកគេ និងពួកខាងស្តេចហេរ៉ូដ ទៅទូលព្រះអង្គថា៖ «លោកគ្រូ! យើងខ្ញុំដឹងថា
សេចក្តីពិតហើយពាក្យដែលលោកមានប្រសាសន៍សុទ្ធតែពិតទាំងអស់។ គឺលោកគ្រូពុំយោគយល់ ហើយក៏ពុំរើសមុខនរណាឡើយ។ 17 ហេតុនេះ សូមលោក
គ្រូប្រាប់យើងខ្ញុំមើល៍ថា បើតាមក្រឹត្យវិន័យ តើយើងត្រូវបង់ពន្ធ ថ្វាយសេសារឬទេ?» 18 ប៉ុន្តែ ព្រះយេស៊ូឈ្វេងយល់គំនិតអាក្រក់របស់ពួកគេ ហើយព្រះអង្គ
មានព្រះបន្ទូលថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាចង់ចាប់កំហុសខ្ញុំដូច្នេះ មនុស្សមានពុតអើយ? 19 ចូរបង្ហាញប្រាក់សម្រាប់បង់ពន្ធនោះឲ្យខ្ញុំមើលមើល៍»។ គេក៏
យកប្រាក់មួយកាក់មកថ្វាយព្រះអង្គ។ 20 ព្រះយេស៊ូមានព្រះបន្ទូលសួរគេថា៖ «តើលើកាក់នេះ មានរូបនរណា ឈ្មោះនរណា?» 21 គេទូលថា៖ «រូប និង
ឈ្មោះព្រះចៅអធិរាជ ព្រះយេស៊ូក៏មានព្រះបន្ទូលទៅគេថា៖ «អ្វីៗដែលជារបស់សេសារ ចូរថ្វាយទៅសេសារវិញទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរ
ថ្វាយទៅព្រះជាម្ចាស់វិញដែរ»។ 22 ពួកគេងឿងឆ្ងល់នឹងចម្លើយរបស់ព្រះអង្គ ហើយនាំគ្នាចាកចេញពីព្រះអង្គទៅ។ 23 នៅថ្ងៃនោះ មានពួកខាងគណៈសាឌូស៊ី
ដែលមិនជឿថា មនុស្សស្លាប់នឹងរស់ឡើងវិញ ចូលមកគាល់ព្រះអង្គ។ ពួកគេទូលសួរព្រះអង្គថា៖ 24 «លោកគ្រូ! លោកម៉ូសេមានប្រសាសន៍ថា បើបុរសណា
ស្លាប់ទៅ តែគ្មានកូនសោះ នោះប្អូនប្រុសរបស់បុរសនោះត្រូវរៀបការនឹងបងថ្លៃ ដើម្បីបន្តពូជឲ្យបងប្រុសរបស់ខ្លួន។ 25 ឧបមាថា មានបងប្អូនប្រុសប្រាំពីរនាក់
បងបង្អស់រៀបការ ហើយស្លាប់ទៅ តែគ្មានកូនសោះ ទុកប្រពន្ធឲ្យប្អូន។ 26 បន្ទាប់មកប្អូនទីពីរ ប្អូនទីបី រហូតដល់ប្អូនទីប្រាំពីរ សុទ្ធតែបានរៀបការជាមួយនាង
ហើយស្លាប់ទៅគ្មានកូនដូចគ្នា។ 27 ហើយនៅទីបំផុត ស្ត្រីនោះក៏ស្លាប់ទៅដែរ។ 28 ដល់ពេលមនុស្សស្លាប់នឹងរស់ឡើងវិញ តើនាងបានទៅជាប្រពន្ធនរណា បើ
បងប្អូនទាំងប្រាំពីរនាក់ សុទ្ធតែបានរៀបការជាមួយនាងគ្រប់គ្នាដូច្នេះ? 29 ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖ «អ្នករាល់គ្នាយល់ខុសហើយ! ព្រោះអ្នក
រាល់គ្នាមិនយល់គម្ពីរ ទាំងមិនស្គាល់ឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ 30 ដ្បិត ពេលមនុស្សស្លាប់នឹងរស់ឡើងវិញ គេមិនរៀបការប្តីប្រពន្ធទៀតឡើយ គឺគេនឹង
បានដូចទេវតានៅស្ថានបរមសុខ។ 31 អំពីមនុស្សស្លាប់នឹងរស់ឡើងវិញ តើអ្នកមិនដែលអានដែលថាអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលថា៖ 32 «យើងជាព្រះ
របស់អប្រាហាំ ជាព្រះរបស់អ៊ីសាក និងជាព្រះរបស់យ៉ាកុប? ព្រះជាម្ចាស់មិនមែនជាព្រះរបស់មនុស្សស្លាប់ទេ គឺជាព្រះអង្គរបស់មនុស្សដែលមានជីវិត» 33
កាលមហាជនបានឮសេចក្តី ដែលព្រះអង្គបង្រៀន ពួកគេងឿងឆ្ងល់ជាខ្លាំង។ 34 ពេលនោះ ពួកខាងគណៈផារីស៊ីប្រជុំគ្នា ព្រោះពួកគេឮថា ព្រះយេស៊ូបានធ្វើឲ្យ
ពួកខាងគណៈសាឌូស៊ីទ័លប្រាជ្ញ។ 35 ក្នុងចំណោមពួកគេមានម្នាក់ជាបណ្ឌិតខាងវិន័យ ទូលសួរព្រះអង្គក្នុងគោលបំណងល្បងលមើលព្រះអង្គថា៖ 36
«លោកគ្រូ! ក្នុងក្រឹត្យវិន័យ តើមានបទបញ្ញាណាសំខាន់ជាងគេ?»។ 37 ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យអស់ពីចិត្ត
គំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា»។ 38 នេះហើយជាបទបញ្ញាទីមួយ ដែលសំខាន់ជាងគេបំផុត។ 39 រីឯបទបញ្ញាទីពីរគឺដូច្នេះ  គឺត្រូវស្រឡាញ់បងប្អូនឯ
ទៀតៗ ឲ្យបានដូចស្រឡាញ់ខ្លួនឯងដែរ។ 40 បទបញ្ញាទាំងពីរនេះ ជាឫសគល់របស់គម្ពីរវិន័យ និងគម្ពីរព្យាការីទាំងអស់»។ 41 ពេលនោះ ពួកខាងគណៈ
ផារីស៊ីនៅតែជុំគ្នា ព្រះយេស៊ូក៏សួរទៅពួកគេ។ 42 ដោយព្រះបន្ទូលថា៖ «តើអ្នករាល់គ្នាយល់ថា ព្រះគ្រិស្តជាព្រះរាជវង្សរបស់អ្នកណាដែរ?» ពួកគេឆ្លើយថា៖
«ព្រះអង្គជាព្រះរាជវង្សរបស់ព្រះបាទដាវីឌ»។ 43 ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ចុះហេតុដូចម្តេចបានជាព្រះបាទដាវីឌ ដែលមានព្រះវិញ្ញាណបំភ្លឺហៅ
ព្រះគ្រិស្តថា ព្រះអម្ចាស់ ទៅវិញដូច្នេះ គឺព្រះអង្គមានរាជឱង្ការថា 44 ព្រះអម្ចាស់មានបន្ទូលមកកាន់ព្រះអម្ចាស់របស់ខ្ញុំថា ចូរអង្គុយនៅខាងស្តាំយើង រហូតដល់
យើងដាក់ខ្មាំងសត្រូវរបស់អ្នកនៅក្រោមជើងរបស់អ្នក? 45 បើព្រះបាទដាវីឌហៅព្រះគ្រិស្តថា ជាព្រះអម្ចាស់ ដូច្នេះ តើឲ្យព្រះគ្រិស្តត្រូវជាព្រះរាជវង្សរបស់
ព្រះអង្គដូចម្តេច?» 46 គ្មាននរណាម្នាក់អាចឆ្លើយទៅព្រះអង្គវិញ សូម្បីតែមួយម៉ាត់ក៏មិនបានផង ហើយចាប់តាំងពីពេលនោះមក គ្មាននរណាហ៊ានសួរព្រះអង្គ
ទៀតឡើយ។

 generated on Thu Feb 8 15:37:30 2024

## ជំពូក 23

1 បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូល ទៅកាន់មហាជន និងពួកសិស្សរបស់ព្រះអង្គ។ ព្រះអង្គមានព្រះបន្ទូលថា៖ 2 ពួកអាចារ្យ និងពួកផារីស៊ី មានភារកិច្ច
បង្រៀនគម្ពីរវិន័យរបស់លោកម៉ូសេ។ 3 អ្វីៗដែលគេបង្រៀនអ្នករាល់គ្នា ចូរស្ដាប់ ហើយយកទៅប្រតិបត្តិតាមទៅ តែកុំយកតម្រាប់តាមអំពើដែលគេប្រព្រឹត្ត
ឡើយ ពីព្រោះគេមិនប្រតិបត្តិតាមសេចក្ដីដែលគេបង្រៀននោះឡើយ។ 4 ពិតមែន អ្នកទាំងនោះបានបង្កើតវិន័យយ៉ាងតឹងរ៉ឹង យកមកផ្ទុកលើស្មារបស់មនុស្ស
ប៉ុន្តែគេមិនជួយសម្រាលបន្ទុកនោះទេ សូម្បីតែបន្តិចបន្តួចក៏មិនជួយផង។ 5 ពួកគេធ្វើកិច្ចការទាំងនេះ គឺដើម្បីឲ្យមនុស្សម្នាកោតសរសើរ គឺគេធ្វើក្លាក់ កាន់តែធំ
ឡើងៗ និងធ្វើខ្សែរំយោល នៅជាយអាវកាន់តែវែងទៅៗ។ 6 ពួកគេចូលចិត្តកន្លែងកិត្តិយសក្នុងពិធីជប់លៀង ហើយរើសកន្លែងអង្គុយនៅមុខគេក្នុងសាលា
ប្រជុំ។ 7 ហើយពួកនេះជាពិសេសចូលចិត្តឲ្យគេអោនកាយគោរព នៅតាមផ្សារ និងឲ្យគេហៅខ្លួនថា «លោកគ្រូ»។ 8 ប៉ុន្តែរីឯអ្នករាល់គ្នាវិញ កុំបង្គាប់គេឲ្យហៅ
ខ្លួនថា «លោកគ្រូ» សោះឡើយ ដ្បិតអ្នករាល់គ្នាមានលោកគ្រូតែមួយគត់ ហើយអ្នករាល់គ្នាសុទ្ធតែជាបងប្អូននឹងគ្នា។ 9 កុំហៅនរណាម្នាក់នៅលើផែនដីនេះថា
«ព្រះបិតា» ឲ្យសោះ ដ្បិតអ្នករាល់គ្នាមាន ព្រះបិតា តែមួយគត់ប៉ុណ្ណោះ គឺទ្រង់គង់នៅស្ថានបរមសុខ។ 10 កុំឲ្យគេហៅអ្នករាល់គ្នាថា គ្រូឡើយ ដ្បិតមានតែ
ព្រះគ្រិស្តមួយព្រះអង្គប៉ុណ្ណោះ ដែលជាគ្រូរបស់អ្នករាល់គ្នា។ 11 ប៉ុន្តែបើអ្នកណាមានឋានៈធំជាងគេក្នុងចំណោមអ្នករាល់គ្នា ត្រូវឲ្យអ្នកនោះបម្រើអ្នករាល់
គ្នាវិញ។ 12 អ្នកណាលើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេបន្ទាបចុះ រីឯអ្នកដែលបន្ទាបខ្លួន នឹងត្រូវគេលើកតម្កើងវិញ។ 13 ប៉ុន្តែ ពួកអាចារ្យ និងពួកផារីស៊ីដ៏មាន
ពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ដ្បិតអ្នករាល់គ្នាបិទទ្វារព្រះរាជ្យនៃស្ថានបរមសុខ មិនឲ្យមនុស្សចូលទៅក្នុង អ្នករាល់គ្នាមិនត្រឹមតែមិនបានចូលខ្លួន
ឯងប៉ុណ្ណោះទេ គឺថែមទាំងរារាំងអ្នកដែលចង់ចូលមិនឲ្យគេចូលទៀតផង។ 14 ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះ
អ្នករាល់គ្នាឆបោកយកទ្រព្យសម្បត្តិរបស់ស្ត្រីមេម៉ាយ ដោយធ្វើឫកជាសូត្រធម៌យ៉ាងយូរ។ ហេតុនេះហើយបានជាអ្នករាល់គ្នាត្រូវទទួលទោសយ៉ាងធ្ងន់ជាមិន
ខាន។ 15 ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាធ្វើដំណើរតាមផ្លូវទឹក និងតាមផ្លូវគោក ស្វែងរក
បញ្ចុះបញ្ចូលគេ ឲ្យចូលសាសនារបស់អ្នករាល់គ្នា ។ លុះពួកគេចូលសាសនាហើយ អ្នករាល់គ្នាធ្វើឲ្យគេរឹតតែអាក្រក់ជួជាតិជាងអ្នករាល់គ្នាមួយទ្វេជាពីរ។ 16
ឱពួកអ្នកដឹកនាំកង្វាក់អើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន អ្នករាល់គ្នានិយាយថា បើអ្នកណាស្បថដោយយកព្រះវិហារមកធ្វើជាសាក្សី ពាក្យសម្បថនោះយក
ជាការពុំបានទេ។ ប៉ុន្តែ បើស្បថដោយយកមាសរបស់ព្រះវិហារធ្វើជាសាក្សី ទើបយកជាការបាន។ 17 មនុស្សកង្វាក់លេលាអើយ! មាស និងព្រះវិហារដែលធ្វើ
ឲ្យមាសទៅជាវត្ថុពិសិដ្ឋ តើមួយណាសំខាន់ជាង? 18 ហើយអ្នកណាស្បថដោយយកអាសនាធ្វើជាសាក្សី ពាក្យសម្បថនោះយកជាការពុំបានទេ ប៉ុន្តែបើស្បថ
ដោយយកតង្វាយលើអាសនាធ្វើជាសាក្សី ទើបយកជាការបាន។ 19 ឱមនុស្សកង្វាក់អើយ! តង្វាយដែលគេថ្វាយលើអាសនា និងអាសនាដែលធ្វើឲ្យតង្វាយទៅ
ជាតង្វាយពិសិដ្ឋ តើមួយណាសំខាន់ជាង? 20 ដូច្នេះ អ្នកណាស្បថដោយយកអាសនាជាសាក្សី អ្នកនោះមានទាំងអាសនា និងមានទាំងអ្វីៗនៅលើអាសនាជា
សាក្សី។ 21 អ្នកណាស្បថដោយយកព្រះវិហារជាសាក្សី អ្នកនោះមានទាំងព្រះវិហារ និងមានទាំងព្រះជាម្ចាស់ដែលគង់នៅក្នុងព្រះវិហារជាសាក្សីដែរ។ 22
ហើយអ្នកណាស្បថដោយយកស្ថានបរមសុខជាសាក្សី អ្នកនោះមានទាំងបល្ល័ង្ករបស់ព្រះជាម្ចាស់ មានទាំងព្រះជាម្ចាស់ដែលគង់នៅលើបល្ល័ង្កជាសាក្សី។ 23
ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ពីព្រោះអ្នករាល់គ្នាយកជីរអង្កាម ជីរនាងវង និងម្អមមួយភាគដប់មកថ្វាយព្រះជាម្ចាស់
ប៉ុន្តែអ្នករាល់គ្នាលះបង់ក្រឹត្យវិន័យសំខាន់ៗចោល គឺមានសេចក្ដីសុចរិត មេត្តាករុណាធម៌ និងជំនឿស្មោះត្រង់ជាដើម។ ប៉ុន្តែវិន័យទាំងប៉ុន្មាននេះហើយ ដែល
អ្នករាល់គ្នាត្រូវប្រតិបត្តិតាមដោយឥតលះបង់ចោលណាមួយឡើយ។ 24 អ្នកដឹកនាំកង្វាក់អើយ! អ្នករាល់គ្នាត្រងយកមូសចេញពីទឹកផឹក តែអ្នករាល់គ្នាលេប
អូដ្ឋវិញ។ 25 ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាសំអាតពែង និងចាន តែខាងក្រៅប៉ុណ្ណោះ ប៉ុន្តែ ផ្នែក
ខាងក្នុងពោរពេញទៅដោយផលដែលកើតមកពីការកេងប្រវ័ញ្ច និងការលោភលន់។ 26 ពួកផារីស៊ីដ៏កង្វាក់អើយ! ចូរសម្អាតផ្នែកខាងក្នុងពែងជាមុនសិន ទើប
អ្វីៗនៅខាងក្រៅបានស្អាតដែរ។ 27 ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាប្រៀបបាននឹងផ្នូរ
ដែលលាបពណ៌ស មើលពីក្រៅឃើញហាក់ដូចជាស្អាត តែខាងក្នុងពោរពេញទៅដោយឆ្អឹងសាកសព និងអ្វីដែលមិនស្អាត់។ 28 ដូចគ្នានោះដែរ អ្នករាល់គ្នា
សំដែងឫកពារខាងក្រៅឲ្យមនុស្សម្នាឃើញថា ជាអ្នកសុចរិត តែចិត្តអ្នករាល់គ្នាពោរពេញដោយគំនិតលាក់ពុត និងគំនិតទុច្ចរិតទៅវិញ។ 29 ពួកអាចារ្យ និងពួក
ផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាបានសង់ផ្នូរឲ្យពួកព្យាការី ព្រមទាំងតុបតែងផ្នូររបស់មនុស្សសុចរិត 30 ដោយខ្លួនពោល
ថា៖ «ប្រសិនបើយើងបានរស់នៅជំនាន់បុព្វបុរសរបស់យើង នោះយើងមុខជាមិនសមគំនិតជាមួយគេ ក្នុងការសម្លាប់ពួកព្យាការីឡើយ»។ 31 ពោលដូច្នេះបាន
សេចក្ដីថា អ្នករាល់គ្នាចោទខ្លួនឯងថាជាពូជពង្សរបស់ពួកអ្នកដែលបានសម្លាប់ព្យាការី។ 32 អ្នករាល់គ្នានៅតែបន្តកិច្ចការរបស់បុព្វបុរសអ្នករាល់គ្នា! 33 ឱពូជ
ពស់វែកអើយ! តើធ្វើម្ដេចឲ្យអ្នករាល់គ្នាគេចផុតពីទោសធ្លាក់នរកបានទៅ? 34 ហេតុនេះហើយ ខ្ញុំចាត់ព្យាការី អ្នកប្រាជ្ញ និងអាចារ្យឲ្យមករកអ្នករាល់គ្នា តែអ្នក
រាល់គ្នានឹងសម្លាប់ពួកគេខ្លះ ឆ្កាងខ្លះ និងវាយធ្វើបាបខ្លះក្នុងសាលាប្រជុំ ព្រមទាំងដេញពួកគេពីក្រុងមួយទៅក្រុងមួយផង។ 35 ដូច្នេះ អ្នករាល់គ្នាត្រូវទទួល
ទោស ព្រោះអ្នករាល់គ្នាបានបង្ហូរឈាមជនសុចរិត ចាប់ពីលោកអេបិលជាមនុស្សសុចរិតរហូតដល់លោកសាការី ជាកូនរបស់លោកបារ៉ាគាដែលអ្នករាល់គ្នាបាន
សម្លាប់ នៅត្រង់ចន្លោះទីសក្ការៈ និងអាសនា។ 36 ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាបានដឹងថា ទោសទាំងនោះនឹងត្រូវធ្លាក់មកលើមនុស្សជំនាន់នេះជាមិនខាន។ 37
យេរូសាឡឹម យេរូសាឡឹមអើយ! អ្នករាល់គ្នាបានសម្លាប់ពួកព្យាការី និងយកដុំថ្មគប់សម្លាប់អស់អ្នកដែលព្រះជាម្ចាស់បានចាត់ឲ្យមករកអ្នករាល់គ្នា។ ច្រើនលើក
ច្រើនសារមកហើយដែលខ្ញុំប្រមូលផ្ដុំអ្នករាល់គ្នា ដូចមេមាន់ក្រុងកូនវានៅក្រោមស្លាប តែអ្នករាល់គ្នាពុំព្រមសោះ។ 38 ហេតុនេះ ផ្ទះរបស់អ្នករាល់គ្នា នឹងត្រូវ
បោះបង់ចោលអោយនៅស្ងាត់ជ្រងំ។ 39 ដ្បិតខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀតហើយ រហូតដល់ពេលអ្នករាល់គ្នាពោលថា៖ «សូម
ព្រះជាម្ចាស់ប្រទានពរដល់ព្រះអង្គដែលយាងមកក្នុងនាមព្រះអម្ចាស់»។


generated on Thu Feb 8 15:37:30 2024

## ជំពូក 24

1 ព្រះយេស៊ូកំពុងយាងចេញពីព្រះវិហារ ពួកសិស្សចូលមកជិត ចង្អុលបង្ហាញវិមានផ្សេងៗក្នុងព្រះវិហារ ថ្វាយព្រះអង្គទត។ 2 ប៉ុន្តែទ្រង់មានព្រះបន្ទូលទៅគេ
ថា៖ «អ្នករាល់គ្នាមិនឃើញអ្វីៗនៅទីនេះទេឬ? ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា លែងមានថ្មត្រួតពីលើថ្មទៀតហើយ វានឹងត្រូវរលំបាក់បែកអស់»។ 3
កាលទ្រង់គង់នៅលើភ្នំដើមអូលីវ ពួកសិស្សនាំគ្នាចូលទៅគាល់ព្រះអង្គដាច់ឡែកពីគេ ហើយទូលថា៖ «សូមប្រាប់ឲ្យយើងខ្ញុំដឹងផង ហេតុការណ៍ទាំងនេះនឹង
កើតឡើងនៅពេលណា? តើមានទីសំគាល់អ្វីឲ្យយើងខ្ញុំដឹងថាដល់ពេលព្រះអង្គយាងមក និងដល់អវសានកាលនៃពិភពលោក?» 4 ព្រះយេស៊ូមានព្រះបន្ទូល
តបទៅគេថា៖ «ចូរប្រុងប្រយ័ត្ន កុំឲ្យនរណាមកបញ្ឆោតអ្នករាល់គ្នាឲ្យវង្វេងបានឡើយ។ 5 ដ្បិតនឹងមានមនុស្សជាច្រើន យកឈ្មោះខ្ញុំទៅប្រើដោយពោលថា៖
«ខ្ញុំនេះហើយជាព្រះគ្រិស្ត ហើយគេនឹងនាំមនុស្សជាច្រើនឲ្យវង្វេង។ 6 អ្នករាល់គ្នានឹងឮគេនិយាយអំពីសង្គ្រាម និងឮដំណឹងថា មានសង្គ្រាមផ្ទុះឡើង។ កុំ
ជ្រួលច្របល់ឡើយ ដ្បិតហេតុការណ៍ទាំងនេះត្រូវតែកើតឡើង តែមិនទាន់ដល់អវសានកាលនៃពិភពលោកនៅឡើយទេ។ 7 ប្រជាជាតិមួយនឹងតតាំងទល់នឹង
ប្រជាជាតិមួយទៀត ប្រទេសមួយតទល់នឹងប្រទេសមួយទៀត។ នៅតាមតំបន់ផ្សេងៗនឹងមានកើតទុរ្ភិក្ស និងរញ្ជួយផែនដី។ 8 ប៉ុន្តែ ហេតុការណ៍ទាំងនេះប្រៀប
បានទៅនឹងការឈឺចាប់ ដើមដំបូងរបស់ស្ត្រីដែលហៀបនឹងសម្រាលកូនប៉ុណ្ណោះ។ 9 គេនឹងបញ្ជូនអ្នករាល់គ្នាទៅធ្វើទុក្ខទោស ព្រមទាំងឲ្យគេសម្លាប់អ្នករាល់គ្នា
ថែមទៀតផង។ ជាតិសាសន៍ទាំងអស់នឹងស្អប់អ្នករាល់គ្នា ព្រោះតែនាមខ្ញុំ។ 10 មានមនុស្សជាច្រើននឹងបែកចិត្តឃ្លាតចេញពីជំនឿ ក្បត់គ្នា និងស្អប់គ្នាផង។ 11
នឹងមានព្យាការីក្លែងក្លាយជាច្រើនមកដល់ ហើយបញ្ឆោតមនុស្សជាច្រើនឲ្យវង្វេង។ 12 ដោយអំពើទុច្ចរិតនឹងរីកចម្រើនឡើងជាខ្លាំង បណ្ដាលឲ្យការស្រឡាញ់
របស់មនុស្សជាច្រើន ត្រូវធ្លាក់ចុះអន់ថយ។ 13 ប៉ុន្តែ អ្នកណាស៊ូទ្រាំរហូតដល់ទីបញ្ចប់ ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ។ 14 គេនឹងប្រកាសដំណឹងល្អអំពី
ព្រះរាជ្យនេះ ពាសពេញសកលលោកទាំងមូល ទុកជាសក្ខីភាពដល់ជាតិសាសន៍ទាំងអស់។ ពេលនោះ ទើបដល់អវសានកាលនៃពិភពលោក។ 15 កាលណា
អ្នករាល់គ្នាឃើញ វត្ថុចង្រៃដ៏គួរស្អប់ខ្ពើម តាំងនៅក្នុងទីសក្ការៈ ដូចព្យាការីដានីយ៉ែលបានថ្លែងទុក» (សូមឲ្យអ្នកអានយល់ពាក្យនេះចុះ) 16 ពេលនោះ អ្នកដែល
រស់ក្នុងស្រុកយូដា ត្រូវនាំគ្នារត់ទៅជ្រកនៅតាមភ្នំ។ 17 រីឯអ្នកនៅលើដំបូលផ្ទះ មិនត្រូវចុះមកយកអ្វីៗនៅក្នុងផ្ទះឡើយ 18 ហើយអ្នកដែលនៅឯចម្ការ ក៏មិន
ត្រូវវិលទៅផ្ទះយកអាវធំរបស់ខ្លួនដែរ។ 19 ប៉ុន្តែគ្រានោះ ស្ត្រីដែលមានផ្ទៃពោះ និងស្ត្រីបំបៅកូនមុខជាត្រូវវេទនាជាពុំខាន។ 20 ចូរទូលអង្វរព្រះជាម្ចាស់ សូមកុំ
ឲ្យអ្នករាល់គ្នាត្រូវរត់ភៀសខ្លួននៅរដូវត្រជាក់ ឬនៅថ្ងៃសប្ប័ទឡើយ 21 ដ្បិតនៅគ្រានោះ ជាគ្រាដែលមានទុក្ខលំបាកយ៉ាងខ្លាំង តាំងពីដើមកំណើតពិភពលោក
មកទល់សព្វថ្ងៃ ហើយទោះជាទៅថ្ងៃមុខទៀត ក៏ពុំដែលមានទុក្ខលំបាកខ្លាំងយ៉ាងនេះដែរ។ 22 ប្រសិនបើព្រះជាម្ចាស់មិនបន្ថយចំនួនថ្ងៃទាំងនោះទេ មុខជាគ្មាន
មនុស្សណាមួយបានរួចជីវិតឡើយ ប៉ុន្តែដោយយោគយល់ដល់ពួកអ្នកដែលព្រះអង្គបានជ្រើសរើស ចំនួនថ្ងៃនឹងកាត់បន្ថយ។ 23 ប្រសិនបើមានគេប្រាប់អ្នក
រាល់គ្នាថា៖ «មើល៍! ព្រះគ្រិស្តគង់នៅទីនេះ» «ឬនៅទីនោះ» កុំជឿគេឡើយ។ 24 ដ្បិតនឹងមានមនុស្សក្លែងខ្លួនធ្វើជាព្រះគ្រិស្ត ព្រមទាំងជាព្យាការី នាំគ្នាសម្ដែង
ទីសម្គាល់ធំអស្ចារ្យ និងឫទ្ធិបាដិហារិយ៍ផ្សេងៗ ដើម្បីបញ្ឆោតមនុស្សរហូតដល់ទៅនាំពួកអ្នក ដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យវង្វេងថែមទៀតផង ប្រសិនបើ
គេអាចធ្វើទៅបាន។ 25 ខ្ញុំបាននិយាយប្រាប់ឲ្យអ្នករាល់គ្នាដឹងជាមុនឲ្យហើយ។ 26 បើមានគេប្រាប់អ្នករាល់គ្នាថា៖ «មើល៍! ព្រះអង្គនៅវាលរហោស្ថាន
ឯណោះ» កុំចេញទៅតាមគេឡើយ ឬមួយបើគេថា៖ «ព្រះអង្គនៅក្នុងបន្ទប់ឯណោះ» ក៏កុំជឿពាក្យគេដែរ។ 27 ដ្បិតបុត្រមនុស្សនឹងយាងមក ប្រៀបបីដូចជា
ផ្លេកបន្ទោរដ៏ភ្លឺ ឆូតកាត់ពីទិសខាងកើតទៅទិសខាងលិច។ 28 សាកសពនៅទីណា ត្មាតក៏មកប្រមូលផ្ដុំគ្នានៅទីនោះដែរ។ 29 ប៉ុន្តែលុះគ្រាដែលមានទុក្ខវេទនា
នេះ កន្លងផុតទៅភ្លាមនោះ ព្រះអាទិត្យនឹងបាត់រស្មី ព្រះច័ន្ទលែងមានពន្លឺទៀតហើយ រីឯផ្កាយទាំងឡាយនឹងធ្លាក់ចុះពីលើមេឃ ហើយអំណាចនានានៅលើ
មេឃ នឹងត្រូវកក្រើករំពើក។ 30 បន្ទាប់ ទីសម្គាល់របស់បុត្រមនុស្សនឹងលេចចេញពីផ្ទៃមេឃមក ហើយកុលសម្ព័ន្ធទាំងប៉ុន្មាននៅលើផែនដី នឹងនាំគ្នាយំគក់
ទ្រូង ។ គេនឹងឃើញបុត្រមនុស្សយាងមកលើពពកក្នុងផ្ទៃមេឃ ប្រកបដោយឫទ្ធានុភាព និងសិរីរុងរឿងដ៏អស្ចារ្យ។ 31 លោកក៏ចាត់ពួកទេវតារបស់លោក
ជាមួយសំឡេងត្រែលាន់ឮរំពងឡើង ឲ្យទៅទិសទាំងបួន ដើម្បីប្រមូលពួកអ្នកដែលព្រះជាម្ចាស់បានជ្រើសរើស ចាប់ពីជើងមេឃម្ខាង ទៅជើងមេឃម្ខាង។ 32
ចូរអ្នករាល់គ្នាយកដើមឧទុម្ពរទៅរិះគិតចុះ។ កាលណាមែករបស់វាមានស្លឹកលាស់ខៀវខ្ចី អ្នករាល់គ្នាដឹងថា រដូវប្រាំងជិតមកដល់ហើយ។ 33 ដូច្នេះ កាលណា
អ្នករាល់គ្នាឃើញព្រឹត្តិការណ៍ទាំងអស់នោះកើតឡើងត្រូវដឹងថា បុត្រមនុស្សក៏ជិតមកដល់ហើយដែរ គឺលោកមកជិតបង្កើយហើយ។ 34 ខ្ញុំសុំប្រាប់អោយអ្នក
រាល់គ្នាដឹងប្រាកដថា ក្នុងពេលដែលមនុស្សជំនាន់នេះ នៅមានជីវិតនៅឡើយ ហេតុការណ៍ទាំងនោះនឹងកើតឡើង ។ 35 ផ្ទៃមេឃ និងផែនដីនឹងរលាយបាត់ទៅ
តែពាក្យដែលខ្ញុំនិយាយមិនរលាយបាត់ទេ។ 36 ប៉ុន្តែរីឯថ្ងៃកំណត់ និងពេលវេលា គ្មាននរណាដឹងឡើយ ទោះបីទេវតានៅស្ថានបរមសុខ ឬព្រះបុត្រាក៏ពុំជ្រាប
ដែរ មានតែព្រះបិតាមួយព្រះអង្គប៉ុណ្ណោះដែលជ្រាប។ 37 នៅគ្រាបុត្រមនុស្សយាងមក ក៏ដូចកាលនៅសម័យលោកណូអេដែរ។ 38 ដ្បិតនៅមុនពេលទឹកជំនន់
ធំ មនុស្សម្នាតែងតែនាំគ្នាស៊ីផឹក រៀបការប្ដីប្រពន្ធរហូតដល់ថ្ងៃដែលលោកណូអេចូលក្នុងទូកធំ។ 39 ហើយគេមិនបានចាប់អារម្មណ៍អ្វីសោះ ទាល់តែទឹកជំនន់
ឡើងមកដល់បំផ្លាញគេអស់ទៅ ដូចគ្នានេះដែរនៅគ្រាដែលបុត្រមនុស្សយាងមក ក៏កើតមានដូច្នោះដែរ។ 40 បើមានមនុស្សពីរនាក់ធ្វើការក្នុងចំការជាមួយគ្នា
ព្រះជាម្ចាស់នឹងយកម្នាក់ទៅ ទុកម្នាក់ទៀតឲ្យនៅ។ 41 បើមានស្ត្រីពីរនាក់កិនស្រូវជាមួយគ្នា ព្រះជាម្ចាស់នឹងយកម្នាក់ទៅទុកម្នាក់ទៀតឲ្យនៅ។ 42 ដូច្នេះ ចូរ
ប្រុងស្មារតីឲ្យមែនទែន ព្រោះអ្នករាល់គ្នាពុំដឹងថា ព្រះអម្ចាស់របស់អ្នករាល់គ្នានឹងមកដល់នៅពេលណាឡើយ។ 43 ប៉ុន្តែអ្នករាល់គ្នាដឹងហើយថា បើម្ចាស់ផ្ទះដឹង
ចោរចូលមកប្លន់ថ្មើរណា គាត់មុខជាប្រុងស្មារតីពុំខាន មិនបណ្ដោយឲ្យចោរចូលមកប្លន់ផ្ទះគាត់បានឡើយ។ 44 ដូច្នេះ អ្នករាល់គ្នាត្រូវត្រៀមខ្លួនជានិច្ច ដ្បិត
បុត្រមនុស្សនឹងមកដល់ នៅវេលាដែលអ្នករាល់គ្នាពុំបានគិត។ 45 បើអ្នកបម្រើណាមានចិត្តស្មោះត្រង់ ហើយឈ្លាសវៃ ម្ចាស់មុខជាផ្ទុកផ្ដាក់ឲ្យអ្នកបម្រើនោះ
មើលខុសត្រូវលើអ្នកបំរើឯទៀតៗ ក្នុងការចែកម្ហូបអាហារឲ្យគេ តាមពេលដែលកំណត់ជាពុំខាន? 46 អ្នកបំរើនោះពិតជាមានពរហើយ ពេលម្ចាស់ត្រឡប់មក
ដល់ផ្ទះវិញ ឃើញអ្នកបម្រើកំពុងបំពេញកិច្ចការរបស់ខ្លួនដូច្នេះ។ 47 ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា ម្ចាស់មុខជាផ្ទុកផ្ដាក់ឲ្យគាត់មើលខុសត្រូវ លើទ្រព្យ
សម្បត្តិទាំងប៉ុន្មានរបស់លោកថែមទៀតផង។ 48 ប៉ុន្តែ បើអ្នកបម្រើអាក្រក់គិតក្នុងចិត្តថា៖ «ម្ចាស់អញក្រមកដល់ណាស់» 49 ហើយគាត់វាយអ្នកបម្រើឯ
ទៀតៗព្រមទាំងទៅស៊ីផឹកជាមួយអ្នកប្រមឹកផងនោះ 50 ពេលម្ចាស់វិលត្រឡប់មកផ្ទះវិញ នៅថ្ងៃដែលអ្នកបម្រើនោះមិននឹកគិត ឬនៅពេលដែលគាត់មិន
ដឹងនោះ 51 លោកនឹងធ្វើទោសគាត់ជាទម្ងន់ ដោយឲ្យគាត់ទទួលទោសរួមជាមួយពួកមានពុតត្បុតដែរ គឺឲ្យទៅនៅកន្លែងយំសោកខឹងសង្កៀតធ្មេញ។

## ជំពូក 25

1 ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបានទៅនឹងស្ត្រីក្រមុំដប់នាក់ ដែលយកចង្កៀងហើយចេញទៅទទួលស្វាមី។ 2 ពួកនាងប្រាំនាក់ជាស្ត្រីឥតគំនិត ហើយប្រាំ
នាក់ទៀតជាស្ត្រីឈ្លាសវៃ។ 3 ស្ត្រីឥតគំនិតយកចង្កៀងទៅ តែមិនយកប្រេងទៅបង្ការជាមួយទេ។ 4 រីឯស្ត្រីឈ្លាសវៃវិញ នាងបានយកចង្កៀងទៅ ទាំងមាន
ប្រេងបង្ការផង។ 5 ដោយស្វាមីក្រមកដល់ នាងទាំងដប់នាក់ងោកងុយពេក ក៏ដេកលក់ទាំងអស់គ្នាទៅ។ 6 ប៉ុន្តែលុះដល់ពាក់កណ្ដាលអធ្រាត្រមានគេស្រែក
ឡើងថា៖ «មើល៍! ស្វាមីមកដល់ហើយ! ចូរនាំគ្នារត់ទៅទទួលលោក!»។ 7 ស្ត្រីក្រមុំទាំងនោះក៏ក្រោកឡើង ហើយរៀបចំអុជចង្កៀង។ 8 ស្ត្រីឥតគំនិតនិយាយទៅ
កាន់ស្ត្រីឈ្លាសវៃថា សុំចែកប្រេងឲ្យយើងខ្លះផង ព្រោះចង្កៀងយើងចង់រលត់អស់ហើយ។ 9 ប៉ុន្តែស្ត្រីឈ្លាសវៃឆ្លើយទៅវិញថា៖ «ទេមិនបានទេ! បើយើងចែកឲ្យ
ពួកនាងក្រែងមិនគ្រាន់សម្រាប់យើងផង និងសម្រាប់ពួកនាងផង។ ចូរនាំគ្នាទៅទិញនៅផ្ទះលក់ប្រេងទៅ»។ 10 នៅពេលដែលស្ត្រីឥតគំនិតទាំងប្រាំចេញទៅរក
ទិញប្រេង ស្រាប់តែស្វាមីមកដល់ ឯស្ត្រីប្រាំនាក់ដែលត្រៀមខ្លួនជាស្រេច នាំគ្នាចូលទៅក្នុងរោងការជាមួយលោក ហើយគេបិទទ្វារជិត។ 11 ក្រោយមក ស្ត្រីប្រាំ
នាក់ទៀតមកដល់ស្រែកហៅថា៖ «លោកម្ចាស់! លោកម្ចាស់! សូមបើកទ្វារឲ្យយើងខ្ញុំចូលផង»។ 12 ស្វាមីឆ្លើយទៅវិញថា៖ «ខ្ញុំសុំប្រាប់ឲ្យនាងទាំងអស់គ្នាដឹង
ច្បាស់ថា ខ្ញុំមិនស្គាល់ពួកនាងទេ!»។ 13 ចូរអ្នករាល់គ្នាប្រុងស្មារតី ដ្បិតអ្នករាល់គ្នាពុំដឹងថា ថ្ងៃណា ឬពេលណាដែលបុត្រមនុស្សមកនោះឡើយ។ 14 ប្រៀប
បាននឹងបុរសម្នាក់ ដែលហៀបចេញដំណើរទៅស្រុកឆ្ងាយ គាត់ហៅពួកអ្នកបម្រើមកប្រគល់ទ្រព្យសម្បត្តិឲ្យ។ 15 គឺឲ្យប្រាំណែនទៅអ្នកទីមួយ ពីរណែនទៅអ្នក
ទីពីរ និងមួយណែនទៅអ្នកទីបី តាមសមត្ថភាពរៀងៗខ្លួន រួចគាត់ចេញដំណើរទៅ។ 16 អ្នកបម្រើដែលបានទទួលប្រាក់ប្រាំណែន យកប្រាក់ចេញទៅរកស៊ីភ្លាម
ហើយចំណេញបានប្រាំណែនទៀត។ 17 ដូច្នោះដែរ អ្នកទីពីរដែលទទួលបានប្រាក់ពីរណែននោះក៍យកទៅរកស៊ី ចំណេញបានពីរណែនទៀត។ 18 រីឯអ្នកដែល
ទទួលប្រាក់មួយណែន បានចេញទៅ ជីកដីកប់ប្រាក់ម្ចាស់របស់ខ្លួនទុក។ 19 លុះពេលយូរក្រោយមក ម្ចាស់វិលត្រឡប់មកវិញ ហើយគិតបញ្ជីជាមួយអ្នកទាំង
បីនោះ។ 20 អ្នកទទួលប្រាក់ប្រាំណែន យកប្រាក់ដែលចំណេញបានប្រាំណែន មកជូនម្ចាស់ដោយពោលថា៖ «លោកម្ចាស់អើយ! លោកបានប្រគល់ប្រាក់ប្រាំ
ណែនឲ្យខ្ញុំប្របាទ ឥឡូវនេះ ខ្ញុំប្របាទចំណេញបានប្រាំណែនទៀត»។ 21 ម្ចាស់ក៏ពោលទៅគាត់ថា៖ «ល្អហើយ! អ្នកបម្រើដ៏ល្អ និងមានចិត្តស្មោះត្រង់អើយ!
អ្នកបានស្មោះត្រង់នឹងកិច្ចការមួយដ៏តូចនេះ ខ្ញុំនឹងតាំងអ្នកឲ្យមើលខុសត្រូវលើកិច្ចការធំៗ។ ចូរអ្នកចូលមកសប្បាយរួមជាមួយនឹងខ្ញុំចុះ»។ 22 អ្នកទទួលប្រាក់
ពីរណែន ក៏យកប្រាក់ដែលចំណេញបានពីរណែនទៀតនោះចូលមកដែរ ហើយជំរាបថា៖ «លោកម្ចាស់អើយ! លោកបានប្រគល់ប្រាក់ពីរណែនឲ្យខ្ញុំប្របាទ
ឥឡូវនេះ ខ្ញុំប្របាទចំណេញបានពីរណែនទៀត»។ 23 ម្ចាស់ក៏ពោលទៅគាត់ថា៖ «ល្អហើយ! អ្នកបម្រើដ៏ល្អ និងមានចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះត្រង់
នឹងកិច្ចការមួយដ៏តូចនេះ ខ្ញុំនឹងតាំងអ្នកឲ្យមើលខុសត្រូវលើកិច្ចការធំៗ ចូរអ្នកចូលមកសប្បាយរួមជាមួយនឹងខ្ញុំចុះ»។ 24 បន្ទាប់មក អ្នកដែលបានទទួលប្រាក់
មួយណែនក៏ចូលមក ហើយជម្រាបថា៖ «លោកម្ចាស់អើយ! ខ្ញុំប្របាទដឹងថាលោកជាមនុស្សតឹងតែងណាស់ លោកតែងច្រូតយកផលពីស្រែដែលលោកមិន
បានសាបព្រោះ ហើយប្រមូលយកផលពីដំណាំដែលលោកមិនបានដាំ។ 25 ខ្ញុំប្របាទបានយកប្រាក់ដែលលោកប្រគល់ឲ្យទៅជីកដីកប់ ព្រោះខ្ញុំប្របាទភ័យ
ខ្លាចពេក ឥឡូវនេះ សូមលោកម្ចាស់យកប្រាក់របស់លោកវិញចុះ»។ 26 ប៉ុន្តែម្ចាស់ក៏ពោលទៅអ្នកនោះថា៖ «នែ៎ អ្នកបម្រើអាក្រក់ និង ខ្ជិលច្រអូសអើយ! អ្នក
ដឹងស្រាប់ហើយថា ខ្ញុំតែងច្រូតយកផលពីស្រែដែលខ្ញុំមិនបានសាបព្រោះ និងប្រមូលផលពីដំណាំដែលខ្ញុំមិនបានដាំ។ 27 អ្នកគួរតែយកប្រាក់របស់ខ្ញុំទៅចង
ការ កាលណាខ្ញុំត្រឡប់មកវិញ ខ្ញុំនឹងទទួលប្រាក់ទាំងដើមទាំងការ។ 28 ចូរយកប្រាក់ពីអ្នកនេះ ហើយប្រគល់ឲ្យអ្នកដែលមានដប់ណែននោះទៅ 29 ដ្បិតអ្នក
ណាមានហើយ អ្នកនោះនឹងទទួលបរិបូណ៌ហូរហៀរថែមទៀត រីឯអ្នកដែលគ្មានវិញ គេនឹងដកហូតនូវអ្វីៗដែលអ្នកនោះមានទៀតផង។ 30 ចំណែកឯអ្នកបម្រើ
ឥតបានការនេះ ចូរយកអ្នកបម្រើនេះទៅចោលនៅទីងងឹតខាងក្រៅ ជាកន្លែងយំសោក ខឹងសង្កៀតធ្មេញនោះទៅ»។ 31 ពេលបុត្រមនុស្សយាងមក ប្រកប
ដោយសិរីរុងរឿង ជាមួយពួកទេវតា លោកនឹងគង់នៅលើបល្ល័ង្កដ៏រុងរឿង។ 32 ពេលនោះមនុស្សគ្រប់ជាតិសាសន៍នឹងមកផ្ដុំគ្នានៅមុខលោក ទ្រង់នឹងញែកគេ
ចេញពីគ្នា ដូចអ្នកគង្វាលញែកចៀមចេញពីពពែ 33 គឺឲ្យចៀមនៅខាងស្ដាំ ពពែនៅខាងឆ្វេង។ 34 បន្ទាប់មក ព្រះមហាក្សត្រនឹងមានព្រះបន្ទូលទៅកាន់អស់
អ្នកនៅខាងស្ដាំព្រះអង្គថា៖ «អស់អ្នកដែលព្រះបិតាខ្ញុំបានប្រទានពរអើយ! ចូរមកទទួលព្រះរាជ្យដែលទ្រង់បានរៀបទុកឲ្យអ្នករាល់គ្នា តាំងពីកំណើតពិភព
លោកមក។ 35 ដ្បិតកាលយើងឃ្លាន អ្នករាល់គ្នាបានឲ្យអាហារដល់យើងបរិភោគ កាលយើងស្រេក អ្នករាល់គ្នាបានឲ្យទឹកដល់យើងពិសា កាលយើងជាជន
បរទេស អ្នករាល់គ្នាបានទទួល យើងឲ្យស្នាក់នៅ 36 កាលយើងគ្មានសម្លៀកបំពាក់ អ្នករាល់គ្នាបានយកសម្លៀកបំពាក់មកឲ្យយើង កាលយើងមានជំងឺ អ្នក
រាល់គ្នាបានយកចិត្តទុកដាក់ដល់យើង កាលយើងជាប់ឃុំឃាំង អ្នករាល់គ្នាក៏បានមកសួរសុខទុក្ខយើងដែរ»។ 37 ក្រោយមកពួកអ្នកសុចរិតទូលព្រះអង្គវិញ
ថា៖ «ព្រះអម្ចាស់អើយ! តើយើងខ្ញុំដែលបានឃើញព្រះអង្គឃ្លាន ហើយយកម្ហូបអាហារមកថ្វាយព្រះអង្គសោយកាលណា? ឬឃើញព្រះអង្គស្រេក ហើយយក
ទឹកមកថ្វាយព្រះអង្គសោយពីអង្កាល់ណាដែរ? 38 តើយើងខ្ញុំដែលបានឃើញព្រះអង្គជាជនបរទេស ហើយទទួលព្រះអង្គឲ្យស្នាក់នៅកាលណាដែរ? ឬឃើញ
ព្រះអង្គគ្មានសម្លៀកបំពាក់ ហើយយកសម្លៀកបំពាក់មកថ្វាយព្រះអង្គពីអង្កាល់? 39 តើយើងខ្ញុំដែលបានឃើញព្រះអង្គប្រឈួន ឬជាប់ឃុំឃាំង ហើយមកសួរ
សុខទុក្ខព្រះអង្គពីអង្កាល់ណាដែរ?»។ 40 ព្រះមហាក្សត្រនឹងមានព្រះបន្ទូលតបទៅគេថា យើងសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា គ្រប់ពេលដែលអ្នករាល់គ្នា
ប្រព្រឹត្តអំពើទាំងនោះ ចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ ដែលជាបងប្អូនរបស់យើងនេះ អ្នករាល់គ្នាក៏ដូចជាបានប្រព្រឹត្តចំពោះយើងដែរ។ 41 បន្ទាប់មក
ព្រះអង្គនឹងមានព្រះបន្ទូលទៅពួកអ្នកនៅខាងឆ្វេងដៃព្រះអង្គថា៖ «ពួកត្រូវបណ្ដាសាអើយ! ថយចេញឲ្យឆ្ងាយពីយើង ហើយធ្លាក់ទៅក្នុងភ្លើងដែលឆេះ
អស់កល្បជានិច្ច ជាភ្លើងបម្រុងទុកសំរាប់ផ្ដន្ទាទោសមារសាតាំង និងបរិវាររបស់វានោះទៅ! 42 ព្រោះពេលយើងឃ្លាន អ្នករាល់គ្នាពុំបានឲ្យម្ហូបអាហារយើង
បរិភោគទេ កាលយើងស្រេក អ្នករាល់គ្នាក៏ពុំបានឲ្យទឹកយើងពិសាដែរ 43 កាលយើងជាជនបរទេសអ្នករាល់គ្នាពុំបានទទួលយើងឲ្យស្នាក់អាស្រ័យឡើយ កាល
យើងគ្មានសម្លៀកបំពាក់ អ្នករាល់គ្នាក៏ពុំបានយកសម្លៀកបំពាក់មកឲ្យយើងដែរ កាលយើងមានជំងឺ និងជាប់ឃុំឃាំង អ្នករាល់គ្នាពុំបានមកមើលយើងទាល់តែ
សោះ»។ 44 បន្ទាប់មកពួកនោះនាំគ្នាទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ! តើយើងខ្ញុំមានដែលបានឃើញព្រះអង្គឃ្លាន ឃើញព្រះអង្គស្រេក ឃើញព្រះអង្គជា
ជនបរទេស ឃើញព្រះអង្គគ្មានសម្លៀកបំពាក់ ឃើញព្រះអង្គប្រឈួន ឬជាប់ឃុំឃាំង ហើយយើងខ្ញុំមិនដែលជួយព្រះអង្គសោះពីអង្កាល់ណា?»។ 45
ព្រះអង្គនឹងមានព្រះបន្ទូលទៅគេថា៖ «យើងសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា គ្រប់ពេលអ្នករាល់គ្នាមិនបានប្រព្រឹត្តអំពើទាំងនោះ ចំពោះអ្នកតូចតាចជាងគេ
បំផុតម្នាក់ អ្នករាល់គ្នាក៏ដូចជាមិនបានប្រព្រឹត្តចំពោះយើងដែរ។ 46 អ្នកទាំងនេះនឹងត្រូវទទួលទោសអស់កល្បជានិច្ច រីឯអ្នកសុចរិតវិញ នឹងទទួលជីវិត
អស់កល្បជានិច្ច»។

---


generated on Thu Feb 8 15:37:30 2024

## ជំពូក 26

1 កាលព្រះយេស៊ូមានព្រះបន្ទូលទាំងនេះរួចហើយ ទ្រង់មានព្រះបន្ទូលទៅកាន់ពួកសិស្សរបស់ព្រះអង្គថា៖ 2 «អ្នករាល់គ្នាដឹងហើយថា ពីរថ្ងៃទៀតដល់បុណ្យ
ចម្លងហើយ បុត្រមនុស្សនឹងត្រូវគេបញ្ជូនទៅឆ្កាង»។ 3 ក្រោយមក ពួកនាយកបូជាចារ្យ និងពួកព្រឹទ្ធាចារ្យរបស់ប្រជាជន ជួបជុំគ្នានៅក្នុងដំណាក់របស់លោក
មហាបូជាចារ្យ ឈ្មោះកៃផាស 4 គេបានសម្រេចចិត្តជាមួយគ្នា រកកលល្បិចចាប់ព្រះយេស៊ូយកទៅធ្វើគុត។ 5 ដ្បិតគេនិយាយគ្នាថា៖ «កុំចាប់ក្នុងពេលបុណ្យ
ឡើយ ក្រែងលោកើតចលាចលក្នុងចំណោមប្រជាជន»។ 6 កាលព្រះយេស៊ូគង់នៅភូមិបេថានី ក្នុងផ្ទះរបស់ស៊ីម៉ូន ជាមនុស្សឃ្លង់។ 7 ពេលព្រះយេស៊ូកំពុង
សោយព្រះស្ងោយ មានស្ត្រីម្នាក់ចូលមករកព្រះអង្គ ទាំងកាន់ដបថ្មកែវមានប្រេងក្រអូបដ៏មានតម្លៃថ្លៃ នាងយកប្រេងក្រអូបនោះចាក់លើព្រះសិរសាព្រះអង្គ។ 8
ប៉ុន្តែពេលពួកសិស្សឃើញដូច្នេះទាស់ចិត្តជាខ្លាំង ហើយពោលថា៖ «ម្តេចក៏ខ្ជះខ្ជាយអ៊ីចឹង! 9 បើយកនាងប្រេងក្រអូបនេទៅលក់មុខជាបានប្រាក់ច្រើនណាស់
សម្រាប់ចែកទានដល់ជនក្រីក្រ»។ 10 ប៉ុន្តែព្រះយេស៊ូជ្រាបគំនិតរបស់គេ ក៏មានព្រះបន្ទូលថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នារករឿងនាងដូច្នេះ? ព្រោះនាងបាន
ធ្វើការដ៏ល្អចំពោះខ្ញុំ។ 11 អ្នករាល់គ្នាមានជនក្រីក្រនៅជាមួយអ្នករហូត រីឯខ្ញុំវិញ ខ្ញុំមិននៅជាមួយអ្នករាល់គ្នារហូតនោះទេ។ 12 ដ្បិតកាលនាងបានចាក់ប្រេង
លាបរូបកាយខ្ញុំដូច្នេះ ដើម្បីធ្វើពិធីបញ្ចុះសពរបស់ខ្ញុំ។ 13 ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា គ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល ពេលណាគេប្រកាស
ដំណឹងល្អ គេនឹងនិយាយអំពីកិច្ចការដែលនាងបានធ្វើនេះដែរ ដើម្បីរំលឹកអំពីនាង»។ 14 ពេលនោះ សិស្សម្នាក់ក្នុងក្រុមសិស្សទាំងដប់ពីរឈ្មោះ យូដាស
អ៊ីស្ការីយ៉ុត បានទៅជួបក្រុមនាយកបូជាចារ្យ 15 ហើយជម្រាបថា៖ «បើខ្ញុំប្រគល់លោកយេស៊ូជូនអស់លោក តើអស់លោកឲ្យអ្វីដល់ខ្ញុំ»? ពួកនាយកបូជាចារ្យ
ក៏រាប់ប្រាក់ឲ្យគាត់សាមសិបស្លឹង។ 16 ចាប់ពីពេលនោះមក យូដាសរកឱកាស ដើម្បីនាំគេទៅចាប់ព្រះយេស៊ូ។ 17 នៅថ្ងៃដំបូងនៃពិធីបុណ្យនំប៉័ងឥតមេ
ពួកសិស្សនាំគ្នាមកគាល់ព្រះយេស៊ូទូលថា៖ «តើព្រះគ្រូចង់ឲ្យយើងខ្ញុំរៀបចំជប់លៀង ជូនក្នុងឱកាសបុណ្យចម្លងនៅកន្លែងណា?» 18 ទ្រង់មានព្រះបន្ទូលថា៖
«ចូរនាំគ្នាទៅក្នុងទីក្រុង ប្រាប់បុរសម្នាក់ថា លោកគ្រូមានប្រសាសន៍ថា ពេលកំណត់របស់ខ្ញុំជិតមកដល់ហើយ ខ្ញុំនឹងធ្វើពិធីបុណ្យចម្លងជាមួយសិស្សរបស់ខ្ញុំនៅ
ក្នុងផ្ទះអ្នក»។ 19 ពួកសិស្សនាំគ្នាធ្វើតាមដូចព្រះយេស៊ូបង្គាប់ ហើយរៀបចំម្ហូបអាហារ សម្រាប់បុណ្យចម្លង។ 20 លុះដល់ល្ងាចចូលមកដល់ ព្រះអង្គបរិភោគរួម
តុជាមួយសិស្សទាំងដប់ពីររូប 21 នៅពេលពួកគេកំពុងបរិភោគ ទ្រង់មានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ក្នុងចំណោមអ្នករាល់គ្នា មាន
ម្នាក់នឹងក្បត់ខ្ញុំ»។ 22 ពួកសិស្សព្រួយចិត្តក្រៃលែង ម្នាក់ៗទូលសួរព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! តើទូលបង្គំឬព្រះអង្គ?» 23 ទ្រង់មានព្រះបន្ទូលទៅគេវិញ
ថា៖ «អ្នកជ្រលក់នំប៉័ងក្នុងចានជាមួយខ្ញុំ គឺអ្នកនោះហើយដែលក្បត់ខ្ញុំ។ 24 បុត្រមនុស្សត្រូវទៅ ដូចមានចែងទុកក្នុងគម្ពីរអំពីលោកស្រាប់។ ប៉ុន្តែ អ្នកដែល
ក្បត់បុត្រមនុស្ស នឹងត្រូវវេទនាជាមិនខាន។ ចំពោះអ្នកនោះ បើមិនបានកើតមកទេ នោះប្រសើរជាង! 25 យូដាសជាអ្នកក្បត់ព្រះអង្គ ទូលសួរថា៖ «តើខ្ញុំឬ
លោកគ្រូ? ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកនិយាយនឹងត្រូវហើយ»។ 26 នៅពេលពួកគេកំពុងបរិភោគ ព្រះយេស៊ូយកនំប៉័ងមកកាន់
ហើយអធិស្ឋានទៅព្រះជាម្ចាស់ រួចក៏កាច់ប្រទានឲ្យពួកសិស្ស ដោយមានព្រះបន្ទូលថា៖ «នេះជារូបកាយខ្ញុំ សូមពិសាចុះ»។ 27 ព្រះអង្គយកពែងមកកាន់
ហើយអរព្រះគុណព្រះជាម្ចាស់ រួចប្រទានឲ្យពួកសិស្ស ទាំងមានព្រះបន្ទូលថា៖ «សុំពិសាទាំងអស់គ្នាចុះ 28 ដ្បិតនេះជាលោហិតរបស់ខ្ញុំ ជាលោហិតនៃ
សម្ពន្ធមេត្រីដែលត្រូវបង្ហូរ ដើម្បីលើកលែងទោសដល់មនុស្សទាំងអស់ឲ្យរួចពីបាប។ 29 ប៉ុន្តែខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ខ្ញុំនឹងមិនពិសាស្រាទំពាំងបាយជូរនេះ
ទៀតឡើយ រហូតដល់ថ្ងៃដែលខ្ញុំនឹងពិសាស្រាទំពាំងបាយជូរថ្មី ជាមួយអ្នករាល់គ្នានៅក្នុងព្រះរាជ្យនៃព្រះបិតារបស់ខ្ញុំ»។ 30 ក្រោយពីពួកគេបានច្រៀងបទ
ទំនុកតម្កើងរួចហើយ ព្រះយេស៊ូយាងឆ្ពោះទៅភ្នំដើមអូលីវ ជាមួយពួកសិស្ស។ 31 ព្រះយេស៊ូក៏មានព្រះបន្ទូលទៅពួកសិស្សថា៖ យប់នេះ អ្នកទាំងអស់គ្នានឹង
បោះបង់ខ្ញុំចោល ដ្បិតមានចែងទុកមកថា៖ «យើងនឹងវាយសម្លាប់អ្នកគង្វាល ហើយហ្វូងចៀមនឹងត្រូវខ្ចាត់ខ្ចាយ។ 32 ប៉ុន្តែ ក្រោយពេលខ្ញុំមានជីវិតរស់ឡើង
វិញ ខ្ញុំនឹងទៅស្រុកកាលីឡេមុនអ្នករាល់គ្នា»។ 33 ប៉ុន្តែ ពេត្រុសទូលព្រះអង្គថា៖ «ទោះបីអ្នកឯទៀតបោះបង់ចោលព្រះអង្គក៏ដោយ ទូលបង្គំនឹងមិនបោះបង់
ចោលព្រះអង្គជាដាច់ខាត»។ 34 ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នកដឹងច្បាស់ថា នៅយប់នេះឯង មុនមាន់រងាវ អ្នកនឹងបដិសេធមិន
ស្គាល់ខ្ញុំបីដង»។ 35 ពេត្រុសទូលព្រះអង្គថា៖ «ទោះបីទូលបង្គំត្រូវស្លាប់ជាមួយព្រះអង្គក៏ដោយ ក៏ទូលបង្គំមិនបដិសេធថា មិនស្គាល់ព្រះអង្គឡើយ»។ សិស្ស
ឯទៀតៗក៏ទូលព្រះអង្គ ដូចពេត្រុសដែរ។ 36 ក្រោយមក ព្រះយេស៊ូយាងទៅជាមួយពួកសិស្សដល់កន្លែងមួយ ឈ្មោះកេតសេម៉ានី ហើយព្រះអង្គមាន
ព្រះបន្ទូលទៅគេថា៖ ពួកអ្នកទាំងអស់គ្នាអង្គុយនៅទីនេះសិនចុះ ខ្ញុំទៅអធិស្ឋាននៅត្រង់កន្លែងនោះ។ 37 ព្រះអង្គនាំពេត្រុស និងកូនរបស់លោកសេបេដេទាំងពីរ
នាក់ទៅជាមួយ ពេលនោះព្រះអង្គចាប់ផ្ដើមព្រួយព្រះហឫទ័យ ហើយអន្ទះសាពន់ប្រមាណ 38 ក្រោយមកទ្រង់មានព្រះបន្ទូលទៅកាន់អ្នកទាំងបីថា៖ «ខ្ញុំព្រួយ
ចិត្តយ៉ាងខ្លាំងស្ទើរតែស្លាប់ អ្នករាល់គ្នានៅទីនេះសិនហើយ ចូរប្រុងស្មារតីជាមួយខ្ញុំ»។ 39 ព្រះអង្គយាងទៅមុខបន្តិច ក្រាបព្រះភក្ត្រដល់ដីហើយអធិស្ឋានថា៖
«ឱព្រះបិតាអើយ! ប្រសិនបើបាន សូមឲ្យពែងនេះរំលងឆ្ងាយពីទូលបង្គំទៅ។ ប៉ុន្តែ សូមកុំធ្វើតាមបំណងទូលបង្គំឡើយ សូមឲ្យបានសម្រេចតាមព្រះហឫទ័យ
របស់ព្រះអង្គវិញ»។ 40 ព្រះអង្គយាងមករកពួកសិស្ស ឃើញគេកំពុងតែដេកលក់ ទ្រង់មានព្រះបន្ទូលទៅពេត្រុសថា៖ «តើអ្នករាល់គ្នាមិនស៊ូទ្រាំប្រុងស្មារតីជា
មួយខ្ញុំ សូម្បីតែមួយម៉ោងក៏មិនបានដែរឬអី? 41 ចូរប្រុងស្មារតី ហើយអធិស្ឋាន កុំឲ្យចាញ់ការល្បួងឡើយ។ វិញ្ញាណរបស់មនុស្សប្រុងប្រៀបបានមែន តែ
សាច់ឈាមរបស់គេនៅទន់ខ្សោយ»។ 42 ព្រះអង្គយាងចេញទៅអធិស្ឋានលើកទីពីរ ទ្រង់មានព្រះបន្ទូលថា៖ «ឱព្រះបិតាអើយ! ប្រសិនបើទូលបង្គំត្រូវតែទទួល
ពែងនៃទុក្ខលំបាកនេះចៀសពុំបានទេនោះ សូមឲ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គចុះ»។ 43 ព្រះអង្គវិលត្រឡប់ទៅរកពួកសិស្សម្តងទៀត ឃើញគេ
ដេកលក់ ដ្បិតគេងងុយពេក បើកភ្នែកពុំរួចសោះ។ 44 ព្រះអង្គក៏យាងចាកចេញពីគេទៅអធិស្ឋានជាលើកទីបី ហើយទូលអង្វរដោយពាក្យដដែល។ 45 បន្ទាប់
មក ព្រះអង្គវិលមករកសិស្សវិញ មានព្រះបន្ទូលទៅគេថា៖ «តើអ្នករាល់គ្នានៅតែដេកលក់ ហើយនាំគ្នាសម្រាកដល់អង្កាល់ទៀត? ដ្បិតពេលកំណត់ដែលបុត្រ
មនុស្សត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃ របស់មនុស្សបាបជិតមកដល់ហើយ។ 46 ចូរក្រោកឡើង! យើងនាំគ្នាទៅ មើល៍ អ្នកដែលក្បត់ខ្ញុំមកជិតដល់ហើយ»។
47 កាលព្រះអង្គកំពុងតែមានព្រះបន្ទូលនៅឡើយ ស្រាប់តែយូដាសជាសិស្សម្នាក់ ក្នុងចំណោមសិស្សទាំងដប់ពីរបានមកដល់ ដោយនាំបណ្តាជនជាច្រើន
ដែលពួកនាយកបូជាចារ្យ និងពួកព្រឹទ្ធាចារ្យរបស់ប្រជាជនបានចាត់អ្នកទាំងនោះ ឲ្យមក ទាំងកាន់ដាវ កាន់ដំបងមកជាមួយផង។ ។ 48 ម្នាក់ដែលក្បត់
ព្រះយេស៊ូ បានប្រាប់សញ្ញាមួយថា៖ «បើខ្ញុំថើបអ្នកណា គឺអ្នកនោះហើយ សុំចាប់គាត់ទៅ»។ 49 ភ្លាមនោះយូដាសមកដល់ គាត់ដើរតម្រង់មករកព្រះយេស៊ូ
ទូលថា៖ «ជម្រាបសួរលោកគ្រូ! រួចក៏ថើបព្រះអង្គ។ 50 ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «សម្លាញ់អើយ! ធ្វើអ្វីដែលអ្នកចង់ធ្វើទៅចុះ»។ ពេលនោះ
បណ្តាជនក៏នាំគ្នាចូលមកចាប់ព្រះអង្គ។ 51 មានម្នាក់ក្នុងចំណោមពួកអ្នកដែលនៅជាមួយព្រះយេស៊ូ បានហូតដាវចេញមកកាប់អ្នកបម្រើរបស់លោកមហា
បូជាចារ្យ ដាច់ស្លឹកត្រចៀក។ 52 បន្ទាប់មកព្រះយេស៊ូមានព្រះបន្ទូលទៅអ្នកនោះថា៖ «ទុកដាវអ្នកទៅក្នុងស្រោមវិញទៅ ដ្បិតអស់អ្នកដែលប្រើដាវនឹងត្រូវស្លាប់
ដោយមុខដាវ។ 53 តើអ្នកស្មានថា ខ្ញុំមិនអាចអង្វរករព្រះបិតាខ្ញុំឲ្យចាត់ទេវតាជាងដប់ពីរកងពល មកជួយខ្ញុំបានភ្លាមៗទេឬអី? 54 បើធ្វើដូច្នោះ តើធ្វើម្តេចនឹង
បានស្របតាមសេចក្តីដែលមានចែងទុកក្នុងគម្ពីរ អំពីហេតុការណ៍ដែលត្រូវតែកើតឡើងនេះទៅ»? 55 ពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់មហាជន
ថា៖ «អស់លោកកាន់ដាវកាន់ដំបងមកចាប់ខ្ញុំ ដូចជាមកចាប់ចោរអញ្ចឹង? ខ្ញុំអង្គុយបង្រៀននៅក្នុងព្រះវិហារជារៀងរាល់ថ្ងៃ តែអស់លោកពុំបានចាប់ខ្ញុំទេ។ 56
ប៉ុន្តែហេតុការណ៍ទាំងនេះកើតឡើង ដើម្បីឲ្យបានស្របតាមសេចក្តី ដែលមានចែងទុកក្នុងគម្ពីរព្យាការី»។ ពេលនោះ ពួកសិស្សនាំគ្នារត់ចោលព្រះអង្គអស់ទៅ។
57 ពួកអ្នកដែលចាប់ព្រះយេស៊ូ នាំគ្នាបណ្តើរព្រះអង្គទៅដល់ដំណាក់របស់លោកកៃផាសជាមហាបូជាចារ្យ។ ពួកអាចារ្យ និងពួកព្រឹទ្ធាចារ្យ ជួបជុំគ្នានៅទីនោះ។


generated on Thu Feb 8 15:37:30 2024

**58** ប៉ុន្តែពេត្រុសដើរតាមព្រះអង្គពីចម្ងាយ គាត់តាមរហូតដល់ទីធ្លាខាងក្នុងដំណាក់របស់មហាបូជាចារ្យ ហើយអង្គុយជាមួយកងរក្សាព្រះវិហារ រងចង់មើល
ហេតុការណ៍នឹងទៅជាយ៉ាងណា។ **59** ពួកនាយកបូជាចារ្យ និងក្រុមប្រឹក្សាជាន់ខ្ពស់ នាំគ្នារកពាក្យចោទប្រកាន់ មួលបង្កាច់ព្រះយេស៊ូ ដើម្បីកាត់ទោសប្រហារ
ជីវិតព្រះអង្គ **60** ទោះបីមានមនុស្សជាច្រើនធ្វើសាក្សីក្លែងក្លាយក៏ដោយ ក៏គេរកមិនឃើញកំហុសព្រះអង្គដែរ។ តែមានបុរសពីរនាក់នាំគ្នាចូលមក **61** ពោលថា៖
«អ្នកនេះបានអះអាងថា ខ្ញុំអាចរុះព្រះវិហាររបស់ព្រះជាម្ចាស់ចោល ហើយសង់ឡើងវិញបានក្នុងរវាងបីថ្ងៃ»។ **62** លោកមហាបូជាចារ្យក្រោកឈរឡើង សួរ
ព្រះអង្គថា៖ តើអ្នកឆ្លើយយ៉ាងម៉េចចំពោះអ្នកចោទប្រកាន់អ្នកទាំងនេះ? **63** ប៉ុន្តែព្រះយេស៊ូនៅស្ងៀម លោកមហាបូជាចារ្យសួរព្រះអង្គទៀតថា៖ ចូរបញ្ជាអ្នក
នាមព្រះដ៏មានព្រះជន្មគង់នៅ តើអ្នកពិតជាព្រះគ្រិស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់មែនឬ? **64** ព្រះយេស៊ូមានព្រះបន្ទូលទៅលោកថា៖ «ត្រូវដូចលោក
និយាយអ៊ីចឹង ប៉ុន្តែ ខ្ញុំសុំបញ្ជាក់ប្រាប់អស់លោកថា អំណើះតទៅ អស់លោកនឹងឃើញ បុត្រមនុស្សគង់នៅខាងស្ដាំព្រះដ៏មានឫទ្ធានុភាព ហើយនឹងយាងមក
លើពពកក្នុងផ្ទៃមេឃ»។ **65** ពេលនោះ លោកមហាបូជាចារ្យហែកអាវរបស់លោក ហើយមានប្រសាសន៍ថា៖ «ជននេះបានពោលពាក្យប្រមាថព្រះជាម្ចាស់!
តើយើងនៅរកសាក្សីទៀតធ្វើអី? មើល៍ អស់លោកបានឮអ្នកនេះពោលពាក្យប្រមាថព្រះជាម្ចាស់អំបាញ់មិញស្រាប់។ **66** តើអស់លោកគិតយ៉ាងណាដែរ?» ពួក
គេឆ្លើយឡើងថា៖ «អ្នកនេះត្រូវមានទោសដល់ជីវិត!» **67** ក្រោយមកគេក៏នាំគ្នាស្ដោះទឹកមាត់ដាក់ព្រះភក្ត្រព្រះអង្គ ហើយគេវាយតប់ព្រះអង្គ ហើយអ្នកខ្លះទះ
កំផ្លៀងព្រះអង្គ **68** ទាំងពោលថា៖ «ទាយមើល៍ ព្រះគ្រិស្តអើយ អ្នកណាវាយព្រះអង្គ?» **69** ពេលនោះ ពេត្រុសអង្គុយនៅខាងក្រៅក្នុងទីធ្លា ហើយមានស្ត្រីបម្រើ
របស់មហាបូជាចារ្យម្នាក់ចូលមកជិតគាត់ និយាយថា៖ «អ្នកឯងជាបក្សពួករបស់យេស៊ូ ជាអ្នកស្រុកកាលីឡេដែរ»។ **70** ប៉ុន្តែ គាត់ប្រកែកថានៅមុខពួកគេថា៖
«ខ្ញុំមិនដឹងថា នាងចង់និយាយអំពីរឿងអ្វីឡើយ»។ **71** ពេលពេត្រុសដើរចេញពីទីនោះ ឆ្ពោះទៅរកខ្លោងទ្វារ មានស្ត្រីបម្រើម្នាក់ទៀតឃើញគាត់ហើយនិយាយ
ថា៖ «អ្នកនេះជាបក្សពួករបស់យេស៊ូជាអ្នកភូមិណាសារ៉ែតដែរ»។ **72** លោកពេត្រុសក៏ប្រកែកសាជាថ្មីទាំងស្បថថា៖ «ខ្ញុំមិនស្គាល់អ្នកនោះទេ!» **73** បន្តិច
ក្រោយមក អស់អ្នកដែលនៅទីនោះ នាំគ្នាចូលទៅជិតពេត្រុសហើយពោលថា៖ «អ្នកឯងពិតជាបក្សពួករបស់អ្នកទាំងនោះ ព្រោះសម្ដីអ្នកឯងបញ្ជាក់ច្បាស់ថា
អ្នកឯងមកពីស្រុកកាលីឡេមែន»។ **74** ពេត្រុសក៏ពោលឡើងថា៖ «គាត់ចាប់ផ្ដើមស្បថថា ខ្ញុំមិនដែលស្គាល់អ្នកនោះទាល់តែសោះ» ភ្លាមនោះ ស្រាប់តែមាន់
រងាវឡើង **75** ពេត្រុសក៏នឹកឃើញព្រះបន្ទូលរបស់ព្រះយេស៊ូថា៖ «មុនមាន់រងាវ អ្នកនឹងបដិសេធមិនស្គាល់ខ្ញុំបីដង»។ បន្ទាប់មក ពេត្រុសចាកចេញពីទីនោះ
ហើយយំសោកយ៉ាងខ្លោចផ្សា។

---


generated on Thu Feb 8 15:37:30 2024

## ជំពូក 27

1 លុះពេលព្រឹកបានមកដល់ ពួកនាយកបូជាចារ្យ និងព្រឹទ្ធាចារ្យរបស់ប្រជាជនប្រជុំគ្នា ហើយសម្រេចចិត្តធ្វើគុតព្រះយេស៊ូ។ 2 ពួកគេចងព្រះអង្គ ហើយបញ្ជូន
ទៅលោកពីឡាតជាទេសាភិបាល។ 3 កាលយូដាស ជាអ្នកដែលក្បត់ព្រះយេស៊ូ ឃើញគេកាត់ទោសព្រះអង្គដូច្នេះ គាត់សោកស្ដាយជាខ្លាំង ក៏យកប្រាក់
សាមសិបស្លឹងទៅប្រគល់ឲ្យពួកនាយកបូជាចារ្យ និងពួកព្រឹទ្ធាចារ្យវិញ 4 ហើយពោលថា៖ «ខ្ញុំបានប្រព្រឹត្តអំពើបាប ព្រោះខ្ញុំបានក្បត់មនុស្សឥតទោសទៅឲ្យគេ
បង្ហូរឈាម»។ ប៉ុន្តែពួកគេឆ្លើយថា៖«តើរឿងនេះមានទាក់ទងអ្វីនឹងយើងទៅ? ជារឿងរបស់អ្នកទេតើ»។ 5 បន្ទាប់មកយូដាសបាចប្រាក់នោះនៅក្នុង
ព្រះវិហារហើយចេញទៅចងកសម្លាប់ខ្លួនទៅ។ 6 ពួកនាយកបូជាចារ្យបានរើសប្រាក់នោះ ហើយពោលថា៖ «គ្មានច្បាប់នឹងបញ្ចូលប្រាក់នេះទៅក្នុងហិបតង្វាយ
ឡើយ ព្រោះវាជាប្រាក់បង់ថ្លៃឈាម»។ 7 ពួកគេបានពិភាក្សាគ្នាហើយ គេក៏យកប្រាក់នោះទៅទិញដីចម្ការរបស់ជាងស្មូន ទុកធ្វើជាកន្លែងបញ្ចុះសពជន
បរទេស។ 8 ព្រោះហេតុនេះហើយបានជាគេហៅចម្ការនោះថា «ចម្ការបង្ហូរឈាម» រហូតមកទល់សព្វថ្ងៃនេះ។ 9 ហេតុការណ៍នេះកើតឡើង ស្របនឹងសេចក្ដី
ដែលមានចែងទុក តាមរយៈព្យាការីយេរេមាមកថា៖ «គេបានយកប្រាក់សាមសិបស្លឹង ជាប្រាក់ដែលជនជាតិអ៊ីស្រាអែលសន្មតថាជាថ្លៃទិញលោកនោះ 10
ហើយគេបានយកប្រាក់នោះទៅទិញចំការរបស់ជាងស្មូន ដូចព្រះអម្ចាស់បង្គាប់មកខ្ញុំ»។ 11 ឥឡូវនេះព្រះយេស៊ូ ឈរនៅចំពោះមុខលោកទេសាភិបាល លោក
សួរព្រះអង្គថា៖ «តើអ្នកជាស្ដេចរបស់យូដាមែនឬ?» ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ត្រូវដូចលោកមានប្រសាសន៍ហើយ»។ 12 ប៉ុន្តែពួកនាយកបូជាចារ្យ និង
ពួកព្រឹទ្ធាចារ្យនាំគ្នាចោទប្រកាន់ព្រះអង្គ តែព្រះអង្គពុំឆ្លើយអ្វីទាល់តែសោះ។ 13 បន្ទាប់មកលោកពីឡាតសួរព្រះអង្គថា៖ «តើអ្នកមិនឮការទាំងប៉ុន្មាន ដែលគេ
ចោទប្រកាន់អ្នកទេឬ»? 14 ប៉ុន្តែ ព្រះអង្គពុំបានឆ្លើយតបមួយម៉ាត់ណាសោះឡើយ ជាហេតុនាំឲ្យលោកទេសាភិបាលងឿងឆ្ងល់ជាខ្លាំង។ 15 ពេលនោះជារៀង
រាល់ឆ្នាំ ក្នុងឱកាសបុណ្យចម្លង លោកទេសាភិបាលតែងតែដោះលែងអ្នកទោសម្នាក់ តាមសំណូមពររបស់បណ្ដាជន។ 16 នៅពេលនោះ មានអ្នកទោសដ៏ល្បី
ម្នាក់ ឈ្មោះបារ៉ាបាស។ 17 កាលបណ្ដាជនមកជុំគ្នាហើយ លោកពីឡាតសួរគេថា៖ «តើអ្នករាល់គ្នាចង់ឲ្យខ្ញុំដោះលែងអ្នកណា? ដោះលែងបារ៉ាបាស ឬយេស៊ូ
ហៅព្រះគ្រិស្ដ?» 18 លោកពីឡាតមានប្រសាសន៍ដូច្នេះ មកពីលោកជ្រាបថា ពួកគេបញ្ជូនព្រះយេស៊ូមកលោក ព្រោះគេមានចិត្តច្រណែន។ 19 នៅពេលដែល
លោកពីឡាត អង្គុយនៅលើវេទិកាកាត់ក្ដី ភរិយារបស់លោកបានចាត់គេឲ្យមកជម្រាបថា៖ «កុំឲ្យលោកឡំនឹងរឿងមនុស្សឥតទោសនេះធ្វើអ្វី។ ដ្បិតតែរឿងបុរសនេះ
ខ្ញុំយល់សប្ដិអាក្រក់ណាស់»។ 20 ពេលនោះពួកនាយកបូជាចារ្យ និងពួកព្រឹទ្ធាចារ្យនាំគ្នាញុះញង់បណ្ដាជន ឲ្យសុំដោះលែងបារ៉ាបាស និងសុំឲ្យប្រហារជីវិត
ព្រះយេស៊ូ។ 21 លោកទេសាភិបាលមានប្រសាសន៍ទៅគេថា៖ «ចំណោមអ្នកទាំងពីរនេះ តើអ្នករាល់គ្នាចង់ឲ្យខ្ញុំដោះលែងអ្នកណា?» ពួកគេឆ្លើយថា៖
«បារ៉ាបាស»។ 22 លោកពីឡាតសួរទៅគេថា៖ «បើដូច្នេះ តើអ្នករាល់គ្នាចង់ឲ្យខ្ញុំធ្វើអ្វីដល់ឈ្មោះ យេស៊ូ ហៅព្រះគ្រិស្ដនេះ?» ពួកគេស្រែកឡើងទាំងអស់គ្នាថា៖
«យកគាត់ទៅឆ្កាងទៅ!» 23 បន្ទាប់មកលោកមានប្រសាសន៍ថា៖ «តើអ្នកនេះបានប្រព្រឹត្តអំពើអាក្រក់អ្វី?» គេនាំគ្នាស្រែកកាន់តែខ្លាំងឡើងថា៖ «យកគាត់ទៅ
ឆ្កាងទៅ»។ 24 ដោយលោកពីឡាតឃើញថា មិនអាចធ្វើអ្វីលើសពីនេះទៀត ហើយផ្ទុយទៅវិញ ឃើញគេកើតចលាចលកាន់តែខ្លាំងឡើងៗដូច្នេះ លោកក៏យក
ទឹកមកលាងដៃនៅមុខបណ្ដាជន ហើយពោលថា៖ «ខ្ញុំឥតទទួលខុសត្រូវក្នុងការបង្ហូរឈាមបុរសនេះឡើយ នេះជាបញ្ហារបស់អ្នករាល់គ្នាទេ»។ 25 ប្រជាជន
ឆ្លើយឡើងទាំងអស់គ្នាថា៖ «យើងខ្ញុំ និងកូនចៅរបស់យើងខ្ញុំ នឹងទទួលខុសត្រូវក្នុងការប្រហារជីវិតជននេះ»។ 26 បន្ទាប់មក លោកពីឡាតក៏ដោះលែង
បារ៉ាបាស រីឯព្រះយេស៊ូវិញ លោកឲ្យគេវាយនឹងរំពាត់ រួចបញ្ជូនព្រះអង្គទៅឲ្យគេឆ្កាង។ 27 បន្ទាប់មក
ពួកទាហានរបស់លោកទេសាភិបាលនាំព្រះយេស៊ូទៅទីធ្លាបន្ទាយ ហើយប្រមូលទាហានមកចោមរោមព្រះអង្គ។ 28 ពួកគេដោះព្រះពស្ត្ររបស់ព្រះអង្គចេញ
ហើយពាក់អាវធំពណ៌ក្រហមទុំឲ្យព្រះអង្គវិញ 29 ពួកគេធ្វើមកុដពីបន្លាមកពាក់លើព្រះសិរសាព្រះអង្គ ហើយយកដើមត្រែងមកដាក់ក្នុងព្រះហស្ដស្ដាំព្រះអង្គ
ហើយពួកគេលុតជង្គង់ចុះ ទាំងពោលពាក្យចំអកព្រះអង្គថា៖ «សូមថ្វាយបង្គំស្ដេចសាសន៍យូដាអើយ!» 30 ពួកបានគេស្ដោះទឹកមាត់
និងយកដើមត្រែងនោះវាយព្រះសិរសាព្រះអង្គទៀតផង។ 31 ក្រោយពីបានប្រមាថមើលងាយព្រះអង្គរួចហើយ ពួកគេដោះអាវធំចេញ យកព្រះពស្ត្ររបស់
ព្រះអង្គមកបំពាក់ថ្វាយព្រះអង្គវិញ រួចបណ្ដើរព្រះអង្គនាំយកទៅឆ្កាង។ 32 ពេលចេញពីទីក្រុងទៅ គេជួបបុរសម្នាក់ឈ្មោះស៊ីម៉ូន ជាអ្នកស្រុកគីរេន គេបង្ខំគាត់
ឲ្យលីឈើឆ្កាងរបស់ព្រះអង្គ។ 33 លុះពួកគេមកដល់កន្លែងមួយឈ្មោះ គាល់កូថា ដែលប្រែថា «ភ្នំលលាដ៍ក្បាល»។ 34 គេយកស្រាទំពាំងបាយជូរលាយជា
មួយប្រមាត់ មកឲ្យព្រះអង្គសោយ ប៉ុន្តែព្រះយេស៊ូក្រេបបន្តិច ព្រះអង្គពុំព្រមសោយទេ។ 35 ក្រោយពីឆ្កាងព្រះអង្គរួចហើយ ពួកគេយកសម្លៀកបំពាក់របស់
ព្រះអង្គមកចាប់ឆ្នោតចែកគ្នា 36 រួចហើយពួកគេអង្គុយយាមព្រះអង្គនៅទីនោះ។ 37 គេបានសរសេរប្រកាសដាក់ខាងលើព្រះសិរសារបស់ព្រះអង្គ អំពីហេតុ
ដែលគេធ្វើទោសព្រះអង្គថា៖ «អ្នកនេះគឺយេស៊ូ ជាស្ដេចជនជាតិយូដា»។ 38 ពួកគេបានឆ្កាងចោរពីរនាក់ជាមួយនិងព្រះយេស៊ូដែរ ម្នាក់នៅខាងស្ដាំ ម្នាក់ទៀត
នៅខាងឆ្វេង។ 39 មនុស្សម្នាដែលដើរកាត់តាមនោះ នាំគ្នាប្រមាថមើលងាយព្រះអង្គ គ្រវីក្បាលដាក់ព្រះអង្គ 40 ទាំងពោលថា៖ «អ្នករុះព្រះវិហារ ហើយសង់
ឡើងវិញតែបីថ្ងៃអើយ! ចូរសង្គ្រោះខ្លួនឯងមើល! បើអ្នកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន អញ្ជើញចុះពីឈើឆ្កាងមកមើល៍!» 41 ពួកនាយកបូជាចារ្យ ពួក
អាចារ្យ និងពួកព្រឹទ្ធាចារ្យក៏នាំគ្នាចំអកដាក់ព្រះអង្គដូចគេដែរ ដោយនិយាយថា៖ 42 «គាត់បានសង្គ្រោះអ្នកឯទៀតៗ តែមិនអាចសង្គ្រោះខ្លួនឯងបានទេ។ គាត់
ជាស្ដេចអ៊ីស្រាអែល ឲ្យគាត់ចុះពីឈើឆ្កាងឥឡូវនេះមក ដើម្បីឲ្យយើងជឿផង។ 43 គាត់បានទុកចិត្តលើព្រះជាម្ចាស់ ទុកឲ្យព្រះអង្គដោះលែងគាត់ឥឡូវនេះទៅ
បើព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងគាត់មែន។ ដ្បិតគាត់ពោលថា៖ «ខ្ញុំជាព្រះបុត្រារបស់ព្រះជាម្ចាស់»។ 44 សូម្បីតែចោរដែលជាប់ឆ្កាងជាមួយព្រះយេស៊ូ ក៏
ជេរប្រមាថព្រះអង្គដូច្នោះដែរ។ 45 ផែនដីទាំងមូលងងឹតសូន្យចាប់ពីម៉ោងប្រាំមួយ រហូតដល់ម៉ោងប្រាំបួន។ 46 ប្រមាណជាម៉ោងបីរសៀល ព្រះយេស៊ូស្រែក
ខ្លាំងៗថា៖ «អេលី» អេលីឡាម៉ាសាបាច់ថានី? ដែលមានន័យថា «ឱព្រះជាម្ចាស់ ជាព្រះនៃទូលបង្គំអើយ! ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ?»
47 ពេលអ្នកខ្លះឈរនៅទីនោះបានឮព្រះបន្ទូលរបស់ព្រះអង្គ ក៏និយាយថា៖ «គាត់កំពុងហៅលោកអេលីយ៉ា»។ 48 ភ្លាមនោះ មានគ្នាគេម្នាក់រត់ទៅយក
សារ៉ាយស្ងួត ជ្រលក់នឹងទឹកខ្មេះ រុំជាប់នៅចុងត្រែងមួយដើម ហើយហុចថ្វាយព្រះអង្គសោយ។ 49 អ្នកឯទៀតៗពោលថា៖ «ចាំមើលមើល៍! តើលោកអេលីយ៉ា
មកសង្គ្រោះគាត់ឬទេ?» 50 បន្ទាប់មកព្រះយេស៊ូស្រែកយ៉ាងខ្លាំងម្ដងទៀត រួចផុតវិញ្ញាណទៅ។ 51 ពេលនោះ វាំងននៅក្នុងព្រះវិហារ ក៏រហែកជាពីរ តាំងពី
លើចុះដល់ក្រោម ផែនដីក៏រញ្ជួយផ្ទាំងថ្មក៏ប្រេះចេញពីគ្នា។ 52 ផ្នូរក៏របើកចំហឡើង ហើយសាកសពប្រជាជនដ៏វិសុទ្ធជាច្រើនបានរស់ឡើងវិញ។ 53 ពួកគេក៏
ចេញពីផ្នូរ ក្រោយពេលទ្រង់មានព្រះជន្មរស់ឡើងវិញ គេបានចូលទៅក្នុងក្រុងដ៏វិសុទ្ធ ព្រមទាំងបង្ហាញខ្លួនឲ្យមនុស្សជាច្រើនបានឃើញផង។ 54 កាលនាយ
ទាហានរ៉ូម៉ាំង និងពួកទាហានដែលនៅយាមព្រះយេស៊ូ បានឃើញផែនដីរញ្ជួយ និងបានឃើញហេតុការណ៍ដែលបានកើតឡើងដូច្នេះ គេមានការភ័យជាខ្លាំង
ហើយពោលថា៖ លោកនេះ ពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន! 55 មានស្ត្រីជាច្រើនមើលពីចម្ងាយ គឺស្ត្រីៗដែលតាមបំរើព្រះយេស៊ូ តាំងពីស្រុកកាលីឡេ
មក។ 56 ក្នុងចំណោមស្ត្រីៗទាំងនោះ មាននាងម៉ារីម៉ាដាឡា នាងម៉ារី ជាម្ដាយរបស់យ៉ាកុប និងយ៉ូសែប ព្រមទាំងភរិយារបស់លោកសេបេដេ។ 57 លុះដល់
ល្ងាចចូលមកដល់ មានអ្នកមានម្នាក់ ឈ្មោះយ៉ូសែប ជាអ្នកក្រុងអើរីម៉ាថេ មកដល់ គាត់ក៏ជាសិស្សរបស់ព្រះយេស៊ូដែរ។ 58 គាត់បានទៅជួបលោកពីឡាតសុំ
យកព្រះសពព្រះយេស៊ូ ក្រោយមកលោកពីឡាតក៏បញ្ជាឲ្យគេប្រគល់ព្រះសពមកគាត់។ 59 លោកយ៉ូសែបយកព្រះសពមករុំនឹងក្រណាត់ផាឱបថ្មី 60 រួចដាក់
ក្នុងផ្នូរថ្មីរបស់គាត់ ជារូងថ្មដែលគេដាប់ធ្វើផ្នូរ។ បន្ទាប់មក គាត់ប្រមៀលថ្មមួយដុំធំបិទមាត់ផ្នូរ ហើយចាកចេញទៅ។ 61 នាងម៉ារីម៉ាដាឡា និងនាងម៉ារីម្នាក់
ទៀត ក៏នៅទីនោះដែរ នាងអង្គុយនៅមុខផ្នូរ។ 62 នៅថ្ងៃបន្ទាប់ ជាថ្ងៃរៀបចំថ្ងៃឈប់សម្រាក ពួកនាយកបូជាចារ្យ និងពួកខាងគណៈផារីស៊ី នាំគ្នាទៅជួបលោក

 generated on Thu Feb 8 15:37:30 2024

ពីឡាត 63 គេជម្រាបថា៖ «លោកម្ចាស់! យើងខ្ញុំនៅចាំពាក្យរបស់ជនបោកប្រាស់នោះ កាលពីគាត់នៅរស់ថា បីថ្ងៃក្រោយពីបានខ្ញុំស្លាប់ នោះខ្ញុំនឹងមានជីវិតរស់
ឡើងវិញ។ 64 ហេតុនេះ សូមលោកបញ្ជាឲ្យគេយាមផ្នូរនោះ រហូតដល់ថ្ងៃទីបីទៅ ក្រែងលោសិស្សរបស់គាត់មកលួចយកសព ហើយប្រាប់ប្រជាជនថាគាត់រស់
ឡើងវិញ។ ការបោកប្រាស់លើកនេះ មុខជាអាក្រក់ជាងមុនទៅទៀត»។ 65 លោកពីឡាតមានប្រសាសន៍ទៅគេថា៖ «អស់លោកមានទាហានស្រាប់ហើយ សុំ
អញ្ជើញទៅចាត់ចែងឲ្យគេយាមផ្នូរ តាមអស់លោកយល់ឃើញទៅចុះ»។ 66 ពួកគេក៏នាំគ្នាចេញទៅចាត់ចែងឲ្យយាមផ្នូរ គឺភ្ជិតផ្នូរ បោះត្រាពីលើ និងដាក់
ទាហានឲ្យនៅយាមផង។


generated on Thu Feb 8 15:37:30 2024

## ជំពូក 28

1 ក្រោយថ្ងៃសប្ប័ទ គឺនៅព្រឹកថ្ងៃអាទិត្យ នាងម៉ារីម៉ាដាឡា និងនាងម៉ារីម្នាក់ទៀតនាំគ្នាទៅមើលផ្នូរ។ 2 ពេលនោះ ស្រាប់តែផែនដីរញ្ជួយយ៉ាងខ្លាំង ដ្បិតមាន
ទេវតារបស់ព្រះអម្ចាស់ ចុះពីស្ថានបរមសុខមកប្រមៀលថ្មចេញពីមាត់ផ្នូរ ហើយអង្គុយលើថ្មនោះថែមទៀតផង។ 3 ទេវតានោះមានទ្រង់ទ្រាយភ្លឺដូចផ្លេកបន្ទោរ
ហើយមានសម្លៀកបំពាក់សដូចសំឡី។ 4 ទាហានភ័យញ័រជាខ្លាំង ភាំងស្មារតីដូចមនុស្សស្លាប់។ 5 ទេវតានិយាយទៅកាន់ស្ត្រីៗថា៖ «កុំភ័យខ្លាចអ្វី! ខ្ញុំដឹងថា
នាងៗ មករកព្រះយេស៊ូ ដែលគេបានឆ្កាង។ 6 ព្រះអង្គមិននៅទីនេះទេ ព្រះអង្គរស់ឡើងវិញហើយ ដូចទ្រង់មានព្រះបន្ទូលរួចមកហើយ។ សុំមកមើលកន្លែង
ដែលគេដាក់ព្រះសពព្រះអង្គឯណេះសិន។ 7 សឹមអញ្ជើញទៅប្រាប់ពួកសិស្សរបស់ព្រះអង្គជាប្រញាប់ ថាព្រះអង្គមានព្រះជន្មរស់ឡើងវិញហើយ ឥឡូវនេះ
ព្រះអង្គយាង ទៅស្រុកកាលីឡេមុនអ្នករាល់គ្នា។ នៅទីនោះ អ្នករាល់គ្នានឹងឃើញព្រះអង្គ»។ 8 ស្ត្រីទាំងនោះប្រញាប់ប្រញាល់ចេញពីផ្នូរ ទាំងភ័យផងទាំង
អរផង ហើយរត់យកដំណឹងនេះរត់ទៅជម្រាបប្រាប់ពួកសិស្ស។ 9 ពេលនោះ ព្រះយេស៊ូយាងមកជួបពួកនាង ដោយមានព្រះបន្ទូលថា៖ «ជម្រាបសួរនាង!»
នាងទាំងនោះក៏ចូលមកឱបព្រះបាទា ហើយក្រាបថ្វាយបង្គំព្រះអង្គ។ 10 បន្ទាប់មកព្រះយេស៊ូមានព្រះបន្ទូលថា៖ «កុំភ័យខ្លាចអ្វីឡើយ! សុំទៅប្រាប់បងប្អូនខ្ញុំឲ្យ
ទៅស្រុកកាលីឡេទៅ គេនឹងឃើញខ្ញុំនៅទីនោះ»។ 11 កាលស្ត្រីទាំងនោះកំពុងតែធ្វើដំណើរទៅ ទាហានខ្លះក៏នាំគ្នាចូលទៅទីក្រុង ជម្រាបពួកនាយកបូជាចារ្យ
អំពីហេតុការណ៍ទាំងប៉ុន្មាន ដែលកើតឡើង។ 12 ពេលនោះពួកនាយកបូជាចារ្យក៏ប្រជុំពិភាក្សាគ្នា ជាមួយពួកព្រឹទ្ធាចារ្យ ហើយសម្រេចចិត្តឲ្យប្រាក់យ៉ាងច្រើន
ដល់ពួកទាហាន 13 ទាំងប្រាប់ថាត្រូវនិយាយថាពេលយើងខ្ញុំកំពុងដេកលក់ មានសិស្សរបស់អ្នកនោះមកលួចយកសពទៅទាំងយប់»។ 14 ប្រសិនបើរឿងនេះ
លេចឮដល់លោកទេសាភិបាល ចាំយើងជួយដោះស្រាយ ដើម្បីកុំឲ្យអ្នករាល់គ្នាមានទោស។ 15 ពួកទាហានទទួលយកប្រាក់ ហើយធ្វើតាមសេចក្ដីដែលគេ
បង្គាប់ រឿងនេះក៏លេចឮសុសសាយក្នុងចំណោមជនជាតិយូដា រហូតមកទល់សព្វថ្ងៃ។ 16 សិស្សទាំងដប់មួយរូប នាំគ្នាធ្វើដំណើរទៅស្រុកកាលីឡេ ហើយ
ឡើងទៅលើភ្នំដែលព្រះយេស៊ូបានប្រាប់ឲ្យគេទៅ។ 17 កាលគេបានឃើញព្រះអង្គ គេក្រាបថ្វាយបង្គំ ប៉ុន្តែមានអ្នកខ្លះនៅមានការសង្ស័យនៅឡើយ។ 18
ព្រះយេស៊ូយាងចូលមកជិតពួកគេ ហើយមានព្រះបន្ទូលថា៖ «គ្រប់ទាំងអំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដីបានប្រគល់មកខ្ញុំហើយ។ 19 ដូច្នេះ
ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាសិស្ស ហើយធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ 20 ចូរបង្រៀនគេ
ឲ្យប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក»។


generated on Thu Feb 8 15:37:30 2024